សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Universite Royale de Droit et des Sciences Economiques
Royal University of Law and Ecnomics

## សារណាបញ្ចប់ការសិក្សា

# បណ្តឹងសុំមោឃភាពនីតិវិធី

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ក. លន់ លក្ខិណា**

សាស្ត្រាចារ្យណែនាំ
លោក **រុន ពណ្ណារិទ្ធ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **លន់ លក្ខិណា** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រជំនាន់ទី ២០ នៃសាលកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាដំបូង នាងខ្ញុំសូមធ្វើការដឹងគុណ និងគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះអ្នកម្តាយ **លន់ សំរិទ្ធ** ចំពោះការលះបង់ទាំងកម្លាំងកាយ កម្លាំងចិត្តក្នុងការខិតខំចិញ្ចឹមបីបាច់ថែរក្សា និងផ្តត់ផ្គង់ក៏ដូចជាផ្តល់ឱកាសក្នុងការរៀនសូត្រចាប់តាំងពីដើមរហូតមកដល់ពេលនេះ ព្រមទាំងអប់រំទូន្មានប្រៀនប្រដៅកូនឱ្យក្លាយជាកូនល្អ សិស្សល្អ ព្រមទាំងជាពលរដ្ឋល្អនៅក្នុងសង្គមផងដែរ ដែលទាំងនេះជាគុណូបការៈដ៏មានអត្ថន័យជ្រាលជ្រៅកាត់ថ្លៃពុំបានចំពោះកូន។

ទន្ទឹមនឹងនេះ សូមថ្លែងអំណរគុណជូនចំពោះ ឯកឧតម្ត សាកលវិទ្យាធិការ សាកលវិទ្យាធិការង គណៈគ្រប់គ្រង សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាពិសេសសូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម **រុន ពណ្ណារិទ្ធ** ដែលជាសាស្ត្រចារ្យណែនាំក្នុងការធ្វើសារណាបញ្ចប់ការសិក្សានេះ ដោយលោកបានខិតខំចំណាយទាំងកម្លាំងកាយ និងចិត្តក្នុងការពន្យល់ ណែនាំ កែតម្រូវចំណុចខ្វះខាតនៃសារណាបញ្ចប់ការសិក្សានេះ។ ជាមួយគ្នានេះដែរ សូមធ្វើការថ្លែងអំណរគុណ ជូនចំពោះ លោកស្រីសាស្ត្រចារ្យ **ចាំង ស៊ីណាត** ដែលបានខិតខំទាំងកម្លាំងកាយ និងចិត្តក្នុងការផ្តល់នូវមតិយោបល់ ក៏ដូចជាគន្លឹះសំខាន់ៗក្នុងការបំពេញបន្ថែមចំណុចខ្វះខាតលើសារណាបញ្ចប់ការសិក្សានេះផងដែរ។

ជាចុងក្រោយ នាងខ្ញុំសូមធ្វើការគោរពជូនពរ ជូនចំពោះ លោកអ្នកមានគុណ ក្រុមគ្រួសារ ឯកឧតម្ត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រី សាស្ត្រាចារ្យ ទាំងអស់ មានសុខភាពល្អ សំណាងល្អ និងជោគជ័យគ្រប់ភារកិច្ចការងារ។

# អារម្ភកថា

បន្ទាប់ពីឆ្លងកាត់ការសិក្សារយៈពេល ៤ឆ្នាំ នៅសាលកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចរួចមក នាងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធាបទ **បណ្តឹងសុំមោឃភាពនីតិវិធី** ដែលទទួលបាការដឹកនាំអំពីលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** ដើម្បីសិក្សាស្រាវជ្រាវ ក៏ដូចជាចងក្រងឡើងជាសារណាបញ្ចប់ការសិក្សា។

ការលើកយក **បណ្តឹងសុំមោឃភាពនីតិវិធី** នេះមកធ្វើជាប្រធានបទនៃសារណាបញ្ចប់ការសិក្សា គឺមិនមែនជាភាពចៃដ្យនោះទេ ដោយហេតុថាប្រធានបទ មោឃភាពនេះគឺមានសារៈសំខាន់ណាស់នៅក្នុងការអនុវត្តនីតិវិធី ដែលវាជាផ្នែកមួយនៃការធានាបាននូវភាពយុត្តិធម៌ ក៏ដូចជាការគោរពនូវសិទ្ធិនៃការការពារខ្លួនជាដើម។ ជាក់ស្តែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ២០០៧ មានការកំណត់យ៉ាងជាក់លាក់អំពីមូលហេតុ ដែលអាចនាំឱ្យមានការប្តឹងសុំមោឃភាពផងដែរ កាលណាការអនុវត្តនីតិវិធីណាមួយដែលមានភាពមិនប្រក្រតី ក៏ដូចជាមានការរំលោភបំពាន ឬការអនុវត្តនោះមានភាពផ្ទុយអំពីបញ្ញត្តិដែលបានកំណត់នៅក្នុងច្បាប់ដែលនៅជាធរមានជាដើម។ ដូចនេះហើយ ចំណុចទាំងនេះ គឺជាចំណុចដែលគួរតែយកចិត្តទុកដាក់ឱ្យបានខ្ពស់ក្នុងការអនុវត្តឱ្យបានត្រឹមត្រូវទៅតាមទម្រង់ ក៏ដូចជាបែបបទនៃនីតិវិធី ពីព្រោះថាមោឃភាពនីតិវីធី គឺសំដៅទៅលើការដែលចាត់ទុកកិច្ច ឬ លិខិតណាមួយជាមោឃៈ មិនអាចយកជាការបាននៅក្នុងសំណុំរឿង។ ជាមួយគ្នានេះដែរ កាលណាកិច្ចនីតិវិធីណាមួយត្រូវបានអនុវត្តហើយតែបែជាត្រូវទុកជាមោឃភាពចោល នេះជាបញ្ហាមួយដែលនាំឱ្យមានការខាតបង់ពេលវេលាក្នុងការអនុវត្ត ដែលនាំឱ្យមានភាពយឺតយ៉ាវជាដើម។ មួយវិញទៀតកត្តាទាំងនេះ ក៏ជាផ្នែកមួយដែរនាំឱ្យមានការបាត់បង់នូវជំនឿចិត្តលើប្រព័ន្ធតុលាការ អំពីអ្នកដែលទទួលសេវាផងដែរ។ ចំណែកឯចំណុចដែលគួរឱ្យចាប់អារម្មណ៍មួយទៀតនោះគឺ កាលណាដែលមានការមោឃភាពនីតិវិធី នឹងនាំឱ្យមានការបាត់បង់នូវវត្ថុតាង ដែលជាមូលដ្ឋានដ៏រឹងមាំក្នុងការចោទប្រកាន់ មិនតែប៉ុណ្ណោះថែមទាំង ធ្វើអោយបុគ្គលដែលមានពិរុទ្ធគ្រប់គ្រាន់ បែជាត្រូវរួចខ្លួនពីការទទួលខុសត្រូវលើអំពើរបស់ខ្លួនទៅវិញ។ លើសពីនេះទៅទៀត មោឃភាពនីតវិធី ក៏ជានីតិវិធីមួយដែលផ្តល់ផលប្រយោជន៍ក្នុងការការពារខ្លួនទៅលើជនដែលស្លូតត្រង់ ដែលត្រូវបានគេរំលោភបំពានសិទ្ធិនៃការការពារខ្លួនផងដែរ។

សរុបជារួមមក នាងខ្ញុំសង្ឃឹមថា សារណាបញ្ចប់ការសិក្សានេះ ដែលរួមមានការលើកឡើងអំពីទ្រឹស្តីគតិយុត្ត ព្រមទាំងរួមបញ្ចូលជាមួយការអនុវត្តជាក់ស្តែងមួយចំនួនផងដែរ នឹងអាចធ្វើជាឯកសារជំនួយក្នុងការសិក្សាស្រាវជ្រាវ។ ទន្ទឹមនឹងនេះផងដែរ នាងខ្ញុំ សូមធ្វើការអធ្យាស្រ័យទុកជាមុន ចំពោះចំណុចខ្វះខាត កំហុសខុសឆ្គងទាំងខ្លឹមសារ ឃ្លាប្រយោគ ព្រមទាំងអក្ខរាវិរុទ្ធ ដោយអចេតនាប្រការណាមួយ។ នាងខ្ញុំរង់ចាំទទួលមតិរិះគន់ដើម្បីស្ថាបនា ឱ្យកាន់តែមានភាពល្អប្រសើរឡើងសម្រាប់នាពេលខាងមុខដោយក្តីរីករាយ។

# មាតិកា

ទំព័រ

សេចក្តីផ្តើម ........................................................ ១

## ជំពូកទី១

## អត្ថន័យ និងមូលហេតុនៃបណ្តឹងសុំមោឃភាពនីតិវិធី

**កថាខណ្ឌទី១៖ អត្ថន័យបណ្តឹងសុំមោឃភាព** ........................................ ៣

១.១. ស្ថាប័នមានសមត្ថកិច្ច ........................................ ៣

១.២. បុគ្គលដែលមានសិទ្ធិប្តឹង ........................................ ៤

១.៣. ចិរវេលានៃការប្តឹង ........................................ ៤

**កថាខណ្ឌទី២៖ មូលហេតុមោឃភាពនៃនីតិវិធី** ........................................ ៤

២.១. មោឃភាពនៃនីតិវិធីដោយសារការបំពានវិធានដែលច្បាប់បានកំណត់ ........................................ ៥

ក. ការបំពានវិធានដែលច្បាប់បានកំណត់ក្នុងដំណាក់កាលស៊ើបអង្កេត ........................................ ៥

ខ. ការបំពានវិធានដែលច្បាប់បានកំណត់ក្នុងដំណាក់កាលស៊ើបសួរ ........................................ ១៤

២.២. មោឃភាពនៃនីតិវិធីដោយសារការបំពានធ្ងន់ធ្ងរដល់សិទ្ធិការការពារខ្លួន ........................................ ១៧

## ជំពូកទី២

## នីតិវិធីសម្រេចលើបណ្តឹងសុំមោឃភាព

**កថាខណ្ឌទី១៖ ចំណាត់ការមុនកិច្ចពិភាក្សាដេញដោល** ........................................ ១៩

១.១. ការដាក់ពាក្យបណ្តឹង ........................................ ១៩

១.២. ការបញ្ជូនសំណុំរឿង ........................................ ២០

១.៣. ការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះ ........................................ ២១

១.៤. ការជូនដំណឹងអំពីកិច្ចពិភាក្សាដេញដោល ........................................ ២១

១.៥. របាយការណ៍សំណុំរឿងមោឃភាព ........................................ ២២

១.៦. ការពិគ្រោះសំណុំរឿង និងសារណា ........................................ ២៤

**កថាខណ្ឌទី២៖ ចំណាត់ការនាពេលកិច្ចពិភាក្សាដេញដោល** ........................................ ២៤

២.១. ដំណើរការនៃកិច្ចពិភាក្សាដេញដោល ........................................ ២៤

២.២. ការសម្រេចសេចក្តីលើបណ្តឹងសុំមោឃភាព ........................................ ២៥

២.២.១. ភាពដែលមិនអាចទទួលយកបាននៃពាក្យបណ្តឹង ........................................ ២៥

២.២.២. ការទទួលយកពាក្យបណ្តឹង ........................................ ២៦

**កថាខណ្ឌទី៣៖ ចំណាត់ការក្រោយកិច្ចពិភាក្សាដេញដោល** ........................................ ២៧

## ជំពូកទី៣
## សេចក្តីសម្រេចលើបណ្តឹងសុំហេយភាព


**កថាខណ្ឌទី១៖ ការបង្វិលសំណុំរឿងទៅចៅក្រមវិញ**..................................................... ៣០

**កថាខណ្ឌទី២៖ ការដកហូតសំណុំរឿង ហើយបង្វិលទៅកាន់ចៅក្រមផ្សេង** .................. ៣០

**កថាខណ្ឌទី៣៖ ការបន្តការស៊ើបសួរដោយសភាស៊ើបសួរ**................................................ ៣០

**សេចក្តីសន្និដ្ឋាន** .............................................................................................................. ៣២

**មតិយោបល់**........................................................................................................................ ៣៤

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ដំណើរការនៃការអនុវត្ត នៅក្នុងសំណុំរឿងនីមួយៗទាមទារឱ្យមានការគោរពទៅលើបទបញ្ញត្តិដែលច្បាប់បានកំណត់ឱ្យបានត្រឹមត្រូវ ចាប់តាំងពីដំណាក់កាលនៃកសាងសំណុំរឿង រហូតដល់ដំណាក់កាលនៃការសម្រេចសេចក្តី។ ដោយហេតុថាការអនុវត្តដែលមិនបានគោរពឱ្យបានត្រឹមត្រូវទៅតាមបញ្ញត្តិនៃច្បាប់ អាចនាំឱ្យមានការប្តឹងសុំមោឃភាពនីតិវិធី។ ពាក្យថា **មោឃភាព** សំដៅលើការដែលចាត់ទុកថាកិច្ចដែលបានបំពេញរួចនោះ ពុំអាចយកជាការបានក្នុងការអនុវត្ត។ មួយវិញទៀតបញ្ញត្តិដែលមានចែង គឺមានលក្ខណៈដាច់ខាតត្រូវតែគោរព។ ដូចនេះ នៅពេលដែលមានការបំពានកិច្ច ឬទម្រង់ណាមួយដែលធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍របស់ភាគី ឬសិទ្ធិនៃការការពារខ្លួននោះគេអាចធ្វើការប្តឹងសុំមោឃភាពបាន។

ការលើកឡើងនូវបញ្ហាខាងលើនេះ បាននាំឱ្យមានសំណួរគតិយុត្តិចោទឡើងថា **តើមោឃភាពត្រូវបានកើតឡើងនៅពេលណា ហើយក្នុងគោលបំណងអ្វី? មួយវិញទៀតតើមានមូលហេតុ ក៏ដូចជាលក្ខខណ្ឌណាខ្លះដែលអាចប្តឹងសុំមោឃភាពនីតិវិធីបាន? ហើយចំពោះនីតិវិធីនៃបណ្តឹងសុំមោឃភាពមានដំណើរការយ៉ាងដូចម្តេចខ្លះ? លើសពីនេះទៅទៀត នៅពេលដែលមានមោឃភាពនីតិវិធី និងមានអានុភាពបែបណាកើតឡើង?**

គោលបំណងនៃការជ្រើសរើសប្រធានបទ បណ្តឹងសុំមោឃភាពនីតិវិធី នេះមកធ្វើជាសារណាបញ្ចប់ការសិក្សា គឺដោយហេតុថា បញ្ហាមួយនេះត្រូវបានអ្នកវិជ្ជាជីវៈមួយចំនួនបានមើលរំលង ហើយមួយវិញទៀត ប្រធានបទនេះចំណុចសំខាន់ដែលអាចផ្តល់នូវសិទ្ធិជូនជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើការប្តឹងទៅលើកិច្ចណាមួយដែលពួកគេយល់ឃើញថាមានភាពមិនប្រក្រតីនៅក្នុងការអនុវត្ត ដែលអាចជាការរំលោភបំពានសិទ្ធិរបស់ពួកគេ។ មិនតែប៉ុណ្ណោះ ការដែលអនុវត្តនីតិវិធីពុំត្រឹមត្រូវ ឬមានការធ្វេសប្រហែសអាចនាំឱ្យជនខិលខូចរួចផុតពីការទទួលខុសត្រូវលើអំពើរបស់ពួកគេ។

នៅក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ គឺធ្វើការផ្តោតសំខាន់តែទៅលើមោឃភាពដែលកើតមានឡើងនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេត ព្រមទាំងដំណាក់នៃការស៊ើបសួរតែប៉ុណ្ណោះ។ ដោយហេតុថានៅក្នុងដំណាក់កាលទាំងពីរនេះ មានការប្តឹងសុំមោឃភាពជាញឹកញាប់លើការអនុវត្តនីតិវិធីមួយចំនួន។ ដោយធ្វើការសិក្សាផ្អែកទៅលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលនៅជាធរមាន។

ដើម្បីធ្វើការសម្រេចបាននូវគោលបំណងនៃសារណានេះ គឺធ្វើការសិក្សាលើឯកសារដែលមានលក្ខណៈជាទ្រឹស្តីដែលពាក់ព័ន្ធទៅនឹង ប្រធានបទ បណ្តឹងសុំមោឃភាពនីតិវិធី រួមផ្សំនឹងការសាកសួរអំពីអ្នកអនុវត្តជាក់ស្តែងផ្ទាល់ ដែលរួមមាន ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងអ្នកដែលពាក់ព័ន្ធដទៃទៀតផងដែរ។ ចំពោះ ឯកសារដែលជាទ្រឹស្តី រួមមានលិខិតបដ្ឋានគតិយុត្តិជាតិ និងអន្តរជាតិ សៀវភៅ គេហទំព័រជាដើម។ ជាមួយគ្នានេះ

ដែរ ក៏រួមមាននូវលិខិតបទដ្ឋានគតិយុត្តដែលអនុវត្តនៅក្នុងបណ្តឹងសុំមោឃភាពនេះផងដែរ។ ចំពោះរចនាសម្ព័ន្ធនៃសារណាបញ្ចប់ការសិក្សានេះ ត្រូវបានបែងចែកចេញជា ៣ជំពូកធំៗ ដែលរួមមាន៖

- ជំពូកទី១៖ អត្ថន័យ និងមូលហេតុនៃមោឃភាពនីតិវិធី
- ជំពូកទី២៖ នីតិវិធីសម្រេចលើបណ្តឹងសុំមោឃភាព
- ជំពូកទី៣៖ សេចក្តីសម្រេចលើបណ្តឹងសុំមោឃភាព

ចុងបញ្ចប់នៃសារណានេះ គឺជាសេចក្តីសន្និដ្ឋា រួមជាមួយមតិយោបល់ ទៅលើប្រធានបទទាំងមូល ព្រមទាំងមានការភ្ជាប់ជាមួយនឹងឯកសារយោង និងឧបសម្ព័ន្ធផងដែរ។

# ជំពូកទី១
# អត្ថន័យ និងមូលហេតុនៃបណ្តឹងសុំមោឃភាព
# នីតិវិធី

# ជំពូកទី១

# អត្ថន័យ និងមូលហេតុនៃបណ្តឹងសុំមោឃភាពនីតិវិធី

## កថាខណ្ឌទី១៖ អត្ថន័យនៃបណ្តឹងសុំមោឃភាព

មោឃភាព សំដៅទៅលើការទុកជាមោឃៈលើកិច្ច ឬ លិខិតទាំងឡាយណាដែលកើតចេញពីភាពមិនស្រប ច្បាប់ណាមួយ ឬ ការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់ និងពិសេសទៅលើទម្រង់ពាក់ព័ន្ធនឹងសិទ្ធិនៃការការពារខ្លួន។

មោឃភាព គឺជាទណ្ឌកម្មចំពោះការមិនគោរពលក្ខខណ្ឌសុពលភាពនៃកិច្ចតតិយុត្ត[1]។

### ១.១. ស្ថាប័នមានសមត្ថកិច្ចសម្រេចលើបណ្តឹងសុំមោឃភាព

សាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា រួមមាន សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល។ សាលាដំបូង ជាសាលាជម្រះក្តីជាន់ទាប។ សាលាឧទ្ធរណ៍ និងតុលាការកំពូលជាសាលាជម្រះក្តីជាន់ខ្ពស់[2]។

សាលាឧទ្ធរណ៍ ជាសាលាជម្រះក្តីថ្នាក់ទីពីរ ដែលនៅក្នុងនោះមានការបែងចែកជាសភាជំនាញ ដែលរួមមាន ៖ សភារដ្ឋប្បវេណី សភាព្រហ្មទណ្ឌ សភាការងារ សភាពាណិជ្ជកម្ម និងសភាស៊ើបសួរ[3]។ សភាស៊ើបសួរមានសមត្ថកិច្ចក្នុងការដោះស្រាយលើបណ្តឹងនានាចំពោះកិច្ចស៊ើបសួរ ឬដីកាសម្រេចនានារបស់ចៅក្រមស៊ើបសួរ និងរឿងក្តីផ្សេងទៀតដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន[4]។ ដូចនេះ ពាក់ព័ន្ធនឹងការប្តឹងសុំមោឃភាព គឺជាសមត្ថកិច្ចរបស់សភាស៊ើបសួរ ដែរជាសភាជំនាញរបស់សាលាឧទ្ធរណ៍ ដូចដែរមានការលើកឡើងពីខាងដើមអំពីសមត្ថកិច្ចរបស់សភាស៊ើបសួរ។ មួយវិញនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលនៅជាធរមានក៏បានបញ្ជាក់យ៉ាងច្បាស់ថា មានតែសភាស៊ើបសួរប៉ុណ្ណោះដែលមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យមោឃភាពនៃលិខិតនៃនីតិវិធី[5]។ ប៉ុន្តែ ការលើកឡើងថា មានតែសភាស៊ើបសួរ ប៉ុណ្ណោះដែលមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យទៅលើបណ្តឹងសុំមោឃភាពនេះ គឺស្ថិតតែក្នុងករណីដែលមានការបើកការស៊ើបសួរ តែប៉ុណ្ណោះ។ ក្នុងករណីដែល ការចោទប្រកាន់មិនឆ្លងកាត់ការបើកការស៊ើបសួរនោះទេ មោឃភាពអាចធ្វើការលើកឡើងនៅចំពោះមុខយុត្តាធិកាជំនុំជម្រះបាន។ ការលើកឡើងបែបនេះ គឺផ្អែកទៅលើការលុបលាងមោឃភាពដោយដីកាដំណោះស្រាយ។ កាលណាដីកាដំណោះស្រាយចូលជាស្ថាពរ លុបលាង

[1] ការផ្សព្វផ្សាយរបស់សាលាត្រាជូ ទ្រឹស្តីនៃមោឃភាពនៃលិខិត ឬកិច្ចនីតិវិធីព្រហ្មទណ្ឌ ប្រែសម្រួលដោយ លោក ចក សម្បត្តិ http://salatraju.com/index.php/post?p=29

[2] មាត្រា ៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

[3] មាត្រា ៣៧ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

[4] មាត្រា ៤៥ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

[5] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៥៣

មោឃភាពនីតិវិធីមុន ប្រសិនបើមាន។ គ្មានមោឃភាពណាមួយនៃនីតិវិធីមុន ត្រូវបានលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះបានទៀតឡើយ[6]។ ដូចនេះ ក្នុងករណីដែលពុំបានឆ្លងកាត់ការបើកការស៊ើបសួរ មោឃភាពអាចធ្វើការលើកឡើងចំពោះមុខតុលាការជំនុំជម្រះ ដោយផ្អែកលើការបកស្រាយនៃមាត្រា ២៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ១.២. បុគ្គលដែលមានសិទ្ធិប្តឹងសុំមោឃភាព

ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ២០០៧ បានកំណត់អំពីបុគ្គលដែនមានសិទ្ធិក្នុងការប្តឹងសុំមោឃភាពលើកិច្ច ឬ លិខិតនៃនីតិវិធីណាមួយដែលខ្លួនយល់ឃើញថាកិច្ចនោះមានភាពមិនប្រក្រតី កិច្ចនោះធ្វើមិនត្រឹមត្រូវតាមក្រមនីតិវិធី ឬកិច្ចនោះធ្វើឡើងដោយមានការរំលោភបំពានសិទ្ធិនៃការការពារខ្លួនយ៉ាងធ្ងន់ធ្ងរក្នុងការអនុវត្ត។

**បុគ្គលទាំងនោះរួមមានៈ**

- ចៅក្រមស៊ើបសួរ
- ព្រះរាជអាជ្ញា
- ជនត្រូវចោទ
- ដើមបណ្តឹងរដ្ឋប្បវេណី[7]។

### ១.៣. ចិរវេលានៃការប្តឹងសុំមោឃភាព

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៧ ពុំមានបញ្ញត្តិណាមួយដែលមានចែងអំពីចិរវេលាដែលអាចធ្វើការប្តឹងសុំមោឃភាពនីតិវិធី ដោយមានភាពជាក់លាក់នោះទេ។ ប៉ុន្តែ បើទោះបីជាពុំមានបញ្ញត្តិដែលចែងជាក់លាក់បែបនេះក៏ដោយ ក៏នៅមានការចង្អុលបង្ហាញអំពីបញ្ញត្តិនៃមាត្រា ២៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលអាចឱ្យដឹងបានថា តើការប្តឹងសុំមោឃភាពអាចធ្វើនៅពេលណា។ បញ្ញត្តិនៃមាត្រា ២៥៦ បានលើកឡើងអំពី ការលុបលាងមោឃភាពដោយដីកាដំណោះស្រាយ ហើយបានធ្វើការបញ្ជាក់ថា គ្មានមោឃភាពណាមួយដែលត្រូវលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះនោះទេ។

ដូចនេះ បង្ហាញឱ្យឃើញថា ការប្តឹងសុំមោឃភាពលើកិច្ច ឬ លិខិតណាមួយនៃនីតិវិធីអាចធ្វើបាននៅមុនពេលដែលដីកាដំណោះស្រាយចូលជាស្ថាពរ។

## កថាខណ្ឌទី២ៈ មូលហេតុនៃបណ្តឹងសុំមោឃភាព

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ មានការកំណត់អំពីមូលហេតុដែលអាចនាំឱ្យមានការមោឃភាពនីតិវិធីដែលវាជាចំណុចពិសេសចំពោះអ្នកដែលមានសិទ្ធិប្តឹង ក្នុងការដាក់ពាក្យបណ្តឹងសុំមោឃភាពនីតិវិធី លើកយក

[6] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៥៦
[7] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៥៣

មកធ្វើជាសំអាងហេតុ ដើម្បីជាផលប្រយោជន៍ក្នុងការការពារខ្លួនចំពោះការរំលោភបំពានសិទ្ធិរបស់ពួកគេដ៏ធ្ងន់ធ្ងររបស់ពួកគេ។

ចំពោះការមិនគោរពវិធានដែលអាចនាំឱ្យមានមោឃភាព នឹងធ្វើការលើកឡើងនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេត និងដំណាក់កាលនៃការស៊ើបសួរ។ ដោយហេតុថាដំណាក់កាលទាំងពីរនេះ សង្កេតឃើញថាមានការមោឃភាពជាញឹកញាប់។

**២.១. មោឃភាពនីតិវិធីដោយសារការបំពានវិធានដែលច្បាប់បានកំណត់**

ការស៊ើបអង្កេត ធ្វើឡើងក្នុងគោលបំណងដើម្បីធ្វើការស្វែងរក ក៏ដូចជាប្រមូលនូវភស្តុតាងក្នុងការកំណត់អំពីបទល្មើស។ ចំពោះការស៊ើបអង្កេតត្រូវបានបែងចែកចេញជាពីរ ដែលក្នុងនោះរួមមាន៖ ការស៊ើបអង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋម។

**ក. ការបំពានវិធានដែលច្បាប់បានកំណត់ក្នុងដំណាក់កាលស៊ើបអង្កេត**

កិច្ចនីតិវិធីស៊ើបអង្កេតជាក់ស្តែង ដែលបានធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធំចំពោះបទល្មើសជាក់ស្តែងដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។

**កិច្ច និងនីតិវិធីដែលអាចនាំឱ្យមានមោឃភាពនៅក្នុងដំណាក់កាលស៊ើបអង្កេតរួមមាន៖**

- **កំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យ**

នៅក្នុងការស៊ើបអង្កេតចំពោះបទល្មើសជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌មានតួនាទីក្នុងការធ្វើកំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន។ ដោយហេតុថា កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យគឺជាភស្តុតាងបង្គោលដ៏សំខាន់ក្នុងការប្រគល់ជូនតុលាការដើម្បីធ្វើការពិនិត្យក្នុងការបន្តនីតិវិធី។ អាស្រ័យហេតុនេះ ក្នុងការស្រាវជ្រាវ និងការពិនិត្យរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និង ការពិនិត្យ បើពុំដូច្នេះទេនឹងនាំឱ្យមានការប្តឹងសុំមោឃភាពអំពីបុគ្គលដែលមានសិទ្ធិក្នុងការប្តឹង[8]។ ជាឧទាហរណ៍ក្នុងករណីដែលកំណត់ហេតុនៃការស្រាវជ្រាវ និងការពិនិត្យគឺពុំមានការចុះហត្ថលេខារបស់មន្ត្រីនគរបាល។

- **ការឆែកឆេរ**

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងនៅក្នុង ធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្ស និងកតិកាសសញ្ញាព្រមទាំងអនុសញ្ញាស្តីពីសិទ្ធិមនុស្សផ្សេងៗទៀត ដែលពាក់ព័ន្ធទៅនឹងសិទ្ធិមនុស្ស សិទ្ធិកុមារ និងនារី[9]។

[8] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ៩០ និងមាត្រា ១០៩

[9] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ជាក់ស្តែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក៏បានបញ្ញត្តិអំពី សិទ្ធិនៃការឆែកឆេរលំនៅឋានត្រូវបានកំណត់យ៉ាងជាក់លាក់អំពីការដែរត្រូវធ្វើឡើងដោយត្រឹមត្រូវទៅតាមបញ្ញត្តិដែលច្បាប់កំណត់។ មិនតែប៉ុណ្ណោះ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ក៏មានការចែងផងដែរចំពោះការឆែកឆេរលំនៅឋាននេះ។ ការបញ្ញត្តិបែបនេះគឺក្នុងគោលបំណងនៃការគោរពឱ្យបាននូវសិទ្ធិឯកជននៃការរស់នៅរបស់បុគ្គលគ្រប់រូប។ ជាមួយគ្នានេះដែរក៏មានការកំណត់អំពីលក្ខខណ្ឌដែលអាចធ្វើការឆែកឆេរបានផងដែរ ហើយប្រសិនបើក្នុងករណីដែលមានការឆែកឆេរដោយមានការបំពានទៅលើបញ្ញត្តិដែលបានកំណត់នោះនឹងនាំឱ្យមានការប្តឹងសុំមោឃភាព ចំពោះការឆែកឆេរនោះបាន។ អាស្រ័យហេតុនេះ មន្ត្រីនគរបាលយុត្តិធម៌ដែលធ្វើការឆែកឆេរ នៅក្នុងការប្រតិបត្តិការនោះត្រូវតែមានការគោរពទៅតាមបញ្ញត្តិដែលមានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ[10]។

**មូលហេតុដែលអាចនាំឱ្យមានការប្តឹងសុំមោឃភាពចំពោះការឆែកឆេររួមមាន៖**

- **ការឆែកឆេរដែលធ្វើឡើងដោយពុំមានការជូនដំណឹងទៅកាន់ព្រះរាជអាជ្ញា**

នៅក្នុងការឆែកឆេរនៅក្នុងបទល្មើសជាក់ស្តែង ត្រូវមានការជូនដំណឹង និងការសុំការអនុញ្ញាតជាបឋមអំពីថ្នាក់លើ( ព្រះរាជអាជ្ញា ) ជាមុនសិន ប្រសិនបើការឆែកឆេរនោះធ្វើឡើងដោយពុំមានការជូនដំណឹងនោះទេ អាចជាមូលហេតុដែលនាំឱ្យមានការប្តឹងសុំមោឃភាពបាន។ ការលើកឡើងបែបនេះគឺក្នុងគោលបំណងដើម្បី ការពារអំពីការចោទប្រកាន់របស់ម្ចាស់លំនៅឋាន ដែលមានការចោទប្រកាន់អំពីការរំលោភបំពានលំនៅឋានជាដើម។

- **ការឆែកឆេរដោយពុំមានការចូលរួមអំពីសាក្សី ក៏ដូចជាសមាសភាពដែលត្រូវចូលរួម**

ជាគោលការណ៍ការឆែកឆេរ ត្រូវមានវត្តមានរបស់អ្នកកាន់កាប់ទីកន្លែង ប៉ុន្តែក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែង អវត្តមាន នោះតម្រូវឱ្យមានការឆែកឆេរនៅចំពោះមុខសាក្សីចំនួនពីររូប[11]។ ចំពោះសាក្សី មិនអាចជាមន្ត្រីនគរបាលយុត្តិធម៌ ឬ មន្ត្រីកងរាជអាវុធហត្ថ ដែលបានចូលរួមនៅក្នុងការប្រតិបត្តិក្នុងការឆែកឆេរនោះទេ។

ដូចនេះក្នុងករណីដូចដែលបានលើកឡើងនេះ ប្រសិនបើការឆែកឆេរ ដោយពុំមានការចូលរួមអំពីសមាសភាពដែលត្រូវចូលរួមនោះទេ នឹងនាំឱ្យមានការប្តឹងសុំមោឃភាពបាន[12]។

- **ការឆែកឆេរដោយពុំគោរពទៅលើអំឡុងពេលនៃការឆែកឆេរ**

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អំពីការដែលត្រូវគោរពទៅលើអំឡុងពេលនៃការឆែកឆេរ ដែលក្នុងនោះរួមមាន៖

[10] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ៩១ និងមាត្រា ១០៩

[11] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ៩២ និងមាត្រា ១០៩

[12] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ៩១ និងមាត្រា ១០៩

ជាគោលការណ៍ការឆែកឆេរមិនអាចធ្វើការផ្តើមនៅមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក នឹងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចនោះទេ។ ដូចនេះប្រសិនបើការឆែកឆេរធ្វើឡើងនៅមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចនោះនាំឱ្យមានមោឃភាពចំពោះការឆែកឆេរនេះ ហើយភស្តុតាងដែលបានពីការឆែកឆេរនេះ ក៏ពុំអាចយកមកធ្វើជាភស្តុតាងនៅក្នុងសំណុំរឿងបាននោះដែរ[13]។

ប៉ុន្តែបើទោះបីជាគោលការណ៍នៃការឆែកឆេរត្រូវគោរពទៅតាមការកំណត់ដែលមិនអាចធ្វើមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាច ក៏ដោយច្បាប់មានការផ្តល់នូវករណីលើកលែងមួយចំនួនផងដែររួមមាន៖

- ករណីបទល្មើសជាក់ស្តែង
- ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង
- ករណីមានសំរែកឱ្យជួយពីក្នុងទីកន្លែង
- ករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សាធារណៈជន
- ក្នុងករណីដែលឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន[14]

មួយវិញទៀតចំពោះមូលហេតុដែលនាំឱ្យមានមោឃភាពចំពោះការឆែកឆេរក្នុង ការិយាល័យមេធាវី ក៏ដូចជាអាគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មាន ឬ សហគ្រាសសារព័ត៌មានសោតទស្សន៍ រួមមាន៖

- ការឆែកឆេរការិយាល័យមេធាវី ដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ គ្មានការចូលរួមពីចៅក្រម ព្រះរាជអាជ្ញា ព្រមទាំងបានធ្វើឡើងនៅចំពោះមុខប្រធានគណៈមេធាវី ឬ ប្រតិភូរបស់មេធាវី ឬ មេធាវីសាមី។
- ការឆែកឆេរអាគារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរឬ សហគ្រាសសារព័ត៌មានសោតទស្សន៍ ដោយពុំមានវត្តមានរបស់ចៅក្រមស៊ើបសួរ ឬ ព្រះរាជអាជ្ញាមួយរូប[15]។

❖ **ការបិទស្លាកបោះត្រាលើវត្ថុតាង**

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការបិទស្លាកលើវត្ថុដែលបានចាប់យកនោះ ដើម្បីធានាឱ្យបានថា វត្ថុដែលចាប់យកនោះមានភាពត្រឹមត្រូវ និងធានាបានអំពីការមិនផ្លាស់ប្តូរនូវវត្ថុតាងដែលបានចាប់យកនោះ[16]។ ដូចនេះក្នុងករណីដែលវត្ថុចាប់យកនោះពុំមានការបិទស្លាកនោះទេ អាចនាំឱ្យមានការមោឃភាពនៃវត្ថុចាប់យកនោះដោយសំអាងអំពីភាពមិនត្រឹមត្រូវនៃវត្ថុនោះ ដែលពុំអាចយកមកធ្វើជាភស្តុតាងបាន។

[13] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ៩១ និងមាត្រា ១០៩

[14] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ៩១ និងមាត្រា ១០៩

[15] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ៩១ និងមាត្រា ១០៩

[16] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ៩២ និងមាត្រា ១០៩

ជាមួយគ្នានេះ ដែរនៅពេលដែលមានការចាប់យក ក៏ដូចជាការបិទស្លាក ព្រមទាំងការបោះត្រារួចហើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីអំពីការចាប់យក ដោយមានការចុះហត្ថលេខា ឬ ផ្តិតស្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬ សាក្សីពីរនាក់។

- **កំណត់ហេតុស្តាប់ចម្លើយ**

ជាគោលការណ៍នៃការស្តាប់ចម្លើយនីមួយៗត្រូវមានកំណត់ហេតុ។ ចំពោះកំណត់ហេតុស្តីពីការស្តាប់ចម្លើយនេះ ត្រូវតែមានការស្រង់ដោយត្រឹមត្រូវ នូវសេចក្តីរាយការណ៍របស់បុគ្គលដែលផ្តល់ចម្លើយ។ មួយវិញទៀតទំព័រនីមួយៗនៃកំណត់ហេតុនេះត្រូវធ្វើការចុះហត្ថលេខា ឬ ផ្តិតស្រាមដៃដោយបុគ្គលដែលបានឆ្លើយ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការអានដោយសំឡេងខ្លាំងៗនូវខ្លឹមសារនៃកំណត់ហេតុ។

មួយវិញទៀត ប្រសិនបើបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬ ផ្តិតស្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ[17]។ ដូចនេះប្រសិនបើការធ្វើកំណត់ហេតុស្តាប់ចម្លើ ពុំមានការគោរពទៅតាមការកំណត់ដែលការអនុវត្តធ្វើឡើងដោយមានការបង្ខិតបង្ខំ ក៏ដូចជាការប្រើប្រាស់នូវអំពើហិង្សា ឬក៏មានភាពមិនប្រក្រតីណាមួយនោះ អាចនាំឱ្យក្លាយជាមូលហេតុនៃការប្តឹងសុំមោឃភាពផងដែរ។ ផ្អែកតាមសាលដីកា ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ បានសម្រេចទទួលបណ្តឹងសុំមោឃភាពដែលកម្មវត្ថុនៃបណ្តឹងនោះគឺ **កំណត់ហេតុស្តីពីការស្តាប់ចម្លើយ**[18] និង**កំណត់ហេតុស្រង់ចម្លើយ**[19]។ នៅក្នុងសាលដីកានេះបានបញ្ជាក់យ៉ាងច្បាស់ថា មូលហេតុនៃការប្តឹងសុំមោឃភាពនេះ គឺដោយសារតែការស្តាប់ចម្លើយដែលធ្វើឡើងទៅលើជនដែលជាអនីតិជននោះ ពុំមានការចូលរួមអំពីឪពុកម្តាយ ក៏ដូចជាមេធាវីនោះទេ ដែលសកម្មភាពទាំងនេះគឺធ្វើឡើងដោយផ្ទុយទៅនឹងមាត្រា ២១ និងមាត្រា ២២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ ដូចនេះសភាស៊ើបសួរពិនិត្យមើលឃើញថា ពាក្យបណ្តឹងសុំមោឃភាពដែលធ្វើឡើងតាមរយៈមេធាវីការពារសិទ្ធិរបស់ជនត្រូវចោទ ធ្វើឡើងត្រឹមត្រូវទៅតាមច្បាប់ ព្រមទាំងតាមរយៈការពិនិត្យលើកំណត់ហេតុនៃការស្តាប់ចម្លើយទាំងក្នុងដំណាក់កាលនគរបាលយុត្តិធម៌ និងដំណាក់កាលអយ្យការគឺពិតជាពុំមានវត្តមានរបស់មេធាវីការពារសិទ្ធិ ក៏ដូចជាឪពុកម្តាយរបស់អនីតជន ដែលជាជនត្រូវចោទនោះទេ។ ដូចនេះ សភាស៊ើបសួរ សម្រេចចេញសាលដីកាទទួលយកបណ្តឹងសុំមោឃភាព សម្រេចមោឃភាពលើកំណត់ហេតុស្តាប់ចម្លើយ ហើយសម្រេចដកកំណត់ហេតុនោះចេញពីសំណុំរឿង និងធ្វើការបង្វិលសំណុំរឿងនោះទៅចៅក្រមស៊ើបសួរវិញ។

---

[17]ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ៩៣ និងមាត្រា ១០៩

[18] កំណត់ហេតុស្តីពីការស្តាប់ចម្លើយ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ របស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង

[19] កំណត់ហេតុស្តីពីការស្រង់យកចម្លើយ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៩

- **បញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង**

បញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង គឺសំដៅដល់ការដែលមន្រ្តីនគរបាលយុត្តិធម៌ អាចធ្វើការកោះហៅបុគ្គលគ្រប់រូបដែលយល់ឃើញថាមានការពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទល្មើស ឬបុគ្គលដែលអាចធ្វើការផ្តល់ព័ត៌មានអំពីរឿងហេតុបាន។ ក្នុងការកោះហៅនេះត្រូវតែមានការយល់ព្រមពីព្រះរាជអាជ្ញា ដែលមានការចុះហត្ថលេខានៅក្នុងដីកាកោះហៅនោះ ព្រមទាំងមានការបោះត្រាជាដើម។

ដូច្នេះ ប្រសិនបើបញ្ជាឱ្យចូលខ្លួននេះពុំមានការយល់ព្រមអំពីព្រះរាជអាជ្ញាតាមរយៈការចុះហត្ថលេខា ក៏ដូចជាការបោះត្រាលើបទបញ្ជារនោះទេ អាចនាំឱ្យមានការធ្វើមោឃភាពបាន[20]។ បញ្ញត្តិនៃ មាត្រា ៩៣ កថាខណ្ឌទី២ ដល់ទី៥ (កំណត់ហេតុលើការស្តាប់ចម្លើយ) ត្រូវយកមកអនុវត្ត។

- **ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬ វិទ្យាសាស្រ្ត**

ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេ ឬ វិទ្យាសាស្រ្ត ត្រូវបានធ្វើឡើងដោយអ្នកជំនាញ ក្នុងគោលបំណងដើម្បីធ្វើការចូលរួមស្វែងរកនូវភស្តុតាងនៅក្នុងរឿងក្តី ព្រមទាំងដើម្បីធ្វើការបញ្ជាក់អំពីការពិតនៃការត្រួតពិនិត្យ។ ឧទាហរណ៍៖ ការពិនិត្យលើក្រយៅដៃដែលជាប់នៅលើវត្ថុចាប់យកដែលជាភស្តុតាងដ៏សំខាន់ក្នុងការបញ្ជាក់អំពីពិរុទ្ធភាពនៃជនណាមួយ។ អ្នកដែលមានសិទ្ធិក្នុងការធ្វើការត្រួតពិនិត្យខាងបច្ចេកទេស ឬវិទ្យាសាស្រ្ត គឺជាបុគ្គលដែលមានជំនាញ។ ក្នុងករណីដែលបុគ្គលនោះមិនទាន់ចុះឈ្មោះក្នុងបញ្ជីអ្នកជំនាញ ដូចមានចែងនៅក្នុងមាត្រា ១៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នោះទេមុនពេលនៃការត្រួតពិនិត្យ បុគ្គលនោះត្រូវធ្វើសម្បថទៅតាមជំនឿរបស់ខ្លួនថា នឹងជួយដោយភក្តីភាពដល់តុលាការ[21]។

ដូចនេះក្នុងករណីដែល ការត្រួតពិនិត្យនោះមិនបានធ្វើឡើងដោយអ្នកជំនាញទេ គេអាចលើកឡើងអំពីមោឃភាពចំពោះការត្រួតពិនិត្យនេះបាន។ ឧទាហរណ៍៖ ត្រូវធ្វើការត្រួតពិនិត្យក្រយៅដៃ ប៉ុន្តែអ្នកជំនាញដែលធ្វើការពិនិត្យបែជាអ្នកដែលមានជំនាញខាងចិត្តសាស្រ្តទៅវិញ ឬក៏សុខាភិបាលទៅវិញ។

- **ការឃាត់ខ្លួន**

ការឃាត់ខ្លួនធ្វើឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្រ្តីនគរបាលយុត្តិធម៌អាចឃាត់ខ្លួន បុគ្គលដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស។ មន្រ្តីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបានដែរ ប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ ៖

-បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន

-មានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។

[20] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ៩៥ និងមាត្រា ១០៩

[21] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ៩៥ និងមាត្រា ១០៩

មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលតម្រូវឱ្យមានការឃាត់ខ្លួននេះ។ ការឃាត់ខ្លួនមានថិរវេលា ៤៨ (សែសិបប្រាំបី) ម៉ោង។ ថិរវេលានេះត្រូវគិតរាប់ចាប់ពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ ចំពោះបទឧក្រិដ្ឋ កាលណាមានតម្រុយដែលបង្ហាញឱ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលត្រូវឃាត់ខ្លួនមន្ត្រីនគរបាលយុត្តិធម៌អាចពន្យារពេលឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ ដើម្បីឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ។ ការពន្យាពេលនេះត្រូវសុំទៅព្រះរាជអាជ្ញា ដែលត្រូវផ្ទៀងផ្ទាត់មើលមូលកភាព។ ការអនុញ្ញាតឱ្យពន្យាពេលឃាត់ខ្លួនដែលធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។ ការពន្យារពេលនេះគឺជាវិធានពិសេស។ ការពន្យាពេលនេះមិនអាចឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោងឡើយ ដោយមិនគិតពីថិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន។

ការពន្យារពេលមិនអាចត្រូវយល់ព្រមបានទេ ប្រសិនបើបុគ្គលដែលឃាត់ខ្លួនជាអនីតិជន ។ ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចត្រូវឃាត់ខ្លួនលើសពី ៣៦ ម៉ោងឡើយ។ ចំពោះ បទមជ្ឈឹម អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចត្រូវឃាត់ខ្លួនលើសពី ៤៨ ម៉ោងឡើយ។ ចំពោះបទឧក្រិដ្ឋ អនីតិជន ដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោងឡើយ។ ចំពោះ បទមជ្ឈឹមវិញ អនីតិជន ដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ។ ចំណែកឯ អនីតិជន ដែលមានអាយុក្រោម ១៤ ឆ្នាំ ពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ។[22]

ដូចនេះ ករណីដែលអាចធ្វើការ មោឃភាព ទៅលើការឃាត់ខ្លួនបានអាចជាការដែលៈ

- ហួសរយៈពេលនៃការឃាត់ខ្លួន
- ធ្វើការឃាត់ខ្លួនដោយពុំមានការជូនដំណឹងទៅកាន់ព្រះរាជអាជ្ញា
- ការពន្យាពេលនៃការឃាត់ខ្លួនដោយពុំមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីព្រះរាជអាជ្ញា
- ការមិនគោរពថិរវេលានៃការឃាត់ខ្លួនរបស់អនីតិជន ជាអាទិ៍។

❖ **កំណត់ហេតុស្តីពីការឃាត់ខ្លួន**

ការឃាត់ខ្លួន បុគ្គលណាម្នាក់មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការប្រាប់ពីមូលហេតុនៃការឃាត់ខ្លួនព្រមទាំងធ្វើការប្រាប់អំពីសិទ្ធិរបស់បុគ្គលនោះផងដែរ។ មួយវិញទៀតមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួន ដែលក្នុងនោះរួមមានការចុះសេចក្តីដូចតទៅៈ

[22]ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ៩៦ និងមាត្រា ១០៩

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យឃាត់ខ្លួន
- អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន
- មូលហេតុនៃការឃាត់ខ្លួន
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមឃាត់ខ្លួន
- ការឱ្យដំណឹងអំពីសិទ្ធិដែលបានបញ្ញត្តិនៃមាត្រា ៩៩ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន)
- ជាយថាហេតុឈ្មោះ អ្នកបកប្រែ។

ចំពោះកំណត់ហេតុស្តីពីការឃាត់ខ្លួនត្រូវចុះហត្ថលេខា ឬ ផ្តិតម្រាមដៃរបស់ជនឃាត់ខ្លួន ក្រោយពីបានអានកំណត់ហេតរួច ឬ បើសាមីខ្លួនមិនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុឱ្យស្តាប់។ ប្រសិនបើជននេះប្រកែកមិនព្រមចុះហត្ថលេខា ឬ ផ្តិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស។ កំណត់ហេតុត្រូវភ្ជាប់ជាមួយសំណុំរឿង។ ដូចនេះក្នុងករណីដែលមានការចុះនិទ្ទេសខ្វះ គឺនាំឲ្យមានមោឃភាព[23]។

- **ជំនួយរបស់មេធាវីក្នុងពេលឃាត់ខ្លួន**

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ថា ច្បាប់ហាមរងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។ ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ និងអាចធ្វើទៅកើតលុះត្រាតែការអនុវត្តត្រឹមត្រូវ តាមបញ្ញត្តិច្បាប់ ហើយជនគ្រប់រូបមានសិទ្ធិការពារខ្លួនពីការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ និងអាចធ្វើទៅកើត លុះត្រាតែការអនុវត្តត្រឹមត្រូវតាម បញ្ញត្តិច្បាប់។ ហើយជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ[24]។

ផ្អែកទៅលើរដ្ឋធម្មនុញ្ញ សិទ្ធិនៃការមានមេធាវីក្នុងអំឡុងពេលនៃការឃាត់ខ្លួន គឺជាវិធានមួយដ៏សំខាន់ក្នុងការធានាឱ្យបាននូវភាពត្រឹមត្រូវគោរពបានទៅតាមគោលការណ៍ស្មារតីរបស់ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាក៏ដូចជាសន្ធិសញ្ញាអន្តរជាតិដទៃទៀតដែលពាក់ព័ន្ធនឹងការការពារសិទ្ធិមនុស្ស។

ដូចនេះក្នុងករណីដែលពុំមានវត្តមានរបស់មេធាវីក្នុងអំឡុងពេលនៃការឃាត់ខ្លួននោះទេ គឺជាមូលហេតុដែលនាំឱ្យមានការមោឃភាពនីតិវិធីនៃការឃាត់ខ្លួននោះបាន[25]។ ចំពោះការដែលមេធាវីអាចធ្វើការពិនិត្យសំណុំរឿងបានលុះត្រាណាតែមេធាវីនោះ មានការដាក់ពាក្យស្នើសុំជាមុនសិន។

- **ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលនៃការឃាត់ខ្លួន**

ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌សុំឲ្យគ្រូពេទ្យមកពិនិត្យបុគ្គលដែលឃាត់ខ្លួនបានគ្រប់ពេលវេលាទៅតាមការដាក់ស្តែង។

[23] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា១០៨
[24] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
[25] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ៩៨ និងមាត្រា ១០៩

ប្រសិនបើការឃាត់ខ្លួនត្រូវបានធ្វើឡើងដោយស្ថានភាពសុខភាពរបស់បុគ្គលដែលត្រូវ ឃាត់ខ្លួនដោយពុំមានការត្រួតពិនិត្យពីគ្រូពេទ្យនោះ អាចនាំឱ្យមានការមោឃភាពនីតិវិធី។គ្រូពេទ្យពិនិត្យផ្ទៀងផ្ទាត់មើលថា តើស្ថានភាពនៃបុគ្គលនោះសមស្របនឹងការឃាត់ខ្លួនដែលឬទេ។ ប្រសិនបើគ្រូពេទ្យយល់ឃើញថា ស្ថានភាពនៃបុគ្គលនោះពុំសមស្របទៅនឹងការឃាត់ខ្លួននោះទេ មន្ត្រីនគរបាលយិត្តិធម៌រាយការណ៍ជាបន្ទាន់ដល់ព្រះរាជអាជ្ញា។ គ្រូពេទ្យចេញវិញ្ញាបនប័ត្របញ្ជាក់សុខភាពដែលត្រូវភ្ជាប់ជាមួយសំណុំរឿង ។ គ្រូពេទ្យចេញវិញ្ញាបនបត្រមន្ត្រីនគរបាលយុត្តិធម៌ចុះនិទ្ទេសនៅលើកំណត់ហេតុអំពីឈ្មោះគ្រូពេទ្យ ព្រមទាំងថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលធ្វើការពិនិត្យសុខភាព។ ព្រះរាជអាជ្ញាអាចចុះទៅកាន់ទីកន្លែង ដើម្បីផ្ទៀងផ្ទាត់លក្ខខណ្ឌនៃការឃាត់ខ្លួន[26]។

- **អនីតិជនដែលត្រូវឃាត់ខ្លួន**

កាលណាបុគ្គលដែលត្រូវឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុកម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬ ដល់អ្នកដែលទទួលភារកិច្ចលើអនីតិជននោះ។[27]

**លក្ខខណ្ឌនៃការឃាត់ខ្លួនបុគ្គលដែលជាអនីតិជនះ**

-ការឃាត់ខ្លួនបុគ្គលដែលជាអនីតិជនដែលមានអាយុពី ១៤ ឆ្នាំ និងក្រោម ១៦ ឆ្នាំ មិនអាចហួសពី ៣៦ ម៉ោង

-ចំពោះបទមជ្ឈឹម អនីតិជនអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោង

-ចំពោះបទឧក្រិដ្ឋ អនីតិជនអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោង

-ចំពោះបទមជ្ឈឹម អនីតិជនអាយុពី ១៦ ឆ្នាំ ដល់អាយុ ១៨ ឆ្នាំ មិនអាចត្រូវឃាត់ខ្លួនហួសរយៈពេល

- **ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍**

សិទ្ធិសេរីភាពប្រជាពលរដ្ឋត្រូវបានការពារ និងធានាយ៉ាងពេញទីដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយកំណត់អំពីការរក្សាសិទ្ធិមិនឱ្យមានការរំលោភបំពានលើអាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូគមនាគមន៍ និងតាមទូរស័ព្ទ ត្រូវបានធានា[28]។ ដូចនេះមន្ត្រីនគរបាលយុត្តិធម៌ពុំមានអំណាចបង្គាប់ឱ្យចាប់ និងថតសំឡេងការសន្ទនាតាមទូរស័ព្ទឡើយ មួយវិញទៀតក៏ពុំមានអំណាចក្នុងបង្គាប់ឱ្យចាប់ ថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ ជាអាទិ៍ សារតាមទូរសារ ឬ សារតាមរយៈអិនធើណែតផងដែរ[29]។

[26] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ៩៩ និងមាត្រា ១០៩

[27] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ១០០

[28] មាត្រា ៤០ កថាខណ្ឌទី៣ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

[29] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ១០៥ និងមាត្រា ១០៩

ក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស្ដាប់ ឬ ថតសំឡេងដើម្បីទុកជាភស្តុតាងដែលបានមកពីការស៊ើបអង្កេតតាមរយៈការលួចស្ដាប់ ឬលួចថតនោះ នឹងនាំឱ្យមានការប្ដឹងសុំមោឃភាពលើភស្តុតាងនោះដោយបុគ្គលដែលច្បាប់អនុញ្ញាតក្នុងការប្ដឹង។

- **ចិរវេលានៃការស៊ើបអង្កេតករណីជាក់ស្ដែង**

ចំពោះការស៊ើបអង្កេតជាក់ស្ដែងត្រូវបានកំណត់រយៈពេលរយៈយ៉ាងជាក់លាក់ ដោយការស៊ើបអង្កេតមិនត្រូវធ្វើឱ្យហួសពីរយៈពេល ប្រាំពីរថ្ងៃនោះទេ ដោយគិតចាប់ពីថ្ងៃដែលត្រូវបានប្រព្រឹត្តបទល្មើស។ មួយវិញទៀតចំពោះការស៊ើបអង្កេតនេះត្រូវធ្វើដោយជាប់គ្នាជានិច្ចនៅក្នុងចិរវេលានេះ។ ប្រសិនបើការស៊ើបអង្កេតមិនបានបញ្ចប់នៅក្នុងរយៈពេល ៧ថ្ងៃនោះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការសុំយោបល់ទៅកាន់ព្រះរាជអាជ្ញា[30]។ ចំពោះការសុំយោបល់នេះ អាចជាការដែលធ្វើការបញ្ជូនទៅកាន់អយ្យការ ឬក៏អាចជាការប្រើនូវវិធានការស៊ើបអង្កេតបឋម។ ដូចនេះក្នុងករណីដែលមានការហួសចិរវេលានៃការស៊ើបអង្កេតក្នុងករណីជាក់ស្ដែងហើយ តែក្នុងនាមជាមន្ត្រីនគរបាលយុត្តិធម៌ពុំមានការសុំយោបល់ទៅកាន់ព្រះរាជអាជ្ញា ដោយបន្តការស៊ើបអង្កេតតាមករណីជាក់ស្ដែងទៀត នោះជាមូលហេតុនៃការប្ដឹងសុំមោឃភាពនីតិវិធីនៃការស៊ើបអង្កេតនោះ។

- **និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ**

កំណត់ហេតុគឺជាសំអាងរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការទុកជាភស្តុតាងក្នុងការសម្រេចសេចក្ដីរបស់តុលាការ។ កំណត់ហេតុដែលត្រូវធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវមានចុះនិទ្ទេសមួយចំនួនដូចជាៈ

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌
- អង្គភាពរបស់មន្ត្រីនគរបាលយុត្តិធម៌នោះ
- កាលបរិច្ឆេទ

កំណត់ហេតុស្ដីពីការស្ដាប់ចម្លើយ ឬ ស្ដីពីការឃាត់ខ្លួន ត្រូវចុះអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ។ ចំពោះទំព័រនីមួយៗនៃកំណត់ហេតុត្រូវមានការចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌។

ចំពោះពាក្យឆូតលុប និងការយោងត្រូវមានការបញ្ជាក់យល់ព្រម ដោយមានការចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌នៅរឹមទំព័រ[31]។

ចំណុចសំខាន់ដែលមន្ត្រីនគរបាលយុត្តិធម៌ ត្រូវមានការប្រុងប្រយ័ត្ន គឺការចុះហត្ថលេខានៅគ្រប់ទំព័រនៃកំណត់ហេតុ ក៏ដូចជាការឆូត ឬយោងនៅក្នុងកំណត់ហេតុជាដើម ព្រោះប្រសិនជាមានការធ្វេសប្រហែស ក៏ដូចជាមិនបានយកចិត្តទុកដាក់ខ្ពស់នោះទេអាចនាំឱ្យមោឃភាពចំពោះកំណត់ហេតុនោះបាន។

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ១០៦ និងមាត្រា ១០៩

[31]ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ១០៨ និងមាត្រា ១០៩

ចំណែកឯនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតបឋម អាចដំណើរការបានដោយការផ្តួចផ្តើមពីមន្ត្រីនគរបាលយុត្តិធម៌ ឬ តាមពាក្យសុំរបស់ព្រះរាជអាជ្ញា ក្នុងករណីបទឧក្រិដ្ឋ មជ្ឈឹម ឬ លហុ។ ការស៊ើបអង្កេតបឋម ដំណើរការនៅក្នុងករណីបទឧក្រិដ្ឋ ឬមជ្ឈឹម មិនជាក់ស្តែង ឬ ក៏ក្នុងករណីដែលចិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែងបានកន្លងផុតទៅ[32]

ចំពោះអំណាច និងកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងការស៊ើបអង្កេតបឋម គឺមានភាពប្រហាក់ប្រហែលគ្នា និងអំណាច កាតព្វកិច្ច របស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងការស៊ើបអង្កេតជាក់ស្តែង ដោយគ្រាន់តែមានបញ្ញត្តិយោងមានភាពខុសគ្នា ហើយមានការកម្រិតមិនសូវទូលំទូលាយដូចទៅនឹងអំណាចនៅក្នុងបទល្មើសជាក់ស្តែងនោះទេ។

វិធាននៃការស៊ើបអង្កេតបឋម មានចែងចាប់ពីមាត្រា ១១១ ដល់មាត្រា ១១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះចំណុចដែលមានភាពខុសគ្នា អំពីការស៊ើបអង្កេតករណីជាក់ស្តែង និងស៊ើបអង្កេតករណីបឋម គឺទាក់ទងទៅនឹងការ ឆែកឆេរ ដែលមានចែងនៅក្នុងមាត្រា ១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ដូចនេះនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតបឋម ចំណុចដែលអាចនាំឲ្យមានការប្តឹងសុំអំពីបុគ្គលដែលមានសិទ្ធិប្តឹងរួមមាន ការឃាត់ខ្លួន (មាត្រា ៩៦), កំណត់ហេតុស្តីពីការឃាត់ខ្លួន មាត្រា ៩៧, អនីតិជនដែលត្រូវឃាត់ខ្លួន មាត្រា ១០០, ការហាមឃាត់មោឲ្យស្តាប់ដោយឯកឯង ជាអាទិ៍ មាត្រា ១០៥, ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា មាត្រា ១០៧, ការឆែកឆេរ មាត្រា ១១៣ និងការបញ្ជារឲ្យចូលខ្លួន ការស៊ើបអង្កេតបឋម មាត្រា ១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ខ. ការបំពានវិធានដែលច្បាប់បានកំណត់នៅក្នុងដំណាក់កាលស៊ើបសួរ**

ការស៊ើបសួរ ត្រូវបានធ្វើឡើងដោយចៅក្រមស៊ើបសួរ ព្រមទាំងបុគ្គលមួយចំនួនទៀតដែលរួមមាន មន្ត្រីនគរបាលយុត្តិធម៌ កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ ព្រមទាំងអ្នកដែលមានសមត្ថកិច្ចដទៃទៀត ព្រមទាំងចូលរួមដោយក្រឡាបញ្ជីដើម្បីឱ្យការស៊ើបសួរនោះជានាឱ្យបាននូវភាពត្រឹមត្រូវ ក៏ដូចជាមានភាពងាយស្រួលក្នុងការកត់ត្រាក្នុងអំឡុងពេលនៃការស៊ើបសួរនោះ។

ចៅក្រមស៊ើបសួរ មានតួនាទីក្នុងការស៊ើបសួរ ទាំងការដោះបន្ទុក និងការដាក់បន្ទុក។ ចំពោះការបើកការស៊ើបសួរ ចៅក្រមធ្វើឡើងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

នៅក្នុងដំណាក់កាលនៃការស៊ើបសួរច្បាប់បានកំណត់លើបញ្ញត្តិមួយចំនួនដែលអាចធ្វើការប្តឹងសុំមោឃភាពនីតិវិធីដែលបានធ្វើទៅហើយនោះ ដែលក្នុងនោះរួមមានៈ

[32] សៀវភៅ នីតិវិធីព្រហ្មទណ្ឌ លោកសាស្ត្រចារ្យ រុណ ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១៧ ២០១៨ ទំព័រ ២៥

- **ការបើកការស៊ើបសួរ**

ការបើកការស៊ើបសួរ ត្រូវតែធ្វើជាដយខានមិនបានចំពោះបទឧក្រិដ្ឋ[33]។ ក្នុងស្មារតីនៃការកំណត់បែបនេះ ដោយហេតុថា បទឧក្រិដ្ឋជាបទល្មើសដែលមានភាពធ្ងន់ធ្ងរ ដែលអាចធ្វើឱ្យមានផលប៉ះពាល់ដល់សិទ្ធិសេរីភាព របស់បុគ្គលក្នុងករណីដែលមានការប្រកាសទោស ដោយពុំឆ្លងកាត់ការស៊ើបសួរ។ ចំពោះ បទមជ្ឈឹម អាចធ្វើការ ស៊ើបសួរ ក៏បានមិនធ្វើការស៊ើបសួរក៏បាន[34]។

ក្នុងករណីដែល បទឧក្រិដ្ឋពុំមានការបើកការស៊ើបសួរ នោះនឹងនាំឱ្យក្លាយជាមូលហេតុនៃការប្តឹងសុំមោឃភាពលើកិច្ចដែលបានបំពេញនោះ។

- **សមត្ថកិច្ចដែនដី**

សមត្ថកិច្ចដែលចៅក្រមស៊ើបសួរ មានក្នុងការបើកការស៊ើបសួរត្រូវបានកំណត់យ៉ាងជាក់លាក់នៅក្នុង បញ្ញត្តនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណីដែលមានវិវាទសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ នោះសភាស៊ើបសួរ ជាអ្នកមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទនេះ ហើយចំពោះសេចក្តីសម្រេចរបស់សភាស៊ើបសួរ គឺជាសេចក្តី សម្រេចបិទផ្លូវតវ៉ា។

**ចំពោះសមត្ថកិច្ចដែលចៅក្រមស៊ើបសួរអាចធ្វើការបើកការស៊ើបសួរបានរួមៈ**

- ចៅក្រមស៊ើបសួរនាទីកន្លែងនៃបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬ ទីសំណាក់របស់បុគ្គលដែលសង្ស័យថាបាន ប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែកសង្ស័យថាបានប្រព្រឹត្តបទល្មើស

ដូចនេះក្នុងករណីដែលមានការអនុវត្តខុសពីសមត្ថកិច្ចដែលបានកំណត់នេះ នឹងនាំឱ្យមានការមោឃភាព ទៅលើកិច្ចដែលចៅក្រមស៊ើបសួរនោះបានបំពេញ[35]។

- **ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ**

ចៅក្រមស៊ើបសួរ ធ្វើការបើកការស៊ើបសួរ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាង អយ្យការ ដែលអនុលោមតាមមាត្រា ៤៤ (ការបើកការស៊ើបសួរ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចៅក្រមស៊ើបសួរ មិនអាចធ្វើការបើកការស៊ើបសួរណាមួយ ដោយពុំមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ របស់ព្រះរាជអាជ្ញា នោះទេ ប៉ុន្តែងមានការណីលើកលែងនៅពេលដែលចៅក្រមស៊ើបសួរបានទទួលបណ្តឹងដោយមានការតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី[36]។

[33] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ១២២

[34] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ១២២

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ១២៣ និងមាត្រា ១១៧

[36] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ១២៤

**ករណីដែលអាចជាមូលហេតុនៃមោឃភាពរួមមាន ៖**

- ចៅក្រមស៊ើបសួរធ្វើការបើកការស៊ើបសួរដោយពុំមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា
- ចៅក្រមស៊ើបសួរពុំមានការជូនដំណឹងអំពីការទទួលបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចមានចែងក្នុងមាត្រា ១៣៨ (ការបញ្ជូនបណ្តឹងទៅកាន់ព្រះរាជអាជ្ញា) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាអាទិ៍។
- និទ្ទេសដែលត្រូវធ្វើការចុះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវមាន៖
  - សេចក្តីសង្ខេបអង្គហេតុ
  - ការកំណត់ឈ្មោះបទល្មើស
  - ការបង្ហាញអត្ថបទច្បាប់ដែលពាក់ព័ន្ធ
  - ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន ហើយត្រូវមានការចុះកាលបរិច្ឆេទ និងចុះហត្ថលេខា[37]។

ជារួមមកក្នុងករណីដែលមានការរំលោភបំពានដូចដែលមានការលើកឡើងនៅក្នុងចំណុចខាងលើនេះ នឹងនាំឱ្យមានការប្តឹងសុំមោឃភាពនីតិវិធីដែលបានធ្វើឡើងនោះ។

❖ **វិសាលភាពនៃការប្តឹង**

នៅក្នុងការទទួលបណ្តឹងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរអាចធ្វើការបើកការស៊ើបសួរតែទៅលើអង្គហេតុដែលបានប្តឹងមកនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ។ ក្នុងករណីដែលការបើកការស៊ើបសួរ ដោយមានលេចចេញនូវបទល្មើសថ្មី នោះចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានទៅកាន់ព្រះរាជអាជ្ញា។ ដូចនេះព្រះរាជអាជ្ញា អាចធ្វើការប្តឹងសុំឱ្យចៅក្រមស៊ើបសួរ ធ្វើការបើកការស៊ើបសួរលើអង្គហេតុថ្មីនោះបាន។ ការបើកការស៊ើបសួរលើអង្គហេតុថ្មីនេះត្រូវតែមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ប្រសិនបើគ្មាននោះចៅក្រមស៊ើបសួរ ពុំមានអំណាចក្នុងការបើកការស៊ើបសួរនោះទេ។ ប៉ុន្តែក្នុងករណីដែលអង្គហេតុថ្មីនោះគឺជាស្ថានទម្ងន់ទោសទៅលើអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺពុំចាំបាច់មានដីកាសន្និបញ្ជូនរឿងឱ្យស៊ើបសួរនោះទេ[38]។

ឧទាហរណ៍៖ ក បានប្រព្រឹត្តអំពើហិង្សាលើជនរងគ្រោះតែជននោះមិនទាន់ស្លាប់នោះទេ ប៉ុន្តែនៅពេលដែលធ្វើការចោទប្រកាន់រួចហើយជនរងគ្រោះក៏បានស្លាប់បាត់បង់ជីវិត។ សរុបជារួមមក ចៅក្រមស៊ើបសួរមានអំណាចក្នុងការបើកការស៊ើបសួរ តែនៅពេលដែលមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ បើសិនការបើកការស៊ើបសួរដោយពុំមានដីកាសន្និដ្ឋាបញ្ជូនរឿងឱ្យស៊ើបសួរនោះទេអាច ជាមូលហេតុនៃការមោឃភាពនីតិវិធីនៃការស៊ើបសួរនោះបាន។

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ៤៤ និងមាត្រា ២៥២

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ១២៥ និងមាត្រា ២៥២

❖ **ជំនួយរបស់ក្រឡាបញ្ជី**

ក្រឡាបញ្ជីមានមុខងារយ៉ាងសំខាន់ ក្នុងការជួយដល់ចៅក្រមស៊ើបសួរ ឱ្យបំពេញកិច្ចស៊ើបសួរបានសម្រេចប្រកបដោយប្រសិទ្ធភាព។ ជាក់ស្តែងចំពោះការសួរចម្លើយរបស់ចៅក្រមស៊ើបសួរ គឺត្រូវមានការធ្វើកំណត់ហេតុសួរចម្លើយ ហើយកំណត់ហេតុទាំងនេះ គឺសុទ្ធសឹងតែជាភស្តុតាងដ៏មានសារៈសំខាន់ក្នុងការថ្លឹងថ្លែងរបស់តុលាការ ព្រោះតុលាការសំអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនតែទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឬដែលត្រូវបានលើកឡើងនៅពេលសវនាការប៉ុណ្ណោះ[39]។ តួនាទីក្រឡាបញ្ជីនៃចៅក្រមស៊ើបសួរ មានភាពសំខាន់ក្នុងការធ្វើកំណត់ហេតុស្តាប់ចម្លើយ កំណត់ហេតុសួរចម្លើយនៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ និងកំណត់ហេតុសវនាការ នៅក្នុដំណាក់កាលជំនុំជម្រះ ជាដើម។

ដូចនេះប្រសិនបើក្នុងដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរបំពេញកិច្ចដោយពុំមានការចូលរួមរបស់ក្រឡាបញ្ជី នោះនឹងនាំឱ្យមានមោឃភាពនីតិវិធី ព្រោះជាក់ស្តែងកំណត់ហេតុត្រូវមានការចុះហត្ថលេខារបស់ក្រឡាបញ្ជី។ ចំណុចនេះបង្ហាញអំពីការធានាបាននូវយុត្តិធម៌ក្នុងការអនុវត្តនីតិវិធីរបស់ចៅក្រមស៊ើបសួរ ដូចនេះប្រសិនបើមានហេតុដូច្នេះកើតឡើងនឹងនាំឱ្យមានការប្តឹងសុំមោឃភាព។ មូលហេតុដែលនាំឱ្យមានការប្តឹងសុំមោឃភាព ក្នុងករណីដែលក្រឡាបញ្ជី បានធ្វើកិច្ចដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរផងដែរ។

**២.២. មោឃភាពនៃនីតិវិធីដោយសារការបំពានធ្ងន់ធ្ងរដល់សិទ្ធិនៃការការពារខ្លួន**

ការមោឃភាពដែលកើតចេញពីការដែលមានការបំពានកិច្ចដែលមិនបានកំណត់ដោយច្បាប់ មានន័យថាក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ពុំបានកំណត់ថាបើមិនបានគោរពតាមត្រូវតែមានការមោឃភាពជាដាច់ខាតនោះទេ។ កិច្ច នោះសំដៅទៅលើកិច្ចទាំងឡាយណាដែលប៉ះពាល់ធ្ងន់ធ្ងរបំផុតដល់សិទ្ធិនៃការការពារខ្លួន។

ការលើកឡើងបែបនេះ គឺផ្អែកទៅលើ មាត្រា ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កថាខណ្ឌចុងក្រោយចែងថានាំឱ្យមានមោឃភាពផងដែល កាលណាការបំពានវិធាន ឬ ទម្រង់ការសំខាន់ណាណាមួយដែលចែងដោយក្រមនេះ ឬ បទបញ្ញត្តិទាំងឡាយស្តីពីនីតិវិធីព្រហ្មទណ្ឌធ្វើឱ្យប៉ះពាល់ប្រយោជន៍របស់ភាគីដែលទទួលរងការរំលោភបំពាននេះ។ វិធាន ឬ ទម្រង់ការដែលមានលក្ខណៈសំខាន់នោះ មានជាអាទិ៍ គឺវិធាន ឬ ទម្រង់ការដែលមានបំណងធានាការគោរពសិទ្ធិនៃការការពារខ្លួន[40]។

ច្បាប់បានកំណត់ទៀតថា តើវិធានដូចម្តេចដែលហៅថា វិធានការ ឬ ទម្រង់ដែលមានលក្ខណៈសំខាន់។ វិធានការ ឬ ទម្រង់ការដែលមានលក្ខណៈសំខាន់ សំដៅដល់វិធានការ ឬ ទម្រង់ការដែលមានលក្ខណៈការការពារសិទ្ធិនៃការការពារខ្លួន។

---

[39] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ៣២១

[40] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៥៣

ដូចនេះ បញ្ញត្តិមួយចំនួននៃក្រមនីតិវិធីព្រហ្មទណ្ឌ ពុំមានការកំណត់ថា ប្រសិនបើមិនបានគោរពតាមត្រូវតែមានការមោឃភាពនោះទេ។ ប៉ុន្តែ ផ្ទុយទៅវិញ ការបំពាននោះធ្វើឱ្យមានផលប៉ះពាល់ដល់សិទ្ធិនៃការការពារខ្លួន ឬ ប៉ះពាល់ដល់ប្រយោជន៍ របស់ភាគី។

ជាឧទាហរណ៍ ៖ ការស្តាប់ចម្លើយរបស់សាក្សីជាដើម[41]។ ជាក់ស្តែង ជាទូទៅចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយសាក្សីបាន។ ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា បើសាក្សីនោះមានតម្រុយពិរុទ្ធភាព ដែលបញ្ជាក់ថាបានចូលរួមប្រព្រឹត្តបទល្មើស នោះចៅក្រមស៊ើបសួរមិនអាចស្តាប់ចម្លើយជននោះក្នុងនាមជាសាក្សីបាននោះទេ។ ចៅក្រមស៊ើបសួរ ត្រូវដាក់ជននោះឱ្យនៅក្រោមការពិនិត្យ។ នៅក្នុងដំណាក់កាលស៊ើបសួរនេះ ដើម្បីបំលែងជននោះពីសាក្សី ទៅជាជនជាប់ចោទ ដើម្បីឱ្យជននោះអាចប្រើប្រាស់សិទ្ធិការពារខ្លួនក្នុងនាមជាភាគី។ នៅក្នុងករណីនេះប្រសិនបើចៅក្រមស៊ើបសួរ។ ដូចនេះ ប្រសិនបើចៅក្រមស៊ើបសួរ ចង់ស្តាប់ចម្លើយជនប្រភេទនេះ ត្រូវធ្វើការបំលែងឋានៈនៃជននេះជាមុនសិន[42]។

[41] ប្រសាសន៍ របស់ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងកិច្ចសម្ភាសន៍ ការផ្សព្វផ្សាយក្រមនីតិវិធីព្រហ្មទណ្ឌ

[42] ប្រសាសន៍ ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធំ ក្នុងកិច្ចសម្ភាស ស្តីពីការផ្សព្វផ្សាយច្បាប់ក្រមនីតិវិធីព្រហ្មទណ្ឌ

# ជំពូកទី២

# នីតិវិធីសម្រេចលើបណ្តឹងសុំមោឃភាព

# ជំពូកទី២
# នីតិវិធីសម្រេចលើបណ្តឹងសុំមោឃភាព

នីតិវិធីមោឃភាព គឺសំដៅទៅលើដំណើរការ ក៏ដូចជារបៀបរបបនៃការចាត់ការបណ្តឹងសុំមោឃភាព ដែលគិតចាប់ពីពេលនៃការទទួលបានពាក្យបណ្តឹងសុំមោឃភាពរហូតដល់ការការសម្រេចសេចក្តី លើពាក្យបណ្តឹងនោះ។ ចំពោះនីតិវិធីនេះ ត្រូវបានបែងចែកចេញជាបីដំណាក់កាលក្នុងការបកស្រាយឲ្យមានភាពងាយស្រួលក្នុងការស្វែងយល់ ដែលក្នុងនោះរួមមាន ចំណាត់ការមុនកិច្ចពិភាក្សាដេញដោល ចំណាត់ការនាពេលកិច្ចពិភាក្សាដេញដោល និងចំណាត់ការក្រោយកិច្ចពិភាក្សាដេញដោល។

## កថាខណ្ឌទី១៖ ចំណាត់ការមុនកិច្ចពិភាក្សាដេញដោល

### ១.១. ការដាក់ពាក្យបណ្តឹង និងការប្តឹងទៅសភាស៊ើបសួរ

ពាក្យបណ្តឹងសុំមោឃភាពត្រូវធ្វើជាលាយលក្ខណ៍អក្សរ មានកំណត់អំពីកិច្ចនីតិវិធីដែលប្តឹងសុំមោឃភាព ត្រូវមានសំអាងហេតុ និងមូលកភាពជាក់ស្តែង ព្រមទាំងកម្មវត្ថុនៃការប្តឹងសុំមោឃភាពនោះមិនមែនជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នោះទេ។ ការលើកឡើងបែបនេះ ដោយផ្អែកលើមាត្រា ២៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានលើកឡើងអំពី ភាពដែលមិនអាចទទួលយកបាននៃពាក្យបណ្តឹងសុំមោឃភាព ប្រសិនបើពាក្យបណ្តឹងនោះពុំបានគោរពទៅតាមបញ្ញត្តនៃមាត្រានេះ ឬមានការផ្ទុយគ្នាពីមាត្រានេះ នោះមានន័យថា ពាក្យបណ្តឹងសុំមោឃភាពនោះមិនអាចទទួលយកបាននោះទេ[43]។

ចំពោះពាក្យបណ្តឹងសុំមោឃភាព ភាគច្រើនត្រូវបានធ្វើឡើងតាមរយៈមេធាវីការពារសិទ្ធិរបស់ជនត្រូវចោទ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាដើម។ ដូចនេះហើយ ពាក្យបណ្តឹងមោឃភាពមួយចំនួន មានភាពត្រឹមត្រូវ និងគោរពបានទៅតាមការកំណត់របស់ច្បាប់ ប៉ុន្តែបើទោះបីជាយ៉ាងណាក៏ដោយ ក៏នៅមានពាក្យបណ្តឹងមួយចំនួនទៀតត្រូវបាន សភាស៊ើបសួរ បដិសេធមិនទទួល ព្រោះតែពាក្យបណ្តឹងទាំងនោះ មិនមានមូលកភាពយ៉ាងជាក់ស្តែង[44]។

- **ការប្តឹងទៅកាន់សភាស៊ើបសួរ**

ការដាក់ពាក្យបណ្តឹងសុំមោឃភាព ត្រូវបានដាក់នៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ ដោយបុគ្គលដែលមានសិទ្ធិក្នុងការប្តឹងសុំមោឃភាព ដែលក្នុងនោះរួមមាន ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជាដើម។

[43] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៧៩

[44] ឧបសម្ព័ន្ធទី៣ ពាក្យបណ្តឹងសុំមោឃភាព

ដូចនេះក្នុងករណីដែលបុគ្គលមានសិទ្ធិប្តឹង មានបំណងប្តឹងបុគ្គលនោះត្រូវគោរពតាមការបញ្ញត្តនៃច្បាប់៖ ក្នុងករណីដែល ចៅក្រមស៊ើបសួរ យល់ឃើញថា លិខិតណាមួយដែលមានមោឃភាព ចៅក្រមស៊ើបសួរនេះ ប្តឹងទៅសភាស៊ើបសួរ តាមរយៈដីកាដោយមានសំអាងហេតុ និងជូនព័ត៌មានដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

ក្នុងករណីដែល ព្រះរាជអាជ្ញា យល់ឃើញថា លិខិតណាមួយដែលមានមោឃភាព ព្រះរាជអាជ្ញាធ្វើពាក្យសុំ ដោយមានសំអាងហេតុ បញ្ជូនទៅកាន់សភាស៊ើបសួរ និងជូនដំណឹងដល់ចៅក្រមស៊ើបសួរ។

ក្នុងករណីដែល ជនត្រូវចោទ ឬ ដើមបណ្តឹង យល់ឃើញថា លិខិតណាមួយដែលមានមោឃភាព សាមីជន អាចធ្វើពាក្យសុំដោយមានសំអាងហេតុ ជូនទៅសភាស៊ើបសួរ និងជូនដំណឹងទៅដល់ចៅក្រមស៊ើបសួរ។ ពាក្យសុំនេះអាចធ្វើបានតាមរយៈមេធាវីរបស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។[45]

**១.២. ការបញ្ជូនសំណុំរឿង**

ពាក្យសុំប្តឹងសុំមោឃភាព ត្រូវចុះបញ្ជីនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ[46]។ ក្រោយពីមានការចុះលេខ ក៏ដូចជាការចុះនៅក្នុងសៀវភៅនៃសំណុំរឿងរួចមក ក្រឡាបញ្ជីនៃប្រធានសភាស៊ើបសួរ នឹងធ្វើ **លិខិតសំណើរបញ្ជូនសំណុំរឿង**[47] ទៅកាន់ចៅក្រមស៊ើបសួរដែលកាន់សំណុំរឿងនោះ។ នៅក្នុងសំណើរបញ្ជូនសំណុំរឿង មានការចុះហត្ថលេខាបោះត្រាដោយប្រធានសភាស៊ើបសួរ និងក្រឡាបញ្ជី។ ជាមួយគ្នានេះផងដែរ ការបញ្ជូនសំណើរបញ្ជូនសំណុំរឿងនេះ ក៏ត្រូវបញ្ជូនអមដោយ **ដីកាបញ្ជូន**[48] ដែលត្រូវផ្ញើជូនលោកប្រធានសាលាដំបូង ដែលក្នុងនោះរួមមាន បញ្ជីរាយនាមលិខិត និងចំនួន នៃសំណុំរឿងដែលត្រូវបញ្ជូនមកសាលាឧទ្ធរណ៍។

ក្រោយពីបានទទួលលិខិតដែលបានបញ្ជូនចេញពីសាលាឧទ្ធរណ៍រួចហើយ សាលាដំបូងនោះនឹងធ្វើការបញ្ជូនសំណុំរឿងមកដោយមានភ្ជាប់ជាមួយនូវ **ដីកាបញ្ជូន**[49] ដែលមានការចុះហត្ថលេខារបស់ប្រធានលេខាធិការដ្ឋានរដ្ឋបាល ដើម្បីធ្វើការចាត់ការនីតិវិធីបន្ត។

គួរបញ្ជាក់ផងដែរ ចំពោះសំណុំរឿងដែលត្រូវបានបញ្ជូនមកកាន់សាលាឧទ្ធរណ៍ គឺជាសំណុំរឿងបង្ការទុក ដែលជាសំណុំរឿងដែលត្រូវបានចម្លងទាំងមូល។ ចំណែកឯសំណុំរឿងដើមត្រូវរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃតុលាការជាន់ដំបូងដដែល។

[45] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៥៣

[46] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៥៣ កថាខណ្ឌ ៥ វាយក្យខណ្ឌទី២

[47] ឧបសម្ព័ន្ធទី៤ សំណើរបញ្ជូនសំណុំរឿង

[48] ឧបសម្ព័ន្ធទី៥ ដីកាបញ្ជូនទៅកាន់ប្រធានសាលាដំបូង

[49] ឧបសម្ព័ន្ធទី៦ ដីកាបញ្ជូនសំណុំរឿង

### ១.៣. ការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះ

នៅពេលដែលសំណុំរឿងត្រូវបានបញ្ជូនមកដល់ការិយាល័យរដ្ឋបាលសភាស៊ើបសួរ ដោយមានការចុះលេខ ក៏ដូចជាការចុះនៅក្នុង **សៀវភៅទទួលសំណុំរឿងសភាស៊ើបសួរ**[50] ព្រមទាំងមានការពិនិត្យផ្ទៀងផ្ទាត់ និងរៀបចំនូវចំនួនសន្លឹកឯកសារឱ្យមានភាពត្រូវត្រឹមទៅតាមលំដាប់លំដោយដើម្បីមានភាពងាយស្រួលក្នុងការពិនិត្យ ។

ដូច្នេះបន្ទាប់ពីធ្វើការពិនិត្យ និងរៀបចំរួចមកសំណុំរឿងនឹងត្រូវធ្វើការបញ្ជូនទៅកាន់ប្រធានសភាស៊ើបសួរភ្លាម ដោយហេតុថាសំណុំរឿងស៊ើបសួរទាំងអស់ត្រូវឆ្លងកាត់ប្រធានសភាស៊ើបសួរ ដើម្បីធ្វើការបែងចែកទៅតាមចៅក្រមម្នាក់តាមរយៈ **ដីកាចាត់តាំង**[51] ដែលជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ ទទួលបន្ទុកលើសំណុំរឿងនោះ។ នៅពេលដែលមានការចាត់តាំងរួចរាល់ហើយនោះ សំណុំរឿងនឹងត្រូវបញ្ជូនមកកាន់អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ ដើម្បីធ្វើការបញ្ជូនបន្តទៅកាន់ចៅក្រមដែលទទួលបន្ទុកសំណុំរឿងចុះហត្ថលេខាទទួលបន្តនីតិវិធី។

### ១.៤. ការជូនដំណឹងអំពីកិច្ចពិភាក្សាដេញដោល

ប្រធានសភាស៊ើបសួរពិនិត្យផ្ទៀងផ្ទាត់មើលថា តើសំណុំរឿងមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបានឬទេ រួចហើយកំណត់កាលបរិច្ឆេទបើកសវនាការ។ ប្រធានសភាស៊ើបសួរជូនដំណឹងដោយផ្ទាល់មាត់អំពីកាលបរិច្ឆេទនៃការបើកសវនាការ ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជូនដំណឹង អំពីកាលបរិច្ឆេទនៃសវនាការដលល់ភាគី និងមេធាវី។

ការជូនដំណឹងដល់ជនត្រូវចោទដែលត្រូវបានឃុំខ្លួន ត្រូវធ្វើតាមរយៈ ការជូនដំណឹងដោយផ្ទាល់មាត់ ឬតាមរយៈប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។

ចំណែកឯការជូនដំណឹងដល់ជនត្រូវចោទនៅក្រៅឃុំ ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីត្រូវធ្វើដូចតទៅគឺ ដោយផ្ទាល់មាត់ តាមផ្លូវរដ្ឋបាល និងតាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុហត្ថ។

កាលណាការជូនដំណឹងធ្វើដោយផ្ទាល់មាត់ ក្រឡាបញ្ជីចុះនិទ្ទេសអំពីកាលបរិច្ឆេទនៃការជូនដំណឹងនៅរឹមទំព័រនៃដីកា។ ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬមេធាវីត្រូវចុះហត្ថលេខារបស់ខ្លួន។ ក្នុងករណីដទៃទៀត ការជូនដំណឹងត្រូវធ្វើដោយការប្រគល់សេចក្តីចម្លងដីកាដោយមានចំណារទទួល[52]។ នៅក្នុងការអនុវត្តជាក់ស្តែង បន្ទាប់ពីមានការចាត់តាំងក្រុមប្រឹក្សារួចរាល់ ហើយក្រឡាបញ្ជីនៃចៅក្រមទទួលបន្ទុកសំណុំរឿង ត្រូវធ្វើការចុះ កាលបរិច្ឆេទនៃកិច្ចពិភាក្សាដេញដោលអោយបានឆាប់រហ័សនៅក្នុងបញ្ជីជំនុំជម្រះ នៅការិយាល័យរដ្ឋបាល ដែលក្នុងនោះរួមមានការបញ្ជាក់អំពីឈ្មោះចៅក្រម និងក្រឡាបញ្ជី។

[50] ឧបសម្ព័ន្ធទី៧ សៀវភៅទទួលសំណុំរឿងសភាស៊ើបសួរ

[51] ឧបសម្ព័ន្ធទី៨ ដីកាចាត់តាំង ក្រុមប្រឹក្សាជំនុំជម្រះ

[52] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៥៨

បន្ទាប់ពីមានការចុះកាលបរិច្ឆេទរួចរាល់ហើយនោះ ប្រធានក្រុមប្រឹក្សាជំនុំជម្រះនឹងធ្វើ **សំណើរចាត់តាំងតំណាងមហាអយ្យការចូលរួមសវនាការ**[53] ទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ចំពោះសំណើរចាត់តាំងតំណាងមហាអយ្យការចូលរួមសវនាការនេះរួមមានការបញ្ជាក់អំពី កាលបរិច្ឆេទនៃសវនាការ ពេលវេលាបន្ទប់សវនាការ និងអត្តសញ្ញាណនៃរឿងក្តីដែលត្រូវជំនុំជម្រះ។

ដូច្នេះ ក្រោយពេលមានការចាត់តាំងតំណាងមហាអយ្យការរួចរាល់មក ក្នុងនាមជាក្រឡាបញ្ជីនៃចៅក្រមទទួលបន្ទុកសំណុំរឿង ធ្វើការព្រាងដីកា ក៏ដូចជាលិខិតមួយចំនួនដែលត្រូវប្រើក្នុងការជូនដំណឹង ដាក់ជូនតំណាងមហាអយ្យការធ្វើការចុះហត្ថលេខា និងធ្វើការកោះហៅបុគ្គលដែលពាក់ព័ន្ធនឹង សំណុំរឿងឱ្យចូលរួមសវនាការ។ ចំពោះជនត្រូវចោទដែលនៅក្រៅឃុំត្រូវបានកោះហៅឱ្យចូលរួមក្នុងសវនាការតាមរយៈ **ដីកកោះហៅជនត្រូវចោទចូលសវនាការ**[54] ប៉ុន្តែប្រសិនបើជាក្នុងករណីដែលជនត្រូវចោទស្ថិតនៅក្នុងការឃុំខ្លួននោះ ការជូនដំណឹងអំពីសវនាការ ត្រូវធ្វើតាមរយៈអគ្គនាយកដ្ឋានពន្ធនាគារតាម **សំណើរចាត់ឱ្យនាំជនត្រូវចោទចូលសវនាការ**[55]។ ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ការជូនដំណឹងធ្វើឡើងតាមរយៈ **ដីកាកោះហៅដើមបណ្តឹងរដ្ឋប្បវេណី**[56]។ ជាមួយគ្នានេះផងដែរ ក្រឡាបញ្ជីក៏ត្រូវជូនដំណឹងទៅកាន់មេធាវី តាមរយៈការធ្វើ **លិខិតអញ្ជើញមេធាវី**[57]។ មិនតែប៉ុណ្ណោះ ក្នុងករណីដែល ជនត្រូវចោទជាជនបរទេ ក្រឡាបញ្ជីក៏ត្រូវធ្វើ **សំណើរសុំចាត់តាំងអ្នកបកប្រែ**[58] ដែលនីតិវិធីនៃការស្នើសុំនេះត្រូវបានធ្វើឡើងតានរយៈក្រសួងយុត្តិធម៌ ដែលមានទំនាក់ទំនងផ្ទាល់ជាមួយស្ថានទូតនៃជនត្រូវចោទនោះ។

ចំពោះការជូនដំណឹងអំពីកាលបរិច្ឆេទនេះ ធ្វើការបញ្ជូនតាមរយៈមន្ត្រីទទួលបន្ទុកផ្នែកកិច្ចការបញ្ជូននៃសាលាឧទ្ធរណ៍[59]។ ចំពោះ ការជូនដំណឹងទៅកាន់បណ្តារខេត្តគឺធ្វើឡើងតាមរយៈ បុគ្គលិកប្រៃសនីយ៍ ព្រោះមន្ត្រីទទួលបន្ទុកផ្នែកកិច្ចការបញ្ជូនធ្វើការបញ្ជូនតែនៅក្នុងតំបន់តែប៉ុណ្ណោះ។

### ១. ៥. របាយការណ៍សំណុំរឿង និងសេចក្តីសន្និដ្ឋាន

ចំពោះរបាយការណ៍សំណុំរឿងនេះ ឃើញថា ប្រធានសភាសព្រហ្មទណ្ឌចាត់តាំងចៅក្រមធ្វើរបាយការណ៍ម្នាក់ ។ ចៅក្រមធ្វើរបាយការណ៍នេះអាចជាប្រធាន ឬជាចៅក្រមអម របាយការណ៍មានកម្មវត្ថុរៀបរាប់អំពីដំណើរ

[53] ឧបសម្ព័ន្ធទី៩ សំណើរចាត់តាំងតំណាងមហាអយ្យការចូលរួមសវនាការ
[54] ឧបសម្ព័ន្ធទី១០ ដីកាកោះហៅជនត្រូវចោទចូលសវនាការ
[55] ឧបសម្ព័ន្ធទី១១ សំណើរចាត់ឱ្យនាំជនត្រូវចោទចូលសវនាការ
[56] ឧបសម្ព័ន្ធទី១២ ដីកាកោះហៅដើមបណ្តឹងរដ្ឋប្បវេណី
[57] ឧបសម្ព័ន្ធទី១៣ លិខិតអញ្ជើញមេធាវី
[58] ឧបសម្ព័ន្ធទី១៤ សំណើរសុំចាត់តាំងអ្នកបកប្រែ
[59] ឧបសម្ព័ន្ធទី១៥ សេចក្តីសម្រេចស្តីពី មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការបញ្ជូន

រឿង ហើយនឹងធ្វើឱ្យដឹងអំពីសាលក្រមដែលជូនមកសាលាឧទ្ធរណ៍នេះ។ របាយការណ៍ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវដាក់នៅក្នុងសំណុំរឿង ហើយត្រូវតែក្បោះក្បាយ ដូចចែងក្នុងមាត្រា ៣៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ចំពោះសភាស៊ើបសួរវិញ ពុំឃើញមានបញ្ញត្តិណាមួយដែលបញ្ជាក់អំពីការធ្វើរបាយការណ៍សំណុំរឿងដូចទៅនឹងសភាព្រហ្មទណ្ឌនោះទេ។ ប៉ុន្តែបើទោះបីជាបែបនេះក៏ដោយ ចំពោះការអនុវត្តជាក់ស្តែង ឃើញមានការធ្វើរបាយការណ៍សំណុំរឿងស៊ើបសួរផងដែរ ជាក់ស្តែងដូចជាក្នុងរឿងបណ្តឹងសុំមោឃភាពនេះជាដើម។ បើទោះបីជាច្បាប់មិនមានចែងក្នុងការធ្វើ ប៉ុន្តែការធ្វើរបាយការណ៍សំណុំរឿងស៊ើបសួរនេះមិនមានផលប៉ះពាល់ចំពោះនីតិវិធីនៃសំណុំរឿងនោះទេ មានតែផ្តល់នូវផលប្រយោជន៍ដល់នីតិវិធី ព្រោះដូចដែលបានលើកឡើងហើយថារបាយការណ៍សំណុំរឿងជាការសង្ខេបនូវសំណុំរឿងទាំងមូល ដើម្បីឱ្យមានភាពងាយស្រួលយល់ ក៏ដូចជាចំណេញពេលវេលាក្នុងការសិក្សាទៅលើសំណុំរឿងទាំងមូលផងដែរ។ ការធ្វើរបាយការណ៍នេះអាចធ្វើបាននៅមុនការជូនដំណឹង ឬនៅក្រោយពេលនៃការជូនដំណឹងក៏បាន តែមិនអាចធ្វើនៅក្រោយកិច្ចពិភាក្សាដេញដោលនោះទេ។

- **ទម្រង់នៃរបាយការណ៍សំណុំរឿងសភាស៊ើបសួរ ចំពោះរឿងមោឃភាពរួមមាន[60]៖**

- លេខសំណុំរឿងនៃសាលាឧទ្ធរណ៍
- អត្តសញ្ញាណនៃគូភាគី
- អង្គហេតុសង្ខេប
- ចម្លើយរបស់គូភាគី
- ឯកសារដែលពាក់ព័ន្ធនឹងបណ្តឹងសុំមោឃភាព
- ទម្រង់នៃបណ្តឹងសុំមោឃភាព
- សេចក្តីសន្និដ្ឋាន ។

របាយការណ៍សំណុំរឿង ដែលធ្វើរួចរាល់ហើយនោះត្រូវធ្វើការដាក់បញ្ចូលទៅក្នុងសំណុំរឿង។ បន្ទាប់មកត្រូវធ្វើការបញ្ជូនទាំងសំណុំរឿង ក៏ដូចជារបាយការណ៍សំណុំរឿងនោះទៅកាន់តំណាងមហាអយ្យការដែលត្រូវបានចាត់តាំងនោះធ្វើសេចក្តីសន្និដ្ឋាន។ ចំពោះ **សេចក្តីសន្និដ្ឋាន**[61] ដែលតំណាងមហាអយ្យការបានធ្វើរួចហើយនោះ គឺត្រូវឆ្លងកាត់ការត្រួតពិនិត្យដោយអគ្គព្រះរាជអាជ្ញារងមួយរូប ដែលត្រូវបានចាត់តាំងដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មុនពេលដែលត្រូវបញ្ជូនត្រឡប់មកកាន់ចៅក្រមទទួលបន្ទុកសំណុំរឿងវិញ។ ចំណុចគួរចាប់អារម្មណ៍ គឺការដែលសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យដោយ

[60] ឧបសម្ព័ន្ធទី១៦ របាយការណ៍សំណុំរឿង

[61] ឧបសម្ព័ន្ធទី១៧ សេចក្តីសន្និដ្ឋាន

អគ្គព្រះរាជអាជ្ញារងមួយរូបទៀតបែបនេះ គឺក្នុងគោលបំណងដើម្បីធានាឱ្យបាននូវភាពត្រឹមត្រូវ នឹងការពារពុំឱ្យកំហុសណាមួយកើតឡើងគ្រង់ប្រការណាមួយ ដែលនាំឱ្យមានភាពមិនប្រក្រតី ក៏ដូចជាធ្វើឱ្យបាត់បង់នូវជំនឿទុកចិត្តអំពីអ្នកដែលទទួលសោវាយុត្តិធម៌ ដែលនាំឱ្យមានផលប៉ះពាល់ដល់ស្ថាប័នទាំងមូល។

### ១.៦. ការពិគ្រោះសំណុំរឿង និងសារណា

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងមេធាវី អាចពិនិត្យមើលសំណុំរឿងរហូតដល់ពេលបើកសវនាការ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវប្រគល់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដល់ក្រឡាបញ្ជីយ៉ាងយូរបំផុត ១ ថ្ងៃមុនពេលសវនាការ។ សេចក្ដីសន្និដ្ឋាន និងសារណា ត្រូវចុះទិដ្ឋាការដោយក្រឡាបញ្ជីដោយមានការចុះកាលបរិច្ឆេទ និងត្រូវបញ្ចូលក្នុងសំណុំរឿងភ្លាមៗ គូភាគី និងមេធាវីត្រូវអនុញ្ញាតឱ្យជូនសារណាដល់ពេលចាប់ផ្ដើមបើកសវនាការ[62]។

## កថាខណ្ឌទី២៖ ចំណាត់ការនាពេលកិច្ចពិភាក្សាដេញដោល

### ២.១. ដំណើរការនៃកិច្ចពិភាក្សាដេញដោល

បន្ទាប់ពីបញ្ចប់ការជូនដំណឹងអំពីកាលបរិច្ឆេទនៃកិច្ចពិភាក្សាដេញដោល ក៏ដូចជាការប្រគល់នូវសេចក្ដីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញារួចមក ក៏ឈានចូលមកកិច្ចពិភាក្សាដេញដោល។ នៅក្នុងការធ្វើកិច្ចពិភក្សាដេញដោលត្រូវប្រព្រឹត្តទៅនៅក្នុងបន្ទប់កិច្ចពិភាក្សាដេញដោល[63]។ នៅមុនពេលដែលក្រុមប្រឹក្សាជំនុំជម្រះចូលមកដល់សាលសវនាការ ក្រឡាបញ្ជីធ្វើការផ្ទៀងផ្ទាត់វត្តមានរបស់អ្នកដែលចូលរួម ដើម្បីរៀបចំកន្លែងអង្គុយដែលមានភាពងាយស្រួលក្នុងការបង្ហាញខ្លួន។ ជាមួយគ្នានេះដែរ ក្រឡាបញ្ជីក៏ត្រូវធ្វើការផ្ទៀងផ្ទាត់ចំពោះដីកាបង្គាប់អំពីការជូនដំណឹង ដើម្បីធ្វើការរាយការណ៍ជូនប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

ក្រោយពេលដែលក្រុមប្រឹក្សាជំនុំជម្រះចូលដល់សវនាការ នោះប្រធានក្រុមប្រឹក្សាជំនុំជម្រះនឹងធ្វើការផ្ទៀងផ្ទាត់វត្តមាន ហើយអ្នកដែលមិនពាក់ព័ន្ធទៅនឹងរឿងក្ដីនឹងត្រូវអញ្ជើញឱ្យទៅរងចាំនៅខាងក្រៅនៃបន្ទប់កិច្ចពិភាក្សាដេញដោល ព្រោះថាក្នុងរឿងស៊ើបសួរគឺត្រូវប្រព្រឹត្តទៅជាអសាធារណៈ។ បន្ទាប់មក ប្រធានក្រុមប្រឹក្សាជំនុំជម្រះនឹងធ្វើការប្រកាសនូវអត្តសញ្ញាណនៃរឿងក្ដីដែលត្រូវធ្វើកិច្ចពិភាក្សាដេញដោល ព្រមទាំងអាននូវរបាយការណ៍សំណុំរឿង។ ក្រោយពីប្រធានក្រុមប្រឹក្សាធ្វើការអានរបាយការណ៍សំណុំរឿងរួចមក តំណាងមហាអយ្យការ ក៏ដូចជាមេធាវីអាចធ្វើការកត់សម្គាល់ដោយសង្ខេប។ មួយវិញទៀតក្នុងករណីដែលតំណាងមហាអយ្យការមានសំនួរអាចធ្វើការលើកឡើងបានដោយមានការសុំអនុញ្ញាតពីប្រធានក្រុមប្រឹក្សា។ បន្ទាប់ពីបញ្ចប់ការសាកសួរហើយ

[62] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៥៩

[63] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៦០

នោះ តំណាងមហាអយ្យការនឹងធ្វើសេចក្តីសន្និដ្ឋាន ហើយបន្តមកទៀតគឺការធ្វើសេចក្តីសន្និដ្ឋានរបស់មេធាវី ហើយចុងក្រោយការសំណូមពរជនត្រូវចោទ។

**២.២. ការសម្រេចសេចក្តី**

កាលណាការពិភាក្សាដេញដោលត្រូវបានបញ្ចប់ សភាស៊ើបសួរធ្វើការពិគ្រោះសម្រេចដោយគ្មានវត្តមានរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គូភាគី និងមេធាវីឡើយ[64]។

នៅក្នុងការសម្រេចសេចក្តីរបស់សភាស៊ើបសួរទៅលើបណ្តឹងសុំមោឃភាពនេះ អាចជាការដែលសម្រេចក្នុងការទទួលយកនូវបណ្តឹងសុំមោឃភាព ឬជាការដែលសម្រេចបដិសេធមិនឱ្យមានមោឃភាពលើកិច្ច ឬលិខិតនៃនីតិវិធីណាមួយ។ ចំពោះការដបិសេធចំពោះបណ្តឹងសុំមោឃភាពគឺផ្អែកទៅលើភាពដែលមិនអាចទទួលយកបាននៃពាក្យបណ្តឹងសុំមោឃភាព។

**២.២.១. ភាពដែលមិនអាចទទួលយកបាននៃបណ្តឹងសុំមោឃភាព**

នៅពេលដែលសភាស៊ើបសួរធ្វើការពិនិត្យពាក្យបណ្តឹងសុំមោឃភាព ឃើញថាពាក្យបណ្តឹងនោះមិនអាចទទួលយកបាន សភាសស៊ើបសួរនឹងធ្វើការប្រកាសអំពីការមិនអាចទទួលយកបាននៃពាក្យបណ្តឹងនោះ តាមរយៈការចេញសាលដីកាដែលជាសេចក្តីសម្រេចចុងក្រោយរបស់សភាស៊ើបសួរ ដែលមានសេចក្តីសម្រេចបដិសេធមិនទទួលយកពាក្យបណ្តឹងសុំមោឃភាព[65]។

ចំពោះសេចក្តីសម្រេចបដិសេធមិនទទួលពាក្យបណ្តឹងសុំមោឃភាពនេះ គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

- **ចំណុចដែលនាំឱ្យពាក្យបណ្តឹងសុំមោឃភាពមិនអាចទទួលយកបាន៖**

- **ពាក្យសុំគ្មានសំអាងហេតុ**

សំដៅលើពាក្យបណ្តឹងសុំមោឃភាព ដែលពុំមានហេតុផលពន្យល់លើកអំពីអង្គហេតុ និងអង្គច្បាប់ដែលបញ្ជាក់ថាកិច្ច ឬលិខិតនោះមានភាពមិនប្រក្រតី ខុសច្បាប់ ប៉ះពាល់ដល់សិទ្ធិនៃការការពារខ្លួនយ៉ាងធ្ងន់ធ្ងររបស់ជនណាមួយ។

- **ពាក្យបណ្តឹងសុំទាក់ទងនឹងដីកាដែលអាចប្តឹងឧទ្ធរណ៍**

ចំពោះដីកាដែលអាចធ្វើការប្តឹងឧទ្ធរណ៍បាន គឺពុំអាចធ្វើការប្តឹងសុំមោឃភាបាននោះទេ។

ជាឧទាហរណ៍៖ ចៅក្រមស៊ើបសួរបានសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ហើយបន្ទាប់ពីរយៈពេល ៥ ថ្ងៃបានកន្លងផុតទៅគឺហួសរយៈពេលនៃការប្តឹងឧទ្ធរណ៍រួចហើយ។ នៅពេលនោះជនត្រូវចោទបានប្តឹង

---

[64] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៦០ ក ៤

[65] ឧបសម្ព័ន្ធទី១៨ សាលដីកាទទួលពាក្យបណ្តឹងសុំមោឃភាព

សុំមោឃភាពលើដីកាសម្រេចឃុំខ្លួន ដោយលើមូលហេតុថាចៅក្រមស៊ើបសួរមិនបានផ្តល់សិទ្ធិឱ្យជនត្រូវចោទបញ្ចេញមតិជុំវិញការសម្រេចឃុំខ្លួននេះ។ ដូចនេះ ពាក្យបណ្តឹងសុំមោឃភាពនេះនឹងត្រូវប្រកាសថាមិនទទួលយកបានដោយមូលហេតុ ដីកាដែលប្តឹងសុំមោឃភាពមកនោះគឺជាដីកាដែលអាចធ្វើការប្តឹងឧទ្ធរណ៍បាន។

ដូចនេះ រាល់ដីកាដែលអាចធ្វើការប្តឹងឧទ្ធរណ៍បានគឺពុំអាចធ្វើការប្តឹងសុំមោឃភាពបាននោះទេ[66]។

- **ពាក្យបណ្តឹងគ្មានមូលកភាពជាក់ស្តែង**

មួយវិញទៀត ប្រសិនបើពាក្យបណ្តឹងសុំមោឃភាពនោះ ត្រូវបានដាក់នៅក្រោយពេលដែលដីកាដំណោះស្រាយចូលជាស្ថាពរនោះ (ការលុបលាងមោឃភាព) គឺមិនអាចដាក់ពាក្យបណ្តឹងមោឃភាពបាននោះទេ។

ដីកាដំណោះស្រាយដែលចូលជាស្ថាពរ លុបលាងមោឃភាពនៃនីតិវិធីមុនប្រសិនបើមាន។ គ្មានមោឃភាពណាមួយដែលត្រូវបានលើកឡើងនៅចំពោះមុខចៅក្រមជំនុំជម្រះបានទៀតឡើយ[67]។ ហេតុដូច្នេះ ហើយបុគ្គលដែលមានសិទ្ធិប្តឹងពុំអាចធ្វើការដាក់ពាក្យបណ្តឹងសុំមោឃភាពទៀតបាននោះទេ។ ភាគីត្រូវធ្វើការប្តឹងនៅមុនពេលដែលដីកាដំណោះស្រាយនោះមិនទាន់ចូលជាស្ថាពរ។ ចំពោះ ពាក្យបណ្តឹងដែលពុំមានមូលកភាពជាក់ស្តែងនេះគឺអាចជាការដែលសំដៅដល់ការដែលគ្មានមូលដ្ឋានទាំងឡាយណាដែលនាំឱ្យមានការសន្និដ្ឋានថាពិតជាមានការប្រព្រឹត្តខុសជានឹងនីតិវិធី។

ចំពោះការសម្រេចសេចក្តីលើការបដិសេធមិនទទួលពាក្យបណ្តឹងសុំមោឃភាពរបស់សភាស៊ើបសួរ គឺជាសេចក្តីសម្រេចមិនអាចតវ៉ាបាន។ ហើយមួយវិញទៀតក្នុងករណីដែលពាក្យប្តឹងសុំត្រូវប្រកាសមិនទទួលបានទេនោះសំណុំរឿងត្រូវបង្វិលភ្លាមទៅចៅក្រមស៊ើបសួរ[68]។

### ២.២.២. ការទទួលយកពាក្យបណ្តឹងសុំមោឃភាព

នៅពេលដែលសភាស៊ើបសួរពិនិត្យឃើញចំណុចដែលនាំឱ្យមានមោឃភាពនោះសភាស៊ើបសួរ នឹងធ្វើការសម្រេចអំពីការទទួលយកពាក្យបណ្តឹងសុំមោឃភាពនោះ។

ដូចនេះ នៅក្នុងការប្រកាសសេចក្តីសម្រេចដែលធ្វើឡើងតាមរយៈ **សាលដីកាដែលទទួលយកពាក្យបណ្តឹងសុំមោឃភាព**[69] ដែលនៅក្នុងនោះរួមមានការបញ្ជាក់នៅក្នុងការវិនិច្ឆ័យសេចក្តីអំពីការទទួលពាក្យបណ្តឹងសុំមោឃភាព ព្រមទាំងបញ្ជាក់អំពីលិខិត ឬកិច្ចណាមួយដែលត្រូវបានទុកជាមោឃភាព រួមជាមួយការបញ្ជាក់អំពីការដកចេញនូវលិខិតដែលត្រូវទុកជាមោឃចេញពីសំណុំរឿង ហើយសម្រេចបង្វិលសំណុំរឿងនោះទៅកាន់ចៅក្រមស៊ើបសួរនៃសាលាដំបូងវិញ។

[66] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៧៩

[67] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៥៦

[68] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៧៩ កថាខណ្ឌទី ៣

[69] ឧសម្ព័ន្ធទី១៩ សាលដីកាបដិសេធពាក្យបណ្តឹងសុំមោឃភាព

ដូច្នេះនៅពេលដែលមានការទទួលយកនូវបណ្ដឹងសុំមោឃភាព នោះនឹងនាំឱ្យមានអានុភាពនៃមោឃកម្ម កើតឡើង[70]។

## កថាខណ្ឌទី៣៖ ចំណាត់ការក្រោយកិច្ចពិភាក្សាដេញដោល

នៅក្រោយកិច្ចពិភាក្សាដេញដោល ក៏ដូចការថយទៅពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាជំនុំជម្រះរួចមក ប្រធានសភាស៊ើបសួរនឹងធ្វើការសម្រចសេចក្ដីអំពីការទទួល ឬបដិសេធចំពោះពាក្យបណ្ដឹងសុំមោឃភាព។ ចំពោះការប្រកាសសាលដីកាអាចធ្វើការប្រកាសនៅពេលសវនាការអសាធារណៈនៅថ្ងៃនោះ ឬ ក៏នៅពេលសវនាការលើកក្រោយ។ សាលដីកាត្រូវតែមានសំអាងហេតុ ហើយត្រូវមានធាតុដែលចាំបាច់ដល់ការត្រួតពិនិត្យរបស់តុលាការកំពូល។ សាលដីកាត្រូវមានការចុះហត្ថលេខាដោយប្រធានសភាស៊ើបសួរ[71]។

- **ចំពោះការជូនដំណឹងអំពីសាលដីកា**

សាលដីកាត្រូវធ្វើការជូនដំណឹងដោយផ្ទាល់មាត់ក្នុងពេលដ៏ខ្លីបំផុតដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក្រឡាបញ្ជីចុះនិទ្ទេសអំពីកាលបរិច្ឆេទនៃការជូនដំណឹងនៅរឹមទំព័រនៃសាលដីកា។ អគ្គព្រះរាជអាជ្ញា ធ្វើការចុះហត្ថលេខាថាបានទទួល[72]។ មួយវិញទៀតចំពោះការអនុវត្តជាក់ស្ដែង ការជូនដំណឹងអំពីសាលដីកាទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជានិច្ចកាលតែងតែធ្វើឡើងជាលាយលក្ខណ៍អក្សរដែលក្នុងនោះការជូនដំណឹងអំពីសាលដីកាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ជាលាយលក្ខណ៍អក្សរបែបនេះតែងតែភ្ជាប់ទៅជាមួយនូវ **ដីកាបញ្ជូន**[73]។

ចំពោះការជូនដំណឹងអំពីសាលដីកាទៅកាន់ភាគី និងមេធាវី ដូចមានចែងនៅក្នុងមាត្រា ២៣៨ (ការជូនដំណឹងអំពីការសម្រេចសេចក្ដីដល់ជនត្រូវចោទ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ[74]។

ដីការបស់ចៅក្រមស៊ើបសួរ ដែលត្រូវជូនដំណឹងដល់ជនត្រូវចោទ ដែលត្រូវឃុំខ្លួនតាមរបៀបដូចតទៅ៖

- ដោយផ្ទាល់មាត់
- តាមរយៈប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួ។

ដីការបស់ចៅក្រមស៊ើបសួរ ដែលត្រូវជូនដំណឹងដល់ជនត្រូវចោទនៅក្រៅឃុំ ដល់ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីតាមរបៀបដូចតទៅនេះ

[70] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៨០
[71] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៦០
[72] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៦០
[73] ឧបសម្ព័ន្ធទី២០ ដីកាបញ្ជូនសាលដីកាទៅកាន់អគ្គព្រះរាជអាជ្ញា
[74] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា មាត្រា ២៦០ កថាខណ្ឌ៧

-ដោយផ្ទាល់មាត់

- តាមផ្លូវរដ្ឋបាល ឬ

-តាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ។

កាលណាការជូនដំណឹងត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ នោះក្រឡាបញ្ជីចុះនិទ្ទេសអំពីការជូនដំណឹងនៅរឹមដីកា។ ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវចុះហត្ថលេខារបស់ខ្លួន។

នៅក្នុងករណីដទៃទៀត ការជូនដំណឹងត្រូវធ្វើតាមការប្រគល់សេចក្ដីចម្លងដីកា ដោយមានចំណាររបស់អ្នកទទួលថាបានទទួលទុកជាសម្គាល់[75]។

[75] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៣៨

# ជំពូកទី៣

# សេចក្តីសម្រេច

# លើបណ្តឹងសុំមោឃភាព

# ជំពូកទី៣
# សេចក្តីសម្រេចលើបណ្តឹងសុំមោឃភាព

នីតិវិធីមោឃភាព គឺជានីតិវិធីមួយដែលមានការផ្តល់នូវផលប្រយោជន៍ជូនជនដែលត្រូវបានរំលោភបំពានតាមរយៈការអនុវត្តនីតិវិធីណាដែលបង្កឡើងដោយ ការមិនគោរពលើវិធានដែលច្បាប់បានកំណត់ ឬ តាមរយៈការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិនៃការការពារខ្លួន។ កាលណាមានការចាត់ទុកកិច្ច ឬលិខិតណាមួយថាមានមោឃភាព នោះនឹងនាំឱ្យមានអានុភាពនៃមោឃកម្មកើតឡើង។

កាលណាមានការទទួលបណ្តឹងសុំមោឃកម្មចំពោះកិច្ច ឬ លិខិតណាមួយនៃនីតិវិធី ប្រសិនបើសភាស៊ើបសួរយល់ព្រមតាមពាក្យសុំនេះ សភាស៊ើបសួរសម្រេចថា តើមោឃកម្មនេះត្រូវធ្វើទៅលើកិច្ច ឬ លិខិតផ្សេងទៀតដែរ ឬទេ។

កិច្ច ឬលិខិតដែលត្រូវចាត់ទុកជាមោឃៈ ត្រូវដកចេញពីសំណុំរឿង ហើយតម្កលទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។

ជាឧទាហរណ៍៖ បុគ្គល ក ដែលជាជត្រូវចោទធ្វើការប្តឹងសុំមោឃភាពលើកំណត់ហេតុការស្តាប់ចម្លើយបន្ទាប់ពីការទទួលសំណុំរឿង ហើយចាត់ការតាមនីតិវិធីរួចមក សភាស៊ើបសួរធ្វើការសម្រេចមោឃភាពតាមពាក្យប្តឹងសុំមោឃភាពនោះ ដូចនេះអានុភាពនៃបណ្តឹងសុំមោឃភាពនឹងកើតមានឡើងតាមរយៈការដកនូវកំណត់ហេតុស្តាប់ចម្លើយនោះចេញពីសំណុំរឿង ហើយលិខិតដែលត្រូវដកចេញនោះនឹងត្រូវធ្វើការបញ្ជូនមកកាន់ការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ ដើម្បីធ្វើការតម្កល់ទុក ហើយសំណុំរឿងនឹងត្រូវធ្វើការបន្តទៅតាមនីតិវិធីបន្ត។

កាលណាមានការទទួលយកពាក្យបណ្តឹងសុំមោឃភាពលើលិខិត ឬ នីតិវិធីណាមួយនោះនឹងនាំឱ្យមានអានុភាព ក៏ដូចជាផលវិបាកមួយចំនួនក្នុងនីតិវិធីផងដែរ។ ជាក់ស្តែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់អំពីផលវិបាកនៃនីតិវិធីដែលកើតមានឡើងតាមរយៈការចាត់ទុកកិច្ច ឬលិខិតណាមួយថាមោឃភាពផងដែរ។ ក្នុងនោះមានកំណត់នៅក្នុងមាត្រា ២៨១ ដែលបានបញ្ញត្តិថា ក្រោយពីធ្វើមោឃកម្មរួចមកសភាស៊ើបសួរអាច ធ្វើការបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ឬ ដកសមត្ថកិច្ចចៅក្រមស៊ើបសួរ ហើយបញ្ជូនទៅកាន់ចៅក្រមស៊ើបសួរដទៃទៀត ហើយម៉្យាងទៀតអាចជាការបន្តការស៊ើបសួរដោយសភាស៊ើបសួរដោយសភាស៊ើបសួរក៏បាន។ ចំពោះចំណុចដែលបានលើកឡើងនៅក្នុងផលវិបាកចំពោះមោឃកម្ម ដូចបានរៀបរាប់នៅក្នុងមាត្រា ២៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នឹងធ្វើការបកស្រាយលំអិតនៅក្នុងចំណុចបន្តបន្ទាប់។

**កថាខណ្ឌទី១៖ ការបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរ**

ការបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញនេះ ធ្វើឡើងនៅពេលដែលសភាស៊ើបសួរមានការទទួលយកនូវបណ្តឹងសុំមោឃភាព ដែលនាំឱ្យមានអានុភាពនៃមោឃកម្មកើតមានឡើង។ ចំពោះការបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញនេះ គឺសំដៅលើការដែលបង្វិលសំណុំរឿងនោះទៅកាន់ចៅក្រមដើមនៅសាលាដំបូងដែលបានធ្វើកិច្ចនីតិវិធីនេះ ដើម្បីចៅក្រមស៊ើបសួរនោះធ្វើការស៊ើបសួរសារជាថ្មីលើកិច្ចនោះ ឬបន្តការស៊ើបសួរបន្តទៀតជាដើម។

ជាការកត់សម្គាល់ ការបង្វិលសំណុំរឿងទៅកាន់ចៅក្រមស៊ើបសួរនេះ មិនមែនអាចធ្វើបានតែនៅពេលដែលមានការទទួលយកនៅបណ្តឹងសុំមោឃភាពនោះទេ តែក្នុងករណីដែលមានការបដិសេធមិនទទួលបណ្តឹងសុំមោឃភាពដោយពាក្យបណ្តឹងសុំមោឃភាពនោះមានហេតុដែលមិនអាចទទួលយកបាននោះ ក៏នឹងនាំឱ្យមានការបង្វិសំណុំរឿងទៅចៅក្រមស៊ើបសួរវិញភ្លាមផងដែរ[76]។

**កថាខណ្ឌទី២៖ ការដកហូតសម្ថតកិច្ចចៅក្រមស៊ើបសួរ ហើយបញ្ជូនទៅចៅក្រមផ្សេង**

ផលវិបាកនៃមោឃភាព ចំពោះចំណុចទី១ ដូចដែលបានលើកឡើងគឺ ជាផលវិបាកដែលពុំមែនជាចំណុចដែលគួរកត់សម្គាល់ធ្ងន់ធ្ងរទៅលើការអនុវត្តរបស់ចៅក្រមស៊ើបសួរនោះទេ ព្រោះជាភាពសមស្របទៅនឹងការបង្វិលសំណុំរឿងទៅកាន់ចៅក្រមស៊ើបសួរដដែលដើម្បីធ្វើការបន្តនីតិវិធីរបស់ខ្លួន។

ប៉ុន្តែក្នុងករណីនៃការដកសមត្ថកិច្ចចៅក្រមស៊ើបសួរដើមដែលបានចាត់ការលើសំណុំរឿងដែលត្រូវបានប្តឹងសុំមោឃភាពនោះ ហើយបញ្ជូនទៅកាន់ចៅក្រមស៊ើបសួរផ្សេងនេះ គឺជាចំណុចដែលគួរតែធ្វើការកត់សម្គាល់អំពីការអនុវត្តនីតិវិធីរបស់ចៅក្រមស៊ើបសួរដើម។ ក្នុងការអនុវត្តនីតិវិធីអាចនឹងមានចំណុចដែលមានភាពមិនប្រក្រតី ឬក៏អាចមានការរំលោភបំពានសិទ្ធិណាមួយ ដែលនាំឱ្យមានការបាត់បង់នូវទំនុកចិត្តរបស់សភាស៊ើបសួរទៅលើចៅក្រមស៊ើបសួរដើមនោះ។ ក្នុងន័យនេះមានន័យថា អាចជាការបារម្ភរបស់សភាស៊ើបសួរ ក្នុងការបង្វិលសំណុំរឿងទៅកាន់ចៅក្រមស៊ើបសួរដដែល ដែលអាចនាំឱ្យមានភាពមិនប្រក្រតីណាមួយកើតឡើងបន្តទៀត ឬយ៉ាងណា។

**កថាខណ្ឌទី៣៖ ការបន្តការស៊ើបសួរដោយសភាស៊ើបសួរ**

ចំពោះការបន្តការស៊ើបសួរដោយសភាស៊ើបសួរនេះ គឺបង្ហាញអំពីការសម្រេចមិនបង្វិលសំណុំរឿងទៅកាន់ចៅក្រមស៊ើបសួរវិញ ហើយក៏មិនជ្រើសរើសការដកហូតសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ។ចំពោះការបន្តការស៊ើបសួរដោយសភាស៊ើបសួរនេះ គឺបង្ហាញអំពីការសម្រេចមិនបង្វិលសំណុំរឿងទៅកាន់ចៅក្រមស៊ើបសួរវិញ ហើយក៏

[76] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៧៩

មិនជ្រើសរើសការដកហូតសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ហើយបញ្ជូនទៅចៅក្រមស៊ើបសួរដទៃទៀតផងដែរ គឺសម្រេចបន្តការស៊ើបសួរដោយខ្លួនឯងតែម្តង។

កាលណាសភាស៊ើបសួរ សម្រេចថាបន្តការស៊ើបសួរដោយខ្លួននោះ សភាស៊ើបសួរប្រគល់ភារកិច្ចទៅសមាជិកម្នាក់របស់ខ្លួន ដែលប្រើប្រាស់អំណាចជាចៅក្រមស៊ើបសួរ លើកលែងតែអំណាចដែលមានចែងនៅក្នុងជំពូកទី៥ ស្តីពីការបិទការស៊ើបសួរនៃមាតិកាទី ១ ស្តីពីចៅក្រមស៊ើបសួរក្នុងគន្ថីនេះ។ ការលើកឡើងអំពីការដែលចៅក្រមស៊ើបសួរ ដែលត្រូវបានចាត់ឱ្យមានអំណាចដូចចៅក្រមស៊ើបសួរ ប៉ុន្តែមិនអាចធ្វើការបិទការស៊ើបសួរនោះដោយសារតែអ្នកដែលមានសមត្ថកិច្ចក្នុងកបិទការស៊ើបសួរក្នុងករណីដែលមានការស៊ើបសួរដោយសភាស៊ើបសួរនេះ គឺប្រធានសភាស៊ើបសួរជាអ្នកមានសិទ្ធិអំណាចក្នុងការបិទការស៊ើបសួរ តាមរយៈការចេញជា សាលដីកាដំណោះស្រាយ[77]។

[77] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ២៨២

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានឆ្លងកាត់ការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីអំពី បណ្តឹងសុំមោឃភាពនីតិវិធី នៅក្នុងរឿងព្រហ្មទណ្ឌរួចមក យើងឃើញថា នីតិវិធីនៃបណ្តឹងសុំមោឃភាព គឺមានសារៈសំខាន់ណាស់ ព្រោះជាវិធានមួយដែលត្រូវបានបង្កើតឡើងក្នុង គោលបំណងដើម្បីការពារសិទ្ធិនៃការការពារខ្លួនរបស់ជនដែលត្រូវបានរំលោភបំពានសិទ្ធិ តាមរយៈការអនុវត្តនីតិវិធីរបស់អ្នកអនុវត្តច្បាប់ ដែលពុំគោរពតាមបញ្ញត្តិច្បាប់ ឬការអនុវត្តនោះរំលោភបំពានសិទ្ធិនៃការការពារខ្លួនយ៉ាងធ្ងន់ធ្ងររបស់ជនណាមួយ។ ចំពោះសិទ្ធិនៃការការពាររបស់ជនគ្រប់រូបគឺមានសារៈសំខាន់ណាស់ ហើយមិនមែនត្រឹមតែច្បាប់ជាតិប៉ុណ្ណោះទេ ដែលត្រូវបានការការពារ ប៉ុន្តែជាក់ស្តែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ក៏ដូចជាអនុសញ្ញា សន្ធិសញ្ញា និងកតិកាសញ្ញាអន្តរជាតិមួយចំនួនក៏ត្រូវបានកំណត់អំពីសិទ្ធិនៃការពារខ្លួនរបស់ជនគ្រប់រូបផងដែរ។

មោឃភាពនីតិវិធី សំដៅដល់ការដែលចាត់ទុកកិច្ច ឬ លិខិតណាមួយជាមោឃមិនអាចយកមកអនុវត្តនៅក្នុងសំណុំរឿងបាន។ ចំពោះ មោឃភាព អាចកើតឡើងតាមរយៈរូបភាពពីរយ៉ាងដែលក្នុងនោះអាចជាការដែលមានគេប្តឹងសុំមោឃភាពនីតិវិធីណាមួយ ឬម្យ៉ាងទៀតសភាស៊ើបសួរធ្វើការមោឃភាពដោយឯកឯងទៅលើកិច្ច ឬលិខិតណាមួយតែម្តងនៅពេលដែលពិនិត្យឃើញមូលហេតុនៃមោឃភាពកិច្ចនោះ។ ជាក់ស្តែង ជាគោលការណ៍សភាស៊ើបសួរអាចធ្វើការពិនិត្យលើមោឃភាពបានលុះត្រាតែមានការប្តឹងសុំពីបុគ្គលណាមួយ ប៉ុន្តែក្នុងករណីដែលមានការប្តឹងឧទ្ធរណ៍លើដីកាសម្រេចណាមួយ ដែលមិនពាក់ព័ន្ធនឹងបណ្តឹងសុំមោឃភាពនោះទេ តែដោយសារតែនៅពេលដែលសភាស៊ើបសួរ ពិនិត្យមើលលើនិយ័តភាពនៃនីតិវិធី ហើយឃើញមានចំណុចដែលអាចមោឃភាព ដូចនេះសភាស៊ើបសួរ អាចប្រកាសអំពីមោឃភាពដោយឯកឯងតែម្តង។ ជាមួយគ្នានេះ បណ្តឹងសុំមោឃភាពនីតិវិធីមិនមែនគ្រប់បុគ្គលទាំងអស់សុទ្ធតែអាចធ្វើការដាក់បណ្តឹងសុំបាននោះទេ ព្រោះច្បាប់បានផ្តល់សិទ្ធិឱ្យតែបុគ្គលមួយចំនួនតែប៉ុណ្ណោះ ដែរបុគ្គលទាំងនោះរួមាមាន ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ដែលអាចធ្វើតាមរយៈមេធាវីរបស់ពួកគេបាន។ ការដាក់ពាក្យបណ្តឹងសុំមោឃភាព គឺត្រូវធ្វើការដាក់នៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរនៃសាលាឧទ្ធរណ៍។ ហើយសំណុំរឿងនឹងត្រូវបានបញ្ជូនមកសភាស៊ើបសួរនៃសាលាឧទ្ធរណ៍។ នៅពេលដែលមានការចាត់តាំងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដែលជាចៅក្រមទទួលបន្ទុកសំណុំរឿងរួចហើយនឹងនាំឱ្យមានការជូនដំណឹងអំពីកិច្ចពិភាក្សាដេញដោលទៅកាន់ភាគីដែលពាក់ព័ន្ធ។ ចំពោះកិច្ចពិភាក្សាដេញដោលនៅក្នុងរឿងមោឃភាព គឺត្រូវធ្វើនៅក្នុងបន្ទប់ពិភាក្សាដេញដោល ជាអសាធារណៈ ដែលពុំអនុញ្ញាតឱ្យបុគ្គលដែលមិនពាក់ព័ន្ធក្នុងរឿងក្តីចូលរួមនោះទេ។ រីឯការសម្រេចសេចក្តី នៅក្នុងរឿងមោឃភាពរបស់សភាស៊ើបសួរវិញ គឺធ្វើឡើងតាមរយៈការចេញសាលដីការបស់សភាស៊ើបសួរ។ សាលដីកានោះអាចជាសាលដីកាបដិសេធបណ្តឹងសុំមោឃភាព ដែលការសម្រេចអំពីការបដិសេធនេះគឺជាសេចក្តីសម្រេចមិនអាចតវ៉ាបាននោះ

មួយវិញទៀតអាចជា សាលដីកាទទួលយកបណ្តឹងសុំមោឃភាព មានន័យថា សភាស៊ើបសួរពិនិត្យឃើញចំណុចដែលនាំឱ្យមោឃភាព ហើយបណ្តឹងសុំមោឃភាពនោះមានមូលកភាពជាក់ស្តែងជាដើម។ ចំណែកឯកលិខិតដែលត្រូវបានសភាស៊ើបសួរទុកជាមោឃនោះ នឹងត្រូវដកចេញពីសំណុំរឿង ហើយបញ្ជូនមកកាន់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ដើម្បីតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនសភាស៊ើបសួរ។ ការដកចេញនូវលិខិតដែលទុកជាមោឃភាពនេះ គឺជាអានុភាពនៃមោឃកម្ម។ លើសពីនេះទៅទៀត មោឃភាពនីតិវិធី ក៏នឹងនាំឱ្យផលវិបាកនៃមោឃកម្មកើតឡើងផងដែរ ដែលអាចជាការបង្វិលសំណុំរឿងទៅកាន់ចៅក្រមស៊ើបសួរវិញ ការដកហូតសមត្ថកិច្ចចៅក្រមស៊ើបសួរ ហើយបញ្ជូនទៅចៅក្រមស៊ើបសួរដទៃទៀត និងការដែលសភាស៊ើបសួរបន្តការស៊ើបសួរដោយខ្លួនឯង។ ចុងក្រោយនៃការសម្រេចសេចក្តី ទទួល ឬបដិសេធបណ្តឹងសុំមោឃភាព ហើយសភាស៊ើបសួរនឹងធ្វើការប្រកាសសាលដីជាអសាធារណៈនៅក្នុងថ្ងៃនៃកិច្ចពិភាក្សាដេញដោល ឬ អាចលើកពេលទៅសវនាការពេលក្រោយក៏បាន។

ជារួមមកឃើញថា វិធាននៃបណ្តឹងសុំមោឃភាពនីតិវិធីនេះ គឺជាវិធានដ៏មានសារៈសំខាន់ដែលអ្នកអនុវត្តច្បាប់គ្រប់រូបដែលពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់ខ្ពស់ដើម្បីចៀសផុតពីការប្តឹងសុំមោឃភាពលើកិច្ច ឬលិខិតណាមួយ ព្រោះដូចការលើកឡើងពីខាងដើមហើយថា មោឃភាពគឺជាការចាត់ទុកថាឥតបានការលើលិខិត ឬកិច្ចណាដែលសម្រេចថាមោឃភាព។ មួយវិញទៀតគ្រប់កិច្ច ក៏ដូចជាលិខិតដែលត្រូវបានធ្វើនោះគឺសុទ្ធតែជាភស្តុតាងជាមូលដ្ឋាននៃការសម្រេច និងពិចារណា ក្នុងការចោទប្រកាន់ ឬការសម្រេចសេចក្តី។ ដូចនេះ ប្រសិនបើការអនុវត្តដោយមានការធ្វេសប្រហែសលើចំណុចណាមួយដែលជាមូលហេតុនៃការមោឃភាពនោះ នឹងនាំឱ្យមានការបាត់បង់នូចមូលដ្ឋាននៃភស្តុតាងក្នុងការសម្រេច ក៏ដូចជាការពិចារណា ដែលអាចនាំឱ្យជនដែលមានពិរុទ្ធរួចផុតពីការចោទប្រកាន់ជាដើម។

# មតិយោបល់

# មតិយោបល់

បន្ទាប់ពីធ្វើការសិក្សាលើប្រធានបទស្តីអំពី **បណ្តឹងសុំមោឃភាពនីតិវិធី** ក្នុងរឿងព្រហ្មទណ្ឌរួចមកបាន សង្កេតឃើញថាមានបញ្ញត្តមួយចំនួនដែលពាក់ព័ន្ធភាពពិបាក ក៏ដូចជាបញ្ហាចោទមួយចំនួនផងដែរ ដែលគួរគប្បី មានការកែប្រែ ក៏ដូចជាបំពេញបន្ថែម ដើម្បីឱ្យការអនុវត្តនីតិវិធីកាន់តែមានប្រសិទ្ធភាព និងជៀសផុតពីការប្តឹងសុំ មោឃភាពនីតិវិធី គួរគប្បីៈ

- ធ្វើការផ្សព្វផ្សាយបន្ថែមអំពីនីតិវិធីព្រហ្មទណ្ឌ ឱ្យកាន់តែមានភាពទូលំទូលាយ
- ធ្វើការបកស្រាយលើបញ្ញត្តិនៃក្រមនីតិវិធី ដើម្បីឱ្យមានភាពងាយស្រួលក្នុងការស្វែងយល់

# ឯកសារយោង

# ឯកសារយោង

## លិខិតបទដ្ឋានគតិយុត្តជាតិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- ច្បាប់ស្តីពី យុត្តិធម៌អនីតិជន

## លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ  ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៩៦
- សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស
- ធម្មនុញ្ញអង្គការសហប្រជាជាតិ

## សៀវភៅ

- នីតិវិធីព្រហ្មទណ្ឌ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត
- សៀវភៅ នីតិវិធីព្រហ្មទណ្ឌ លោកគ្រូ កើតរិទ្ធិ

## គេហទំព័រ

- ការផ្សព្វផ្សាយរបស់សាលាត្រាជូ ទ្រឹស្តីនៃមោឃភាពនៃលិខិត ឬកិច្ចនីតិវិធីព្រហ្មទណ្ឌ ប្រែសម្រួលដោយ លោក ចក សម្បត្តិ http://salatraju.com/index.php/post?p=29

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

| ល.រ | | ចំនួន |
|---|---|---|
| ឧបសម្ព័ន្ធទី១ | កំណត់ហេតុស្តីពីការស្តាប់ចម្លើយ | ២ |
| ឧបសម្ព័ន្ធទី២ | កំណត់ហេតុស្តីពីការស្រង់ចម្លើយ | ១ |
| ឧបសម្ព័ន្ធទី៣ | ពាក្យបណ្តឹងសុំមោឃភាព | ៣ |
| ឧបសម្ព័ន្ធទី៤ | សំណើចាត់បញ្ជូនសំណុំរឿង | ១ |
| ឧបសម្ព័ន្ធទី៥ | ដីកាបញ្ជូន | ១ |
| ឧបសម្ព័ន្ធទី៦ | ដីកាបញ្ជូន | ១ |
| ឧបសម្ព័ន្ធទី៧ | សៀវភៅទទួលសំណុំរឿងស៊ើបសួរ | ១ |
| ឧបសម្ព័ន្ធទី៨ | ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះ | ១ |
| ឧបសម្ព័ន្ធទី៩ | សំណើចាត់តាំងតំណាងមហាអយ្យការចូលរួមសវនាការ | ១ |
| ឧបសម្ព័ន្ធទី១០ | ដីកាកោះជនត្រូវចោទឱ្យចូលសវនាការ | ១ |
| ឧបសម្ព័ន្ធទី១១ | សំណើសុំចាត់ឱ្យនាំជនជាប់ចោទមកសវនាការ | ១ |
| ឧបសម្ព័ន្ធទី១២ | លិខិតអញ្ជើញមេធាវី | ១ |
| ឧបសម្ព័ន្ធទី១៣ | ដីកាកោះដើមបណ្តឹងរដ្ឋប្បវេណី | ១ |
| ឧបសម្ព័ន្ធទី១៤ | សំណើសុំចាត់តាំងអ្នកបកប្រែ | ១ |
| ឧបសម្ព័ន្ធទី១៥ | របាយការណ៍សំណុំរឿងសភាស៊ើបសួរ | ១ |
| ឧបសម្ព័ន្ធទី១៦ | សេចក្តីសន្និដ្ឋាន | ១ |
| ឧបសម្ព័ន្ធទី១៧ | ដីកាសម្រេចអំពីមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន | ១ |
| ឧបសម្ព័ន្ធទី១៨ | សាលដីកាសភាស៊ើបសួរ (ទទួលពាក្យបណ្តឹងសុំមោឃភាព) | ៣ |
| ឧបសម្ព័ន្ធទី១៩ | សាលដីកាសភាស៊ើបសួរ (ប្រកាសមិនទទួលពាក្យបណ្តឹងមោឃភាព) | ១ |
| ឧបសម្ព័ន្ធទី២០ | ដីកាបញ្ជូន (សាលដីកា) ទៅកាន់អគ្គព្រះរាជអាជ្ញា | ១ |

# ឧបសម្ព័ន្ធទី១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង
ខេត្តកំពង់ឆ្នាំង

*សំណុំរឿងព្រហ្មទណ្ឌលេខ៖*

*ចុះថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ២០១៩*

## កំណត់ហេតុសួរចម្លើយ

ឆ្នាំពីរពាន់ដប់ប្រាំបួន ខែ កក្កដា ថ្ងៃទីពីរ វេលាម៉ោងពីរ និងសាបសិបនាទី រសៀល ។

យើង ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកំពង់ឆ្នាំង ដោយមានលោក ជាក្រឡាបញ្ជី អមផង បានសួរ និងកត់យកចម្លើយរបស់ឈ្មោះ ជាជនសង្ស័យ ។

សួរ-ឆ្លើយ៖ ខ្ញុំបាទឈ្មោះ កទ ប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ , កើតនៅ ស្រុក ខេត្តកំពង់ឆ្នាំង ,មានទីលំនៅភូមិចុងកោះ ត ,ឪពុកឈ្មោះ ), ម្តាយឈ្មោះ , មានប្រពន្ធឈ្មោះ មានកូន០ , ទោសពីមុន ធ្លាប់ជាប់ពន្ធនាគាចំនួន០២ខែ ពីបទ៖ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។

សួរ-ឆ្លើយ៖ ខ្ញុំបាទសូមឆ្លើយជូនលោកព្រះរាជអាជ្ញាតែការពិតថា ៖ កាលពីថ្ងៃកើតហេតុខ្ញុំបាទមិនចាំថ្ងៃទេ គឺនៅថ្ងៃនោះខ្ញុំបាទបានទិញថ្នាំញៀនពីឈ្មោះ ដោយបានគេតាមទូរសព្ទទិញថ្នាំចំនួន០១កញ្ចប់ ក្នុងតម្លៃ២០០០០រៀល ដោយខ្ញុំបាទបានណាតជួបឈ្មោះ សៅ នៅផ្លូវកែងសន្ទូច ពេលទៅជួបឈ្មោះ ឈ្មោះ សៅមិនទាន់បានអោយថ្នាំញៀនមកខ្ញុំបាទនោះទេ គឺគាត់បានប្រើខ្ញុំបាទអោយយកកញ្ចប់នំមួយកញ្ចប់ និង ទូរសព្ទចំនួន០២គ្រឿង ម៉ាកអ៊ិនចុចពិលទាំងពីរ ទៅអោយបងវា តែខ្ញុំបាទមិនស្គាល់បងវាទេ ដោយពេលនោះគាត់ប្រាប់ថាអោយយកទៅអោយបងគាត់នៅចាំនៅសាលារៀនកាណានចាំទទួល ពេលនោះ ខ្ញុំបាទបានជិះយកថ្នាំទៅអោយមនុស្សប្រុសម្នាក់នោះ ពេលទៅដល់ខ្ញុំបាទបានហុយកញ្ចប់នោះទៅអោយគេ ហើយគេហុយលុយអោយមកខ្ញុំបាទចំនួន៥០០០០រៀល រួចពេលខ្ញុំបាទបានទទួលលុយរួច ខ្ញុំបាទបានជិះម៉ូតូត្រលប់មកក្រោយវិញដើម្បីមកយកថ្នាំពីឈ្មោះ សៅ តែមិនទាន់មកជួបឈ្មោះ សៅ ផងមកដល់ពាក់កណ្តាលផ្លូវនៅកែងស៊ីម៉ាក់ ក៏ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង ។

ស.ឆៈ ខ្ញុំបាទធ្លាប់ទិញថ្នាំពីឈ្មោះសៅ នេះបានចំនួន០៥ដងមកហើយ ។

ស.ឆៈ ខ្ញុំបាទមិនធ្លាប់បានចែកចាយ និងលក់ដូរថ្នាំញៀននេះពីមុនមកទេ ។

ស.ឆៈ សមត្ថកិច្ចចាប់ឃាត់ខ្លួនខ្ញុំបាទមិនបានដកហូតអ្វីពីខ្ញុំបាទទេ ។ ខ្ញុំបាទមិនទទួលស្គាល់ថ្នាំញៀនចំនួន០១កញ្ចប់ និង ទូរសព្ទចំនួន០២គ្រឿងនេះទេ មិនមែនជារបស់ខ្ញុំបាទទេ ជារបស់ឈ្មោះ ។

ស.ឆៈ ខ្ញុំបាទមិនស្គាល់ឈ្មោះ ប ,ឈ្មោះ ឈ្មោះ ,ឈ្មោះ ,ឈ្មោះ មឿន ផារ៉ុត នោះទេ ។

ស.ឆ៖ ថ្នាំញៀនដែលខ្ញុំបាទបានទិញមក គឺខ្ញុំបាទបានយកមកជក់តែម្នាក់ឯងប៉ុណ្ណោះ ។ខ្ញុំបាទធ្លាប់បានជាប់ពន្ធនាគារចំនួន០២ខែ ពីបទ៖ ប្រើប្រាស់ដោយខុសច្បាប់នូវសារជាតុញៀន ។

ចម្លើយខ្ញុំអស់តែប៉ុណ្ណេះ។

ឈប់សួរ បានអានឲ្យស្តាប់ សាមីខ្លួនឆ្លើយថាបានត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខា និងផ្តិតស្រាមដៃជាមួយយើង។

អ្នកឆ្លើយ | ក្រឡាបញ្ជី | ព្រះរាជអាជ្ញារង

**ឧបសម្ព័ន្ធទី២**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង**

**ផែនការងារប្រឆាំងគ្រឿងញៀន**

**ការិយាល័យប្រឆាំងគ្រឿងញៀន**

**កំណត់ហេតុស្តាប់ចម្លើយ**

នៅ ............ ឆ្នាំ ............

ខែ ............ ថ្ងៃទី ............ វេលាម៉ោង ............ នាទី

យើង ............ ជាមន្ត្រីនគរបាលយុត្តិធម៌

ឋានៈ ............

បានតាមដានស៊ើបអង្កេតក្នុងករណី: ............

............

ជំនួយការដោយ លោក ............ ឋានៈ ............

ចូលរួមដោយ លោក:

១/ លោក ............ ឋានៈ ............

២/ លោក ............ ឋានៈ ............

៣/ លោក ............ ឋានៈ ............

៤/ លោក ............ ឋានៈ ............

៥/ លោក ............ ឋានៈ ............

យើងបាននាំខ្លួនឈ្មោះ ............

ដែលត្រូវបានឃាត់ខ្លួន ក្នុងករណី ............

មកចំពោះមុខយើង ដែលបានឆ្លើយឲ្យយើងដូចខាងក្រោម:

**អំពីអត្តសញ្ញាណ ជនសង្ស័យត្រូវស្តាប់ចម្លើយ**



១-គោត្តនាម-នាម ............ ភេទ ............ អាយុ 17 ឆ្នាំ

ឈ្មោះជាអក្សរឡាតាំង ............ ហៅក្រៅ ............

-ជនជាតិ ............ សញ្ជាតិ ............ ថ្ងៃ/ខែ/ឆ្នាំកំណើត ............

-ស្រុកកំណើតភូមិ ............ ឃុំ ............

ស្រុក ............ ខេត្ត ............

-ទីលំនៅបច្ចុប្បន្នភូមិ ............ ឃុំ/សង្កាត់ ............

ស្រុក/ខណ្ឌ ............ ខេត្ត/ក្រុង ............

-អត្តសញ្ញាណបណ្ណលេខ: ............ ចុះថ្ងៃទី ............ ផ្តល់នៅ ............

-លិខិតឆ្លងដែនលេខ: ............ ចុះថ្ងៃទី ............ ផ្តល់នៅ ............

-មុខរបរ ............ កំរិតវប្បធម៌ ............ ប្រើប្រាស់ទូរស័ព្ទលេខ: ............

-ប្តី/ប្រពន្ធឈ្មោះ: ............

-ឪពុកឈ្មោះ: ............ អាយុ 41 ឆ្នាំ មុខរបរ ............

-ម្តាយឈ្មោះ: ............ អាយុ 41 ឆ្នាំ មុខរបរ ............

-ទោសពីមុន ............

-ប្រវត្តិសកម្មភាព ............

[illegible]

[illegible]

កំណត់ហេតុនេះ បានធ្វើចប់សព្វគ្រប់នៅថ្ងៃ/ខែ/ឆ្នាំដដែល វេលាម៉ោង 17h និង 00 នាទី បានអានសារឡើងវិញ ដោយសាមីខ្លួនឯង ឬ ដោយមន្ត្រីនគរបាលយុត្តិធម៌ បញ្ជាក់អះអាងថាពិតជាត្រឹមត្រូវ និង យល់ព្រមផ្តិតមេដៃស្តាំ ទុកជាភស្តុតាងដូចខាងក្រោម ។

**អ្នកចូលរួម** | **ជំនួយការ** | **មន្ត្រីនគរបាលយុត្តិធម៌**

ជនដែលត្រូវបានឃាត់ខ្លួន

(ស្នាមមេដៃស្តាំ និង ឈ្មោះ)

# ឧបសម្ព័ន្ធទី៣

17 07.05.2019

សាលាដំបូងខេត្តកំពង់ឆ្នាំង
បប
លេខ 1029
ថ្ងៃទី 06.05.2019
ម៉ោង ជ៧ព្រឹក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យប្តឹងសុំឲ្យមោឃភាពកំណត់ហេតុស្រង់ចម្លើយ**

ខ្ញុំបាទមេធាវី សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ ៨១២ ជាមេធាវីចាត់តាំងឲ្យការពារសិទ្ធិអនីតិជនឈ្មោះ យុ ១៧ឆ្នាំ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៧៤ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង។ ទូរស័ព្ទលេខៈ

**<u>សូមគោរពជូន</u>**

**ឯកឧត្តមប្រធានសភាស៊ើបសួរនៃសាលាឧទ្ធរណ៍**

**<u>កម្មវត្ថុ:</u>** ប្តឹងសុំអោយសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ទុកជាមោឃនូវកំណត់ហេតុស្រង់ចម្លើយឈ្មោះ អាយុ ១៧ឆ្នាំ នៅថ្ងៃទីដប់ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង។

**<u>យោង:</u>** -កំណត់ហេតុស្រង់ចម្លើយឈ្មោះ អាយុ ១៧ឆ្នាំ នៅថ្ងៃទីដប់ ខែកុម្ភៈ ឆ្នាំ២០១៩។
-មាត្រា ២៥២ មាត្រា ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។
-មាត្រា ២២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយស សូមជម្រាបជូន**ឯកឧត្តមប្រធានសភាស៊ើបសួរ**មេត្តាជ្រាបថា តាមចម្លើយរបស់ឈ្មោះ ជាអនីតិជនអាយុ ១៧ឆ្នាំ នៅចំពោះមុខចៅក្រមស៊ើបសួរថា គាត់សុំបដិសេធចម្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដោយហេតុថា ប៉ូលីសបានវ៉ៃគាត់ និងបង្ខំគាត់ឲ្យឆ្លើយ។

បើពិនិត្យលើកំណត់ហេតុស្រង់ចម្លើយឈ្មោះ អាយុ ១៧ឆ្នាំ នៅថ្ងៃទីដប់ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង ឃើញថា ពុំមានវត្តមានរបស់មេធាវី ឬអាណាព្យាបាលរបស់គាត់ឡើយ។

មាត្រា ២២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រង់កថាខណ្ឌទី២ និងទី១០ ចែងថាៈ

កថាខណ្ឌទី២៖ ការស្តាប់ចម្លើយត្រូវប្រព្រឹត្តដោយមានវត្តមានរបស់មេធាវី ដោយប្រើប្រាស់នីតិវិធីកុមារមេត្រីមានលក្ខណៈជាឯកជន និងជាការសម្ងាត់។

កថាខណ្ឌទី១០៖ វិធានដែលបានបញ្ញត្តិនៅក្នុងមាត្រានេះមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេ នឹងនាំឲ្យមានមោឃភាពនៃនីតិវិធី។

ការស្តាប់ចម្លើយឈ្មោះ ដែលជាអនីតិជនអាយុ ១៧ឆ្នាំ របស់ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង ខាងលើនេះ មិនគោរពតាមស្មារតីមាត្រា ២២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនទេ។ ដូច្នេះកំណត់ហេតុស្រង់ចម្លើយឈ្មោះ អាយុ ១៧ឆ្នាំ នៅថ្ងៃទីដប់ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ការិយាល័យព្រហ្មទណ្ឌកំរិតស្រាល នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង ត្រូវទុកជាមោឃៈ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម**ឯកឧត្តមប្រធាន**មេត្តាពិនិត្យ និងសម្រេចអំពើពាក្យប្តឹងសុំរបស់ខ្ញុំបាទ តាមនីតិវិធីច្បាប់ ដោយក្តីអនុគ្រោះ។

សូម**ឯកឧត្តមប្រធានសភាស៊ើបសួរ**មេត្តាទទួលនូវការគោរពដ៏ស្មោះ អំពីខ្ញុំបាទ៕

*ធ្វើនៅកំពង់ឆ្នាំង, ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩*

**ហត្ថលេខា និងត្រា**

<u>ចម្លងជូនៈ</u>

-លោក **អ៊ុំ ចាន់ថន** ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ឆ្នាំង

*"ដើម្បីជូនជាព័ត៌មាន"*

**ក្រុមមេធាវីការពារសិទ្ធិ**

**RIGHTS DEFENSE LAWYERS**

លេខ ៦១២-០១៩០៦

ថ្ងៃច័ន្ទ ១៣រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក.ពស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៩

## ពាក្យសុំមោឃភាពនៃនីតិវិធី

ខ្ញុំមេធាវី ៖ អត្តលេខ ៦១២ មានការិយាល័យក្រុមមេធាវី **ការពារសិទ្ធិ**(RDG) ស្ថិតនៅអគារលេខ ៦១ ផ្លូវលេខ ៦០៦ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាអ្នក...ការពារក្តីឲ្យឈ្មោះ .

សាលាដំបូង... ទទួលថ្ងៃទី 02 AUG 2019 លេខ 3118 ម៉ោង 10

**សូមគោរពជូន**

**ឯកឧត្តម ប្រធានសាលាឧទ្ធរណ៍**

**កម្មវត្ថុ** សំណើសុំមោឃភាពឯកសាររបស់មន្ត្រីនគរបាលយុត្តិធម៌ មានដូចជា ៖

១-កំណត់ហេតុស្តីពីការឃាត់ខ្លួន ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១០៩ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ ។

២-កំណត់ហេតុសរុប នៃការឃាត់ខ្លួន ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១០៩ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ ។

៣-កំណត់ហេតុស្រង់ចម្លើយ ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១០៩ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ ។

**យោង** -ច្បាប់ស្តីអំពីលក្ខន្តិកៈមេធាវី ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម០៨៩៥/០៦ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ១៩៩៥។

-ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២៥៣ ។

-ពាក្យសុំពឹងពាក់មេធាវី ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០១៩ របស់ឈ្មោះ ប៊ុន យ៉េង ស្នើសុំ ឲ្យប្តឹងសុំមោឃភាពនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ ។

សេចក្តីដូចមានខ្លឹមសារក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ សូមជម្រាបជូនលោកចៅក្រម មេត្តាជ្រាបថា ឈ្មោះ ត្រូវបានតំណាងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ បើកការស៊ើបសួរលើអង្គហេតុ រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ កាលពីខែកុម្ភៈ ឆ្នាំ២០១៩ ដូចមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ លេខ ១១៨៥ អយយ/១៩ ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១៩ (ឯកសារក្នុងសំណុំរឿង) ។

-តាមការចោទប្រកាន់ខាងលើនេះ នៅក្នុងដំណាក់ស៊ើបអង្កេតបឋមរបស់តំណាងអយ្យការ កូនក្តីខ្ញុំ បានឆ្លើយថា ខ្លួនសុំបដិសេធចោលចម្លើយនៅនគរបាលនៃអធិការដ្ឋាននគរបាលក្រុងព្រះសីហនុ ដោយសារនៅពេលសាកសួរនោះ សមត្ថកិច្ចបានសម្លុតឲ្យរូបខ្លួនឆ្លើយ ។

Scanned with CamScanner

-ម្យ៉ាងទៀត កូនក្តីខ្ញុំ មានមុខរបរលក់បបរគ្រៀងដឹកតាមម៉ូតូយកទៅលក់ នៅឆ្ងាយពីផ្ទះ ដល់មាត់សមុទ្រអូរត្រេះ នៅរៀងរាល់ថ្ងៃចេញពីផ្ទះតាំងពីម៉ោងប្រាំ ឬប្រាំមួយព្រឹក រហូតដល់ម៉ោងប្រាំបួនជាង ឬដប់ ទើបមកដល់ផ្ទះវិញ ហើយមិនដែលបានទៅចូលព្រៃកាប់អុសយកមកដុតទេ ព្រោះ ម្ចាស់ផ្ទះជួល អ្នកដែលជួលបន្ទប់នីមួយៗ គេមិនឲ្យដុតអុសទេ គឺរាល់ពេលចំអិនបបរ ឬដាំបាយ ស្លសម្លរ នោះ គឺត្រូវដុតឲ្យងជាច្រើនឆ្នាំមកហើយ ពិសេសទៅទៀតនោះ នៅជុំវិញផ្ទះជួល ឬឆ្ងាយពីផ្ទះជួល ស្ថិតនៅភូមិ៥ ក្រុមទី១២ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ពុំមានព្រៃសំរាប់កាប់អុស ឬអ៊ុចស្គាកាយដី ឡើយ ព្រោះថា ក្នុងភូមិ៥ នេះ សុទ្ធតែផ្ទះទាំងអស់ ។

-តាមសេចក្តីបញ្ជាក់ការពិតរបស់កូនក្តីខ្ញុំ បានបញ្ជាក់ថា ខ្លួនមិនបានរំលោភសេពសន្ថវៈលើឈ្មោះ ទ ចំពោះចម្លើយនៅនគរបាលយុត្តិធម៌ កូនក្តីខ្ញុំ បានបដិសេធចោលហើយ ព្រោះថា ឈ្មោះ សម្លុតឲ្យឆ្លើយដូចក្នុងកំណត់ហេតុស្រង់ចម្លើយ ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១៩ ដោយគាត់ថា ឲ្យទទួលស្គាល់ការរំលោភសេពសន្ថវៈលើឈ្មោះ គេនឹងឲ្យទៅផ្ទះវិញ ដោយគ្រាន់តែប្រគល់ប្រាក់ចំនួន ៨០០ដុល្លាអាមេរិក ឲ្យម្តាយជនរងគ្រោះ ពេលនោះ បានសួរប្រពន្ធឈ្មោះ ថា ត្រូវឆ្លើយដូចប៉ូលីសប្រាប់ឲ្យឆ្លើយ ឬយ៉ាងណា ពេលនោះ ប្រពន្ធខ្លួនថា ឲ្យឆ្លើយដូចប៉ូលីសប្រាប់ទៅ និងសុខចិត្តប្រគល់ប្រាក់ចំនួន ៨០០ដុល្លាអាមេរិក ឲ្យម្តាយជនរងគ្រោះ ។

-បទល្មើសនេះ មិនមែនជាបទល្មើសជាក់ស្តែងឡើយ គឺមិនដឹងថា មន្ត្រីនគរបាលយុត្តិធម៌ធ្វើការឃាត់ខ្លួនកូនក្តីខ្ញុំបែបណាទេ ព្រោះថា តាតមាត្រា ៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា ក្នុងករណីរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ដែលអាចចេញបញ្ជាឲ្យចូលខ្លួនបាន ការបញ្ជាឲ្យចូលខ្លួនេះ ត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ មានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង ។ ប៉ុន្តែផ្ទុយមកវិញ ឯកសារក្នុងសំណុំរឿងដែលមន្ត្រីនគរបាល បានកសាងឡើង ដើម្បីចាប់ឃាត់ខ្លួនកូនក្តីខ្ញុំនោះ ពុំឃើញមានឯកសារណាមួយដូចមានចែងក្នុងមាត្រា ៩៤នេះ ឡើយ ។ តាមមាត្រា ៩៤ នេះ «កថាខណ្ឌទី២ដល់ទី៥ នៃមាត្រា៩៣ (កំណត់ហេតុលើកាស្តាប់ចម្លើយ)នៃក្រមនេះ ត្រូវយកមកអនុវត្ត» ដូច្នេះ កំណត់ហេតុស្រង់ចម្លើយ ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១៩ នោះ ត្រូវយមកអនុវត្តដូចមាត្រា ៩៤នេះដែរ ម្យ៉ាងទៀត «កំណត់ហេតុស្រង់ចម្លើយ» ដែលមន្ត្រីនគរបាលយុត្តិធម៌កសាងឡើងនោះ ពុំមែនជាប្រភេទកំណតុហេតុ ដូចមានចែងក្នុងមាត្រា ៩៣ ឡើយ ។

-តាមខ្លឹមសារកំណត់ហេតុស្តីពីការឃាត់ខ្លួន ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១០៩ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ នោះ ពុំមានការយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា តាមមាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឡើយ គឺគ្រាន់តែជូនដំណឹងដល់ព្រះរាជអាជ្ញាប៉ុណ្ណោះ(កំណត់ហេតុសរុបនៃការឃាត់ខ្លួននៃចំណុចទី៨) តែពុំឃើញមានឯកសារណាមួយជាលាយលក្ខណ៍អក្សរ បានយល់ព្រមពីព្រះរាជអាជ្ញា ថាឲ្យធ្វើការឃាត់ខ្លួនឈ្មោះ នាះទេ ហើយក្នុងខ្លឹមសារកំណត់ហេតុនេះដដែល ត្រង់ចំណុចទី៧ មន្ត្រីនគរបាលយុត្តិធម៌ ក៏ពុំបានប្រាប់

CS Scanned with

ឲ្យកូនក្តីខ្ញុំ ដឹងអំពីសិទ្ធិពឹងពាក់មេធាវីដូចមានចែងតាមមាត្រា៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឡើយ ពិសេសទៅទៀតនោះ ក្នុងកំណត់ហេតុស្តីពីការឃាត់ខ្លួន ខាងលើ ដែលមានចែងក្នុងមាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងយ៉ាងច្បាស់ថា «...មន្ត្រីនគរបាល ប្រាប់សិទ្ធិដល់សាមីខ្លួនឲ្យបាន ដឹងផងដែរ អំពីសិទ្ធិដែលមានចែងនៅមាត្រា ៩៨(ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន)» ។

-តាមកំណត់ហេតុស្រង់ចម្លើយ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០១៩ បានបញ្ជាក់ថា «បន្តការស៊ើបអង្កេតនៅក្នុងក្របខណ្ឌតតិយុត្តិនៃបទល្មើស(១)ជាក់ស្តែង» ប៉ុន្តែតាមការអះអាងរបស់ឈ្មោះ ត្រូវជាម្តាយរបស់ឈ្មោះ ក្នុងកំណត់ហេតុស្តាប់ការបំភ្លឺ ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០១៩ បញ្ជាក់ថា អង្គហេតុរំលោភសេពសន្ថវៈតាំងពីពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៩ ទើបកូនស្រី កាន ទំ ប្រាប់ថាឈ្មោះ . រាប់រំលោភច្រើនដង (កំណត់ហេតុបណ្តឹង)។ ដូច្នេះ តាមអង្គហេតុនេះ ឃើញថា មិនមែនជាបទល្មើសជាក់ស្តែងទេ ព្រោះថា តាមមាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា «ថិរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង មិនអាចលើសពី ប្រាំពីថ្ងៃ គិតពីថ្ងៃប្រព្រឹត្តិបទល្មើស ។ កិចស៊ើបអង្កេត ត្រូវប្រព្រឹត្តទៅជាប់ជានិច្ចនៅក្នុងថិរវេលានេះ ។ ការស៊ើបអង្កេត មិនបានបញ្ចប់ក្នុងរយៈពេល ប្រាំពីរថ្ងៃនោះទេ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្នើសុំយោបល់ព្រះរាជអាជ្ញា» ។ ក្នុងន័យនេះ ឃើញថា បទល្មើសកើតឡើងតាំងពីពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោងដប់ប្រាំ ទើបមន្ត្រីនគរបាលយុត្តិធម៌ ចាប់ផ្តើបស៊ើបអង្កេតបឋម ជាហេតុធ្វើឲ្យការស៊ើបអង្កេតនេះ មិនបានគោរពវិធានក្នុងមាត្រា ១០៦ ខាងលើ ឡើយ ។

ដូច្នេះ ឯកសារដូចបានរៀបរាប់ខាងលើ ដែលមន្ត្រីនគរបាលយុត្តិធម៌ បានកសាងរៀបចំ ដើម្បីចាប់ឃាត់ខ្លួនកូនក្តីខ្ញុំនេះ ឃើញថា ជាឯកសារខុសទៅនឹងមាត្រា ៩៣ , មាត្រា ៩៤ , មាត្រា ៩៦(កថាខណ្ឌទី៣) , មាត្រា ៩៧ ,មាត្រា ៩៨ មាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

សូមសំណូមពរ សុំតុលាការ មេត្តា មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិតាមមាត្រា ១០៩ នូវឯកសារដូចបានរៀបរាប់ខាងលើ ដោយក្តីអនុគ្រោះ ។

សូមលោកប្រធាន មេត្តា ទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

មេធាវីសេខា និងត្រា

Scanned with CamScanner

# ឧបសម្ព័ន្ធទី៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

លេខ

**សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ**

សូមជម្រាបជូន

**លោក ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ឆ្នាំង**

**កម្មវត្ថុ៖** សំណើចាត់បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ មកសភាស៊ើបសួរសាលាឧទ្ធរណ៍ ។

**យោង៖** ពាក្យសុំចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ របស់លោកកទិត ឡាយ មេធាវីការពារសិទ្ធិអោយជនត្រូវចោទឈ្មោះ ដែលបានដាក់ពាក្យផ្ទាល់មកសភាស៊ើបសួរ សុំមោឃកម្មលើកំណត់ហេតុស្តាប់ចម្លើយ និងកំណត់ហេតុសួរចម្លើយរបស់ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្ត និងអយ្យការ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបលោកជ្រាបថា លោក ជាមេធាវីការពារសិទ្ធិអោយជនត្រូវចោទឈ្មោះ ៖ ភេទប្រុស អាយុ ១៧ឆ្នាំ បានដាក់ពាក្យបណ្តឹងផ្ទាល់មកសភាស៊ើបសួរ ដែលមានខ្លឹមសារថា លើពិនិត្យលើកំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ និងកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ របស់កូនក្តីខ្ញុំបាទ នៅការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្ត និងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ដោយហេតុថា ពុំមានមេធាវី ឬ អាណាព្យាបាលឡើយ ។

យោងតាមបញ្ញត្តិមាត្រា ២៥៣ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ និងដើម្បីសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ មានមូលដ្ឋានពិនិត្យ សម្រេចលើបណ្តឹងសុំនេះបាន សូមលោកចាត់បញ្ជូនសំណុំរឿងព្រហ្មទណ្ឌ ដូចចែងក្នុងកម្មវត្ថុខាងលើ មកសភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ក្នុងរយៈពេលដ៏ខ្លីតាមការគួរ ។

សូមលោកទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ថ្ងៃច័ន្ទ ៦រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩

**បានឃើញ**

**ប្រធានសភាស៊ើបសួរ**

**ក្រឡាបញ្ជី**

**ឧបសម្ព័ន្ធទី៥**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

លេខ [illegible] ឧ.១៩

# ដីកាបញ្ជូន

ផ្ញើជូន: លោកប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង

| រាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|
| ១.លិខិតលេខ [illegible] រប.ឧ.១៩ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការចាត់បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ [illegible] ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ មកសភាសៀបសួរសាលាឧទ្ធរណ៍ភ្នំពេញ ។ | ០១ច្បាប់ | ដើម្បីចាត់ការតាមនីតិវិធី |
| សរុប | ០១ច្បាប់ | |

ថ្ងៃច័ន្ទ ៦រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩

ជ. ប្រធានសាលាឧទ្ធរណ៍

# ឧបសម្ព័ន្ធទី៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង

ខេត្តកំពង់ឆ្នាំង

លេខ : ............ / ១៩

## ដីកាបញ្ជូន

គោរពជូន ឯកឧត្តមអគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍

| ល.រ | រាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| 01 | សំណុំរឿង [illegible] ចុះថ្ងៃទី 02.07.2019 [illegible] 456 [illegible] 19 ចុះថ្ងៃទី 02.07.2019 របស់សាលាដំបូង [illegible] | 01សំណុំ | ដើម្បីជូនជាសមត្ថកិច្ច ។ |
| | សរុប | 01សំណុំ | |

ថ្ងៃ អង្គារ ៥ រោច ខែ ស្រាពណ៍ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅកំពង់ឆ្នាំង ថ្ងៃទី 20 ខែ 08 ឆ្នាំ 2019

ប្រធានលេខាធិការដ្ឋានរដ្ឋបាល

**ឧសម្ព័ន្ធទី៧**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការអម
សាលាឧទ្ធរណ៍

# សៀវភៅចុះបណ្ដឹង

# សភាស៊ើបសួរ

# ឧបសម្ព័ន្ធទី៨

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

## ដីកាចាត់តាំង

## ប្រធានសភាស៊ើបសួរ

សភាស៊ើបសួរ

លេខ:

ចាត់ឯកឧត្តម/លោក ............................ ជាចៅក្រម

ឲ្យពិនិត្យអំពី អង្គហេតុ នីតិវិធី ទម្រង់ និង គតិច្បាប់ នៃសំណុំរឿង សភាស៊ើបសួរលេខ: ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ របស់ សាលាឧទ្ធរណ៍ ដោយធ្វើរបាយការណ៍ប្រាប់ឲ្យដឹងអំពីអង្គហេតុ សេចក្តីសម្រេច សំអាងហេតុរបស់សាលាដំបូង **ខេត្តកំពង់ឆ្នាំង** អំពីទម្រង់ និងគតិច្បាប់ ហើយធ្វើសេចក្តីសន្និដ្ឋានចង្អុលប្រាប់នូវនីតិវិធី ដែលសាលាឧទ្ធរណ៍ត្រូវ អនុវត្ត។

ថ្ងៃច័ន្ទ ១១រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩

**ប្រធាន**

ផ្លូវសម្តេចសុធារស សាលាឧទ្ធរណ៍-មហាអយ្យការ (ទល់មុខព្រះបរមរាជវាំង ក្នុងបរិវេណក្រសួងយុត្តិធម៌)

# ឧបសម្ព័ន្ធទី៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍-មហាអយ្យការ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះទី៧
សូមគោរពជូន
ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

**កម្មវត្ថុ៖** ស្នើចាត់តំណាងមហាអយ្យការចូលរួមសវនាការ

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមជ្រាបថា នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៩ វេលាម៉ោង ១៤:០០ នាទី "បន្ទប់លេខ ៣" សាលាឧទ្ធរណ៍បើកធ្វើការពិភាក្សាដេញដោលលើសំណុំរឿង **សតាស៊ើបសួរ** ចំនួន ២ រឿង មានដូចខាងក្រោម៖

| ល.រ | លេខសំណុំរឿង | ឈ្មោះត្រូវចោទ | ឈ្មោះដើមបណ្តឹង | កម្មវត្ថុបទល្មើស | ក្រុមប្រឹក្សា | មកពី | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ០១ | ២៦៣/២៦.០៨.២០១៩ | -- | | ប្តឹងឧទ្ធរណ៍របស់ជនរងគ្រោះ សុំមោឃកម្មកំណត់ហេតុស្តាប់ចំលើយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩។ ពីបទ: ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន (ករណីមិនរាងចាល)។ | លោក<br>លោក<br>លោក | កំពង់ឆ្នាំង | រឿងថ្មី |
| ០២ | ២៦១/២៦.០៨.២០១៩ | ... | | ប្តឹងឧទ្ធរណ៍របស់មេធាវី សម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ៥៦៥២ ក ដ.ព.ស ចុះថ្ងៃទី០៥.០៨.២០១៩។ ពីបទ: លួចមានស្ថានទម្ងន់ទោស (គាស់ទម្លុះទម្លាយ)។ | | ភ្នំពេញ | រឿងថ្មី |

ថ្ងៃអង្គារ ១២រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សាលាឧទ្ធរណ៍, ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩
ប្រធានក្រុមប្រឹក្សា

ចាត់លោក.................... ............ចូលរួម
**អគ្គព្រះរាជអាជ្ញា**

27/8/19

# ឧសម្ព័ន្ធទី១០

សាលាឧទ្ធរណ៍-មហាអយ្យការ

សំណុំរឿងសតាសុីបសួរ

លេខ:

ចុះថ្ងៃទី១០-០២-២០២០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**<u>ដីកាកោះហៅជនត្រូវចោទឲ្យចូលសវនាការ</u>**

យើង.. ....... ព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍ ។

បានឃើញ (ដីកា ឬសាលដីកាបញ្ជូន) របស់តុលាការសាលាឧទ្ធរណ៍ ។

បង្គាប់មកឈ្មោះ ភេទប្រុស អាយុ ៦៧ឆ្នាំ ជនជាតិខ្មែរ កើតនៅឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ, ទីលំនៅផ្ទះលេខ ផ្លូវ ភូមិ ណ្ឌឬ វ រាជធានីភ្នំពេញ ឱ្យចូលមកសាលាឧទ្ធរណ៍នាថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០២០ វេលាម៉ោង ៨,០០ព្រឹក នៅបន្ទប់ សវនាការទី៣ ជាកំណត់ ដើម្បីជំនុំជម្រះពីបទ: រំលោភទំនុកចិត្ត ។

ដោយក្រុមប្រឹក្សាជំនុំជម្រះទី VII ដូចខាងក្រោម៖

១- លោក ជាប្រធាន

២- លោក ជាចៅក្រមប្រឹក្សា

៣-លោក ជាចៅក្រមប្រឹក្សា

- ក្រឡាបញ្ជី លោក

ថ្ងៃព្រហស្បតិ៍ ១២រោច ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០២០

(<u>ជនជាប់ចោទអាចអមដោយមេធាវី</u>)

# ឧបសម្ព័ន្ធទី១១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ភ្នំពេញ, ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩

មហាអយ្យការ

សាលាឧទ្ធរណ៍

លេខ.....

**អគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍**

**ជម្រាបមក**

**ឯកឧត្តម អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ**

**កម្មវត្ថុៈ** សំណើសុំចាត់ឱ្យនាំជនត្រូវចោទមកសវនាការ ។

**យោងៈ** សំណុំរឿងសើ៊បសួរលេខ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ។

ជាប់ចោទពីបទ: **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន( ករណីមិនរាងចាល )** ប្រព្រឹត្តនៅចំណុចភូមិចំការតាម៉ៅ ឃុំស្រែថ្មី ស្រុករលាប្អៀ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**សូមចាត់ឱ្យនាំជនត្រូវចោទ:**

១-ឈ្មោះ ភេទប្រុស អាយុ ១៧ ឆ្នាំ ជនជាតិខ្មែរ ឃុំខ្លួននៅថ្ងៃទី ៣០-០៦-២០១៩ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦៤០/១៩ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩ នៅមន្ទីរឃុំឃាំងខេត្តកំពង់ឆ្នាំង។

**នៅកាន់សាលាឧទ្ធរណ៍ នៅពេលបើកសវនាការជំនុំជម្រះនៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៩ វេលាម៉ោង ១៤:00 នាទី នៅបន្ទប់សវនាការទី III ជាកំណត់ ។**

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារសិទ្ធិជនត្រូវចោទ លើកំណត់ហេតុចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ របស់ការិយាល័យប្រឆាំងគ្រឿងញៀន និងកំណត់ហេតុស្តាប់ចំលើយចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។

ដោយក្រុមប្រឹក្សាជំនុំជម្រះទី VII មានសមាសភាពដូចខាងក្រោម៖

- លោក ប្រធានក្រុមប្រឹក្សា
- លោក ចៅក្រុមប្រឹក្សា
- លោក ចៅក្រុមប្រឹក្សា
- លោក ក្រឡាបញ្ជី

29/08/2019

នៅពេលចប់សវនាការហើយ ត្រូវនាំជនត្រូវចោទខាងលើត្រឡប់ទៅពន្ធនាគារវិញ ដើម្បីបន្តអនុវត្តសេចក្តីសម្រេចរបស់តុលាការពីមុន បើគ្មានសេចក្តីសម្រេចថ្មីទៀតទេ ។

**ជ.អគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍**

**ព្រះរាជអាជ្ញា**

# ឧបសម្ព័ន្ធទី១២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍-មហាអយ្យការ

សំណុំរឿងសភាស៊ើបសួរលេខ
ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩

## ដីកាកោះដើមបណ្តឹងរដ្ឋប្បវេណី

យើង ព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍។

បង្គាប់មកឈ្មោះ ភេទប្រុស អាយុ ៤១ឆ្នាំ ជាដើមបណ្តឹងរដ្ឋប្បវេណី មានទីលំនៅបច្ចុប្បន្ន នៅផ្ទះលេខ១៥៣១ ផ្លូវជាតិលេខ២ ភូមិទួលរកា សង្កាត់ចាក់អង្រែ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

**ឱ្យចូលមកសាលាឧទ្ធរណ៍ នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៩ វេលាម៉ោង ១៤:00 នាទី នៅបន្ទប់សវនាការទី III ជាកំណត់។**

ដើម្បីជំនុំជម្រះលើ បណ្តឹងឧទ្ធរណ៍របស់របស់មេធាវីការពារសិទ្ធិជនត្រូវចោទ នឹងដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ: ៥៦៥២ ភ ដ.ព.ស ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

ជាប់ចោទពីបទ: **លួចមានស្ថានទម្ងន់ទោស** (**គាស់ទម្លុះទម្លាយ**) ប្រព្រឹត្តនៅចំណុចក្នុងរោងចក្រសាញលីងថេកស្តាយខប ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា **២៥៧** នៃក្រមព្រហ្មទណ្ឌ។

ដោយក្រុមប្រឹក្សាជំនុំជម្រះទី VII មានសមាសភាពដូចខាងក្រោម៖

- លោក ប្រធានក្រុមប្រឹក្សា
- លោក ចៅក្រមប្រឹក្សា
- លោក ចៅក្រមប្រឹក្សា
- លោក ក្រឡាបញ្ជី

ថ្ងៃពុធ ១៣រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ភ្នំពេញ, ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩
**ព្រះរាជអាជ្ញា**

បុគ្គលពាក់ព័ន្ធត្រូវបានកោះហៅក្នុងឋានៈជាជនរងគ្រោះ
**(ការមិនចូលបង្ហាញខ្លួននៅពេលសវនាការ, ការមិនព្រមឆ្លើយឱ្យពត៌មានក្នុងឋានៈជាសាក្សី ឬការឆ្លើយឱ្យពត៌មានក្លែងក្លាយ ត្រូវផ្តន្ទាទោសតាមច្បាប់)**

# ឧបសម្ព័ន្ធទី១៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍-មហាអយ្យការ

សំណុំរឿងសភាស៊ើបសួរលេខ

ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩

## ដីកាកោះដើមបណ្ដឹងរដ្ឋប្បវេណី

យើង ព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍។

បង្គាប់មកឈ្មោះ កទប្រុស អាយុ ៤១ឆ្នាំ ជាដើមបណ្ដឹងរដ្ឋប្បវេណី មានទីលំនៅបច្ចុប្បន្ន នៅផ្ទះលេខ១៥៣១ ផ្លូវជាតិលេខ២ ភូមិទួលរកា សង្កាត់ចាក់អង្រែ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

**ឱ្យចូលមកសាលាឧទ្ធរណ៍ នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៩ វេលាម៉ោង ១៤:00 នាទី នៅបន្ទប់សវនាការទី III ជាកំណត់។**

ដើម្បីជំនុំជម្រះលើ បណ្ដឹងឧទ្ធរណ៍របស់របស់មេធាវីការពារសិទ្ធិជនត្រូវចោទ នឹងដីកាសម្រេចមិនព្រមដោះលែងឲ្យនៅក្រៅឃុំលេខ: ៥៦៥២ ភ ដ.ព.ស ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

ជាប់ចោទពីបទ: **លួចមានស្ថានទម្ងន់ទោស (គាស់ទម្លុះទម្លាយ)** ប្រព្រឹត្តនៅចំណុចក្នុងរោងចក្រសាញលីងថេកស្ដាយខប ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ២៥៧ នៃក្រមព្រហ្មទណ្ឌ។

ដោយក្រុមប្រឹក្សាជំនុំជម្រះទី VII មានសមាសភាពដូចខាងក្រោម៖

- លោក ប្រធានក្រុមប្រឹក្សា
- លោក ចៅក្រមប្រឹក្សា
- លោក ចៅក្រមប្រឹក្សា
- លោក ក្រឡាបញ្ជី

ថ្ងៃពុធ ១៣រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ភ្នំពេញ, ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩

**ព្រះរាជអាជ្ញា**

បុគ្គលពាក់ព័ន្ធត្រូវបានកោះហៅក្នុងឋានៈជាជនរងគ្រោះ

(ការមិនចូលបង្ហាញខ្លួននៅពេលសវនាការ, ការមិនព្រមឆ្លើយឲ្យពត៌មានក្នុងឋានៈជាសាក្សី ឬការឆ្លើយឲ្យពត៌មានក្លែងក្លាយ ត្រូវផ្ដន្ទាទោសតាមច្បាប់)

# ឧបសម្ព័ន្ធទី១៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

លេខ........រ.ប.ឧ / ១២

សាលាដំបូងរាជធានីភ្នំពេញ
ចូល

**សូមគោរពជូន**

ឯកឧត្តម ប្រធានសាលាដំបូងរាជធានីភ្នំពេញ

**កម្មវត្ថុ** : សំណើសុំលោក ជាអ្នកបកប្រែភាសារ ចិន ០១ រូប ។

**យោង** : សំណុំរឿងព្រហ្មទណ្ឌលេខ ៩៣៤ ចុះថ្ងៃទី ០៨-១១-២០១០ របស់សាលាឧទ្ធរណ៍ ។

**តបកម្មវត្ថុ និង យោងខាងលើ** សាលាឧទ្ធរណ៍ សូមជំរាបជូនឯកឧត្តមប្រធានមេត្តាជ្រាបថា : សាលាឧទ្ធរណ៍បានទទួលចាត់ការសំណុំរឿងព្រហ្មទណ្ឌលេខ ៩៣៤ ចុះថ្ងៃទី ០៨-១១-២០១០ ដែលមាន**ជនជាប់ចោទឈ្មោះ** ជាជនជាតិ ចិន ជាប់ចោទពីបទ ប្លន់ និងសមគំនិត ប្រព្រឹត្តនៅភូមិត្រពាំងគង ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១៤-១០-២០០៩ ។ ដោយជនជាប់ចោទទាំងពីររូបនេះ ពុំមានលទ្ធភាពក្នុងការស្វែងរកអ្នកបកប្រែដោយខ្លួនឯង ។

អាស្រ័យហេតុនេះសូម ឯកឧត្តមប្រធាន ចាត់អ្នកបកប្រែលោក ដើម្បីចូលរួមធ្វើ**ការ**បកប្រែឱ្យជនជាប់ចោទ ដែលបើកសវនាការប្រព្រឹត្តនៅថ្ងៃទី ០២ ខែមិនា ឆ្នាំ ២០១២ វេលាម៉ោង **៨.០០**ព្រឹក នៅសាលសវនាការបន្ទប់ទី ១ សាលាឧទ្ធរណ៍ ដោយអនុគ្រោះ ។

សូមឯកឧត្តម ទទួលនូវការគោរពរាប់អានដ៏ ជ្រាលជ្រៅអំពី នាងខ្ញុំ ។

សាលាឧទ្ធរណ៍ ថ្ងៃទី........ខែ........ឆ្នាំ ២០១២

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

ផ្លូវសម្តេចសុធារស សាលាឧទ្ធរណ៍-មហាអយ្យការ (ទល់មុខព្រះបរមរាជវាំង ក្នុងបរិវេណក្រសួងយុត្តិធម៌

ព្រះរាជាណាចក្រកម្ពុជា **ឧបសម្ព័ន្ធទី១៥**

សាលាឧទ្ធរណ៍ភ្នំពេញ ជាតិ សាសនា ព្រះមហាក្សត្រ

**បានឃើញ** កំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ នៅនគរបាលយុត្តិធម៌ខេត្តកំពង់ឆ្នាំងៈ

១-ថ្នាំញៀន ០១ កញ្ចប់ ទម្ងន់ ០,២៦g

២-ទូរស័ព្ទដៃ ០១ គ្រឿង ម៉ាក NOKAI ពណ៌ខ្មៅ

**៣.ចម្លើយបំភ្លឺរបស់គូភាគី**

បានឃើញ ចម្លើយរបស់ជនត្រូវចោទឈ្មោះ បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ថាៈ ខ្លួនធ្លាប់ជក់ថ្នាំញៀន រយៈពេល ០២ ខែក្រោយពីខ្លួនចេញពីពន្ធនាគារដោយសាររឿងប្រើប្រាស់គ្រឿងញៀនខុសច្បាប់ក្នុងឆ្នាំ២០១៨ ហើយចំពោះថ្នាំញៀន ដែលខ្លួនជក់គឺខ្លួនទិញពីឈ្មោះ សៅ ភេទប្រុស អាយុប្រហែល២១ឆ្នាំ មានទីលំនៅភូមិចុងកោះ សង្កាត់ផ្សារឆ្នាំង ក្រុង/ខេត្តកំពង់ឆ្នាំង ខ្លួនធ្លាប់ទិញថ្នាំញៀនពីគាត់បានចំនួន ០៥ ដង ខ្លួនទិញថ្នាំញៀនម្តងៗ ០១ កញ្ចប់ តំលៃ ០២ម៉ឺនរៀល ពេលបានថ្នាំញៀនហើយខ្លួនយកទៅជក់តែម្នាក់ឯងនៅផ្ទះជួល ។ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល១១ និង២០នាទី ខ្លួនបានតេទូរស័ព្ទទៅរកទិញថ្នាំញៀនពីឈ្មោះ ចំនួន ០១ កញ្ចប់ តំលៃ ០២ម៉ឺនរៀល ហើយគាត់បានប្រាប់ឲ្យខ្លួនមកយកថ្នាំញៀន នៅមុំផ្លូវកែងភ្នំសន្ទុច ពេលខ្លួនមកដល់កន្លែងណាត់ គាត់បានប្រើខ្លួនឲ្យយកថ្នាំញៀន ចំនួន ០១ កញ្ចប់ដាក់ក្នុងកញ្ចប់នំយកទៅឲ្យម៉ូយដែលទិញថ្នាំញៀនពីគាត់នៅមុំផ្លូវកែងមុខសាលាកាណាន ពេលខ្លួនយកថ្នាំញៀនទៅឲ្យម៉ូយរួចពេលត្រឡប់មកវិញក៏ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួន ហើយបញ្ជូនមកកាន់ស្នងការខេត្តកំពង់ឆ្នាំងតែម្តង ។

បានឃើញ ចម្លើយរបស់ជនត្រូវចោទឈ្មោះ បានឆ្លើយនៅអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំងថាៈ កាលពីថ្ងៃកើតហេតុខ្លួនមិនចាំថ្ងៃទេ គឺនៅថ្ងៃនោះខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ដោយបានតេតាមទូរស័ព្ទទិញថ្នាំចំនួន ០១ កញ្ចប់ ក្នុងតម្លៃ ២០០០០រៀល ដោយខ្លួនបានណាត់ជួបឈ្មោះ សៅ នៅផ្លូវកែងសន្ទុច ពេលទៅជួបឈ្មោះ ឈ្មោះ ...មិនទាន់បានឲ្យថ្នាំញៀនមកខ្លួននោះទេ គឺគាត់បានប្រើខ្លួនឲ្យយកកញ្ចប់នំមួយកញ្ចប់ និងទូរស័ព្ទចំនួន ០២ គ្រឿង ម៉ាកអ៊ិនចុចពិលទាំងពីរ ទៅឲ្យបងវាតែខ្លួនមិនស្គាល់បងវាទេ ដោយពេលនោះគាត់ប្រាប់ថាឲ្យយកទៅឲ្យបងគាត់នៅចាំនៅសាលារៀនកាណានចាំទទួល ពេលនោះខ្លួនបានជិះយកថ្នាំទៅឲ្យមនុស្សប្រុសម្នាក់នោះ ពេលទៅដល់ខ្លួនបានហុយកញ្ចប់នោះទៅឲ្យគេ ហើយគេហុយលុយឲ្យមកខ្លួនចំនួន៥០០០០រៀល រួចពេលខ្លួនបានទទួលលុយរួច ខ្លួនបានជិះម៉ូតូត្រលប់មកក្រោយវិញ ដើម្បីមកយកថ្នាំពីឈ្មោះ តែមិនទាន់មកជួបឈ្មោះ ផងមកដល់ពាក់កណ្តាលផ្លូវនៅកែងស៊ីម៉ាក់ ក៏ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង ។ ខ្លួនធ្លាប់ទិញថ្នាំពីឈ្មោ នេះបានចំនួន ០៥ ដងមកហើយ ។ ខ្លួនមិនធ្លាប់បានចែកចាយ និងលក់ដូរថ្នាំញៀននេះពីមុនមកទេ ។ សមត្ថកិច្ចចាប់ឃាត់ខ្លួន ខ្លួនមិនបានដកហូតអ្វីពីខ្លួនទេ ។ ខ្លួនមិនទទួលស្គាល់ថ្នាំញៀនចំនួន ០១ កញ្ចប់ និងទូរស័ព្ទចំនួន ០២ គ្រឿងនេះទេ មិនមែនជារបស់ខ្លួនទេ ជារបស់ឈ្មោះ សៅ ។ ខ្លួនមិនស្គាល់ឈ្មោះ នៅ សំអុល, ឈ្មោះ ឈ្មោះ ឈ្មោះ ឈ្មោះ នោះទេ ។ ថ្នាំញៀនដែលខ្លួនបានទិញមក គឺខ្លួនបានយកមកជក់តែម្នាក់ឯងប៉ុណ្ណោះ ។ ខ្លួនធ្លាប់បានជាប់ពន្ធនាគារចំនួន ០២ ខែ ពីបទៈប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។

**៤. ឯកសារពាក់ព័ន្ធបណ្តឹងអាយតាក**

**បានឃើញ** កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ នៅនគរបាលយុត្តិធម៌ខេត្តកំពង់ឆ្នាំង ។

**បានឃើញ** កំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ នៅនគរបាលយុត្តិធម៌ខេត្តកំពង់ឆ្នាំង:

១-ថ្នាំញៀន ០១ កញ្ចប់ ទម្ងន់ ០,២៦g

២-ទូរស័ព្ទដៃ ០១ គ្រឿង ម៉ាក NOKAI ពណ៌ខ្មៅ

**៣.ចម្លើយបំភ្លឺរបស់គូភាគី**

បានឃើញ ចម្លើយរបស់ជនត្រូវចោទឈ្មោះ បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ថា: ខ្លួនធ្លាប់ជក់ថ្នាំញៀន រយៈពេល ០២ ខែក្រោយពីខ្លួនចេញពីពន្ធនាគារដោយសាររឿងប្រើប្រាស់គ្រឿងញៀនខុសច្បាប់ក្នុងឆ្នាំ២០១៨ ហើយចំពោះថ្នាំញៀន ដែលខ្លួនជក់គឺខ្លួនទិញពីឈ្មោះ សៅ ភេទប្រុស អាយុប្រហែល២១ឆ្នាំ មានទីលំនៅភូមិចុងកោះ សង្កាត់ផ្សារឆ្នាំង ក្រុង/ខេត្តកំពង់ឆ្នាំង ខ្លួនធ្លាប់ទិញថ្នាំញៀនពីគាត់បានចំនួន ០៥ ដង ខ្លួនទិញថ្នាំញៀនម្តងៗ ០១ កញ្ចប់ តំលៃ ០២ម៉ឺនរៀល ពេលបានថ្នាំញៀនហើយខ្លួនយកទៅជក់តែម្នាក់ឯងនៅផ្ទះជួល ។ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល១១និង២០នាទី ខ្លួនបានតេទូរស័ព្ទទៅរកទិញថ្នាំញៀនពីឈ្មោះ ចំនួន ០១ កញ្ចប់ តំលៃ ០២ម៉ឺនរៀល ហើយគាត់បានប្រាប់ឲ្យខ្លួនមកយកថ្នាំញៀន នៅមុំផ្លូវកែងភ្នំសន្ទូច ពេលខ្លួនមកដល់កន្លែងណាត់ គាត់បានប្រើខ្លួនឲ្យយកថ្នាំញៀន ចំនួន ០១ កញ្ចប់ដាក់ក្នុងកញ្ចប់នំយកទៅឲ្យម៉ូយដែលទិញថ្នាំញៀនពីគាត់នៅមុំផ្លូវកែងមុខសាលាកាណាន ពេលខ្លួនយកថ្នាំញៀនទៅឲ្យម៉ូយរួចពេលត្រឡប់មកវិញក៏ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួន ហើយបញ្ជូនមកកាន់ស្នងការខេត្តកំពង់ឆ្នាំងតែម្តង ។

បានឃើញ ចម្លើយរបស់ជនត្រូវចោទឈ្មោះ បានឆ្លើយនៅអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំងថា: កាលពីថ្ងៃកើតហេតុខ្លួនមិនចាំថ្ងៃទេ គឺនៅថ្ងៃនោះខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ដោយបានតេតាមទូរស័ព្ទទិញថ្នាំចំនួន ០១ កញ្ចប់ ក្នុងតម្លៃ ២០០០០រៀល ដោយខ្លួនបានណាតជួបឈ្មោះ សៅ នៅផ្លូវកែងសន្ទូច ពេលទៅជួបឈ្មោះ ឈ្មោះ ... មិនទាន់បានឲ្យថ្នាំញៀនមកខ្លួននោះទេ គឺគាត់បានប្រើខ្លួនឲ្យយកកញ្ចប់នំមួយកញ្ចប់ និងទូរស័ព្ទចំនួន ០២ គ្រឿង ម៉ាកអ៊ិនចុចពិលទាំងពីរ ទៅឲ្យបងវា តែខ្លួនមិនស្គាល់បងវាទេ ដោយពេលនោះគាត់ប្រាប់ថាឲ្យយកទៅឲ្យបងគាត់នៅចាំនៅសាលារៀនកាណានចាំទទួល ពេលនោះខ្លួនបានជិះយកថ្នាំទៅឲ្យមនុស្សប្រុសម្នាក់នោះ ពេលទៅដល់ខ្លួនបានហុយកញ្ចប់នោះទៅឲ្យគេ ហើយគេហុយលុយឲ្យមកខ្លួនចំនួន៥០០០០រៀល រួចពេលខ្លួនបានទទួលលុយរួច ខ្លួនបានជិះម៉ូតូត្រលប់មកក្រោយវិញ ដើម្បីមកយកថ្នាំពីឈ្មោះ តែមិនទាន់មកជួបឈ្មោះ ផងមកដល់ពាក់កណ្តាលផ្លូវនៅកែងស៊ីម៉ាក់ ក៏ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង ។ ខ្លួនធ្លាប់ទិញថ្នាំពីឈ្មោះ នេះបានចំនួន ០៥ ដងមកហើយ ។ ខ្លួនមិនធ្លាប់បានចែកចាយ និងលក់ដូរថ្នាំញៀននេះពីមុនមកទេ ។ សមត្ថកិច្ចចាប់ឃាត់ខ្លួន ខ្លួនមិនបានដកហូតអ្វីពីខ្លួនទេ ។ ខ្លួនមិនទទួលស្គាល់ថ្នាំញៀនចំនួន ០១ កញ្ចប់ និងទូរស័ព្ទចំនួន ០២ គ្រឿងនេះទេ មិនមែនជារបស់ខ្លួនទេ ជារបស់ឈ្មោះ សៅ ។ ខ្លួនមិនស្គាល់ឈ្មោះ នៅ សំអុល, ឈ្មោះ ឈ្មោះ ឈ្មោះ ឈ្មោះ នោះទេ ។ ថ្នាំញៀនដែលខ្លួនបានទិញមក គឺខ្លួនបានយកមកជក់តែម្នាក់ឯងប៉ុណ្ណោះ ។ ខ្លួនធ្លាប់បានជាប់ពន្ធនាគារចំនួន ០២ ខែ ពីបទៈប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។

**៤. ឯកសារពាក់ព័ន្ធបណ្តឹងរោយភាព**

**បានឃើញ** កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ នៅនគរបាលយុត្តិធម៌ខេត្តកំពង់ឆ្នាំង ។

**បានឃើញ** កំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ នៅអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ។

**៥.ទម្រង់នៃបណ្តឹងមោឃភាព**

**បានឃើញ** ពាក្យបណ្តឹងសុំមោឃកម្មកំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ របស់មេធាវី ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ សុំមកសភាស៊ើបសួរ ។

បណ្តឹងមោឃភាពនេះ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងតាមមាត្រា ៥៥ និងមាត្រា ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**៦. សេចក្តីសន្និដ្ឋាន**

# ឧបសម្ព័ន្ធទី១៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មហាអយ្យការអមសាលាឧទ្ធរណ៍**
សំណុំរឿងសភាស៊ើបសួរលេខ ១៧០
ចុះថ្ងៃទី ០៨-០៦-២០១៩

<u>សេចក្ដីសន្និដ្ឋាន</u>

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ១១-០២-២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ។

តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង សម្រេចចោទប្រកាន់លើ ៖

-ជនត្រូវចោទឈ្មោះ ហៅ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ ទីកន្លែងកំណើតនៅភូមិ ឃុំ ក្រុង ខេ ង មានទីលំនៅបច្ចុប្បន្ននៅភូមិសន្ទួច ស្រុក ខេត្ត ឪពុកឈ្មោះ (រ) ម្ដាយឈ្មោះ ) នៅលីវ ជាអនីតិជន ទោសពីមុនត្រូវបានព្យួរការអនុវត្តទោស ។(ដីកាឃុំខ្លួនលេខៈ១០៣/១៩ ចុះថ្ងៃទី១១-២-២០១៩)

**<u>ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទៈ</u>** អំពើលួច(កាច់កម៉្តូ) ប្រព្រឹត្តនៅចំណុចភូមិត្រពាំងចិក្សា សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

<u>-សហដើមបណ្ដឹងរដ្ឋប្បវេណីៈ</u>

១.ឈ្មោះ ភេទប្រុស អាយុ ៤២ឆ្នាំ មានអាសយដ្ឋាននៅភូមិកង្កែប ឃុំប្រឡាក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។

២.ឈ្មោះ ភេទប្រុស អាយុ ២២ឆ្នាំ មានអាសយដ្ឋាននៅភូមិស្រែព្រីង សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

**<u>អំពីអង្គហេតុ</u>**

កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩ នៅវេលាម៉ោង១៤និង៣០នាទី នៅចំណុចមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ឆ្នាំង និងនៅម៉ោង១៥និង០០នាទី នៅចំណុចមុខផ្ទះឈ្មោះ ស្ថិតនៅក្នុងភូមិត្រពាំងចិក្សា សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កើតមានករណី អំពើលួច (កាច់កម៉្តូ) ដែលបង្កឡើងដោយ ១.ឈ្មោះ ២.ឈ្មោះ ៣.ឈ្មោះ , ៤.ឈ្មោះ និង៥.ឈ្មោះ ។ បានកាច់កម៉្តូរបស់ជនរងគ្រោះឈ្មោះ ភេទប្រុស និងឈ្មោះ ៀន ភេទប្រុស បណ្ដាលឲ្យបាត់បង់ម៉ូតូចំនួន០២គ្រឿង ។ (ឯកសារលេខ ២១/២)

**<u>អំពីលទ្ធផលអង្កេត</u>**

-បានឃើញចម្លើយរបស់ជនត្រូវចោទឈ្មោះ ។ បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលអយ្យការប្រហែលគ្នា ថាៈ ខ្លួនសុំបដិសេធចម្លើយរបស់ខ្លួននៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ទាំងស្រុង ព្រោះខ្លួនមិនដែលបានចូលរួមកាច់កម៉្តូជាមួយឈ្មោះ ឈ្មោះ ។ និងឈ្មោះ ខ្លួនស្គាល់ឈ្មោះ ព្រោះវាជាបងប្អូនជីដូនមួយរបស់ខ្លួន ហើយពីរនាក់ទៀតខ្លួនស្គាល់ដែរ តែពុំច្បាស់ទេ គឺធ្លាប់ដើរលេងជាមួយគ្នាកាលរៀននៅវិទ្យាល័យសុរាម្រិត ។ ខ្លួនមិន

បានដឹងថាពួកវាជាអ្នកកាច់កម៉ូតូគេយកទៅលក់ទេ ។ ខ្លួនធ្លាប់ជក់ថ្នាំញៀនដែរ តែបានឈប់រយៈពេលពីរខែហើយ ព្រោះរៀនភាសាកូរ៉េ ដើម្បីទៅធ្វើការនៅកូរ៉េ ។ កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩ ខ្លួនមិនជួបឈ្មោះ ឈ្មោះ ន និងឈ្មោះ នោះទេ គឺខ្លួនបានទៅរៀនកូរ៉េនៅសាលារៀនបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយចូលរៀននៅម៉ោង៧ព្រឹក និងចេញវិញម៉ោង១១ព្រឹក ។ បន្ទាប់ពីចេញមកម្តាយខ្លួនបានមកឌុបខ្លួនទៅផ្ទះជួលវិញ ហើយខ្លួនបានដេកថ្ងៃដល់ម៉ោង៣រសៀល និងអង្គុយជជែកលេងជាមួយអ្នកជិតខាង ហើយម៉ោង៤កន្លះក៏ងូតទឹកមករៀន ព្រោះត្រូវចូលរៀនម៉ោង៥ល្ងាច បន្ទាប់មកម្តាយខ្លួនក៏ឌុបខ្លួនទៅរៀន ហើយម៉ោង៧យប់ម្តាយខ្លួនបានចាំយកខ្លួនទៅផ្ទះជួលវិញ ។ នៅម៉ោងប្រហែល៨យប់ឈ្មោះ ន បានមកផឹកស៊ីនៅបន្ទប់ជួលរបស់ខ្លួន បន្ទាប់មកឈ្មោះ បានគេហៅមិត្តភក្តិវាមកផឹកដែរមានឈ្មោះ ភេទប្រុស អាយុ ២០ឆ្នាំ, ឈ្មោះ ម៉ាប់ ភេទប្រុស អាយុ ១៩ឆ្នាំ, ឈ្មោះ ប្រុស អាយុ ២១ឆ្នាំ ។ លុះដល់ម៉ោង៨និង៣០នាទី ខ្លួនបានប្រាប់ឈ្មោះ សេង គឹមហាន និងអ្នកដទៃ ឲ្យទៅផ្ទះវិញ ព្រោះខ្លាចម្តាយមកឃើញ ហើយគេក៏ទៅផ្ទះអស់ ។ លុះស្អែកឡើងថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង៤ ជិត៥ល្ងាច ក៏មានសមត្ថកិច្ចចូលមកឃាត់ខ្លួន ហើយក៏នាំខ្លួនទៅចាប់ឈ្មោះ ។ ពីមុនមកខ្លួនមិនដែលធ្លាប់បានចូលរួមសកម្មភាពកាច់កម៉ូតូជាមួយអ្នកទាំងបីនាក់នេះទេ ។ សុំឲ្យតុលាការដោះលែងខ្លួនឲ្យមានសេរីភាពវិញផង ។ (ឯកសារលេខ ២១/១, ៤០/៣)

-បានឃើញចម្លើយរបស់ជនត្រូវចោទឈ្មោះ នឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា: កាលពីថ្ងៃទី០៥-២-២០១៩ វេលាម៉ោង៨ព្រឹក ឈ្មោះ បានទូរស័ព្ទមកខ្លួនឲ្យទៅផ្ទះជួលនៅម្តុំរោងចក្រស្វាយជ្រុំ ដើម្បីផឹកស៊ី ពេលខ្លួនទៅដល់ផ្ទះរបស់ឈ្មោះ ខ្លួនឃើញមានគ្នាចំនួន៦នាក់ តែខ្លួនមិនស្គាល់ឈ្មោះពួកគេទេ ទាល់តែសួរឈ្មោះ ទើបស្គាល់ ហើយឈ្មោះ បងប្អូនជីដូនមួយរបស់ខ្លួន ។ ខ្លួនបានចូលផឹកស៊ីជាមួយពួកគេបានប្រហែលកន្លះម៉ោង ខ្លួនក៏ជិះម៉ូតូទៅផ្ទះវិញ ។ លុះដល់ថ្ងៃទី០៦-២-២០១៩ វេលាម៉ោងប្រហែល៣ល្ងាច ឈ្មោះ ជាអ៊ំ បានមកប្រាប់ខ្លួនថាសមត្ថកិច្ចចាប់ឈ្មោះ ដោយគេចោទថា លួចម៉ូតូគេ ។ លុះដល់ថ្ងៃទី០៧-២-២០១៩ វេលាម៉ោងប្រហែល៦ព្រឹក សមត្ថកិច្ចមកចាប់ខ្លួនដល់ផ្ទះខ្លួនតែម្តង ដោយចោទថា ខ្លួនលួចម៉ូតូគេ ។ (ឯ.ល ៣៧/១)

**ឯកសារពាក់ព័ន្ធ**

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ២៨៣/០១៩ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ។ (ឯកសារលេខ ២១/២)

-បានឃើញ ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ: ១០៣/១៩ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ឆ្នាំង ។ (ឯកសារលេខ ៣០/២)

-បានឃើញ ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ: ១០៣/១៩ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ឆ្នាំង ។ (ឯកសារលេខ ៣១/២)

-បានឃើញ លិខិតជូនព័ត៌មានអំពីការបិទការស៊ើបសួរដល់តំណាងអយ្យការលេខ: ២៣៤/១៩ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ របស់របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ឆ្នាំង។ (ឯ.ល ៤២)

**អំពីសេចក្តីសម្រេចរបស់តុលាការ**

**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ: ៨៧០ អ.យ/២០១៩ របស់អយ្យការអមសាលាដំបូង

ខេត្តកំពង់ឆ្នាំង បានសម្រេចថា៖

<u>ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេច៖</u>

បញ្ជូនជនត្រូវចោទ:

១.  (មានសាវតាជាតិខាងលើ)

២.  ន (មានសាវតាជាតិខាងលើ)

បន្តនីតិវិធីស៊ើបសួរលើឈ្មោះ៖

៣  មានសាវតាជាតិខាងលើ)

៤.  (មានសាវតាជាតិខាងលើ)

៥.  (មានសាវតាជាតិខាងលើ)

និងសំណុំរឿងព្រហ្មទណ្ឌលេខ: ៣៤ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ ទៅជំនុំជម្រះ ។

**<u>អំពីឧទ្ធរណ៍ច្បាប់</u>**

** បានឃើញ** ពាក្យសុំ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ របស់លោក  ។ មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ  ដែលបានដាក់ពាក្យប្តឹងផ្ទាល់មកសភាស៊ើបសួរ សុំមោឃកម្មលើកំណត់ហេតុស្រង់ចម្លើយរបស់ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង ។

បណ្តឹងនេះធ្វើឡើង [illegible] 253 .............................. នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

[illegible] 2019

[illegible]
26/06/19

[illegible]

# ឧបសម្ព័ន្ធទី១៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

## សេចក្ដីសម្រេច
## ស្ដីពី
## ការកំណត់ភារកិច្ចដល់មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន

លេខ: ៩៧ របឧ/២០១៨

## ប្រធានសាលាឧទ្ធរណ៍

-បានឃើញ បញ្ញត្តិមាត្រា ២៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ស្ដីពីគោលការណ៍នៃការបញ្ជូនដោយឥន្ទានុសិទ្ធ។

-បានឃើញ ប្រកាសលេខ: ៣០ កយប្រក.០៧ ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌ ស្ដីពី មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា។

-បានឃើញ សេចក្ដីសម្រេចលេខ: ៨៩ របឧ.២០១៦ ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ ស្ដីពីការកំណត់ភារកិច្ចដល់មន្ត្រីទទួលបន្ទុកការបញ្ជូន។

-យោង តាមការចាំបាច់ដើម្បីអនុវត្តកិច្ចការបញ្ជូនដីកាកោះ សេចក្ដីសម្រេចផ្សេងៗរបស់សាលាឧទ្ធរណ៍ ដើម្បីសម្រួលដល់ដំណើរការនីតិវិធីឱ្យបានសមស្រប។

## សម្រេច

១-ចាត់មន្ត្រីគ្រប់គ្រងរដ្ឋបាល និងមន្ត្រីជាប់កិច្ចសន្យា ឱ្យទទួលបន្ទុកគ្រប់គ្រង និងធ្វើការបញ្ជូនដីកាកោះ សេចក្ដីសម្រេចនៅសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ដូចខាងក្រោម៖

| | | |
|---|---|---|
| -លោក វិរោចន៍ សុវណ្ណឌី | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | ជាប្រធាន |
| -លោក កុច ភិរុណ | មន្ត្រីគ្រប់គ្រងរដ្ឋបាល | អនុប្រធាន |
| -លោក សែម រចនា | មន្ត្រីក្រមការ | អនុប្រធាន |
| -លោក ទ្រី ប៊ុយ៉ា | មន្ត្រីគ្រប់គ្រងរដ្ឋបាល | សមាជិក |
| -លោក ទូន ច័ន្ទកុសល្យ | មន្ត្រីក្រមការ | សមាជិក |
| -លោក អោក ថាត | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |
| -លោក យ៉ាន់ តន់ | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |
| -លោក ចៅ ធារ៉ី | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |
| -លោក ជុំ សារុធកក្កដា | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |

២-មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនទាំងអស់ មានភារកិច្ច៖

-ប្រធានទទួលបន្ទុកកិច្ចការបញ្ជូន ទទួលបន្ទុកកិច្ចការងាររួម សម្របសម្រួលបែងចែកភារកិច្ចដល់អនុប្រធាន និងសមាជិក និងទទួលការងារផ្សេងៗទៀតថ្នាក់ដឹកនាំប្រគល់ឱ្យ ។

-អនុប្រធាន ត្រូវចុះបញ្ជីដីកាកោះ លិខិតជូនដំណឹង សេចក្ដីសម្រេចដែលបានទទួលពីក្រឡាបញ្ជី ទៅក្នុងសៀវភៅកត់ត្រាដីកាកោះជំនុំជម្រះ និងក្នុងសៀវភៅជូនដំណឹងសេចក្ដីសម្រេចឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

-ពេលដីកាបង្គាប់ ត្រូវចុះបញ្ជី រួចហើយប្រគល់ឱ្យក្រឡាបញ្ជីទទួលបន្ទុកចុះហត្ថលេខាទទួលឱ្យបានឆាប់បំផុត។ ក្នុងករណីក្រឡាបញ្ជីទទួលបន្ទុកអវត្តមាន ត្រូវបញ្ជូនដោយផ្ទាល់ដល់ចៅក្រមទទួលបន្ទុក។

-អនុប្រធានត្រូវជួយចាត់ចែងការងារ ដោយសហការជាមួយប្រធានជាប់ជាប្រចាំ និងទទួលការងារជំនួសប្រធាន តាមការប្រគល់សិទ្ធិពីប្រធាន និងមានសិទ្ធិចាត់ចែងការងារជំនួសប្រធាន ពេលប្រធានមានធុរៈ។

-ប្រធាន អនុប្រធាន និងសមាជិកទាំងអស់នៃមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន មានសិទ្ធិចុះហត្ថលេខាលើរបាយការណ៍បញ្ជូន លិខិតជូនដំណឹងពីសេចក្តីសម្រេច ដែលខ្លួនបានបញ្ជូនឱ្យភាគី ដើម្បីបញ្ជាក់អំពីការប្រគល់ទទួលឱ្យបានច្បាស់លាស់ និង ត្រឹមត្រូវ។

៣-មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនទាំងអស់ ត្រូវពាក់ស្លាកបិតរូបថតជាសំគាល់ និងត្រូវមានសីលធម៌ការងារស្អាតស្អំ គោរពវិន័យការងារ។ រាល់កិច្ចការបញ្ជូនដីកា លិខិតជូនដំណឹង ឬ សេចក្តីសម្រេច ត្រូវអនុវត្តឱ្យបានទាន់ពេលវេលា មិនត្រូវយកទុកចោល ឬ រង់ចាំទទួលលាភសក្ការៈពីភាគីណាមួយឡើយ។

៤-គ្រប់សកម្មភាពនៃការអនុវត្តកិច្ចការបញ្ជូន មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនទាំងអស់ ត្រូវស្ថិតនៅក្រោមការដឹកនាំបច្ចេកទេស និងការគ្រប់គ្រង ពីអគ្គលេខាធិការរដ្ឋបាលសាលាឧទ្ធរណ៍ដោយផ្ទាល់ ក្នុងករណីចាំបាច់មានបញ្ហាដែលពិបាកដោះស្រាយ ជាមួយក្រឡាបញ្ជី ចៅក្រម ឬស្ថាប័នពាក់ព័ន្ធ ត្រូវជូនដំណឹងមកថ្នាក់ដឹកនាំជាបន្ទាន់ ។

៥-ក្នុងករណីអនុវត្តភារកិច្ចមិនគោរពតាមវិធានការនៃការបញ្ជូន ឬមានចេតនាឱ្យកិច្ចដំណើរការនីតិវិធីមានការខកខាន នឹងត្រូវទទួលវិន័យតាមផ្លូវរដ្ឋបាល ហើយបើមានកំហុសធ្ងន់ធ្ងរដូចជាការបន្លំ ហត្ថលេខា ឬស្នាមមេដៃនៃភាគីទទួល នឹងត្រូវទទួលទោសតាមច្បាប់។

៦-គ្រប់សេចក្តីសម្រេច របស់សាលាឧទ្ធរណ៍ ស្តីពីការកំណត់ភារកិច្ចដល់មន្ត្រីទទួលបន្ទុកការបញ្ជូនពីមុនៗមកត្រូវទុកជានិរាករណ៍ ។

សេចក្តីសម្រេចនេះ មានអានុភាពអនុវត្ត ចាប់ពីចុះហត្ថលេខាតទៅ។

<u>**ចម្លងជូន៖**</u>
-ចៅក្រម, ព្រះរាជអាជ្ញា
-ក្រឡាបញ្ជី
"ដើម្បីជ្រាប"
-សាមីខ្លួន
"ដើម្បីអនុវត្ត"
-ឯកសារ

ថ្ងៃពុធ ៣កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០១៨
ប្រធានសាលាឧទ្ធរណ៍

យូ_ប៊ុនឡេង

# ឧបសម្ព័ន្ធទី១៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
ស្រួបទោស
លេខៈ ,
ចុះថ្ងៃទី ២៥-១០-២០១៧
សាលដីកា
១
ចុះថ្ងៃទី ២៧-០២-២០១៨

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

បង្កើតឡើង តាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើ តាមព្រះរាជក្រមលេខៈ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ -៧ -២០១៤ បានបើកសវនាការសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃអង្គារ ១៣កើត ខែផល្គុន ឆ្នាំរកា នព្វសក័ ព.ស.២៥៦១ នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ ដែលមានសមាសភាពដូចខាងក្រោមៈ

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក ជាប្រធាន
លោក ជាចៅក្រមប្រឹក្សា
លោក ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក ព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក

ដើម្បីជំនុំជម្រះលើបណ្តឹងសុំស្រួបទោស នៃសំណុំរឿងព្រហ្មទណ្ឌលេខៈ ចុះថ្ងៃទី២៥-១០-២០១៧ របស់សាលាឧទ្ធរណ៍ ដែលបានសុំអនុវត្តស្រួបទោសតាមសាលដីកាស្ថាពរលេខៈ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ របស់សាលាឧទ្ធរណ៍ និងសាលដីកាស្ថាពរលេខៈ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ របស់សាលាឧទ្ធរណ៍ ។

**កម្មវត្ថុៈ** ប្តឹងសុំអនុវត្តស្រួបទោសលើ

**-ទណ្ឌិតឈ្មោះ** ហៅ ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ មុខរបររត់ម៉ូតូឌុប កើតនៅភូមិរំម៉េង ឃុំលាស់ពង់ ស្រុកឈូក ខេត្តកំពត មានទីលំនៅភូមិរំម៉េង ឃុំលាស់ពង់ ស្រុកឈូក ខេត្តកំពត ឪពុកឈ្មោះ ) ម្តាយឈ្មោះ ស) មានប្រពន្ធឈ្មោះ ភាន កូន០៤នាក់ ទោសពីមុនគ្មាន។

**-បច្ចុប្បន្ន ទណ្ឌិតឈ្មោះ** " ហៅ កំពុងជាប់ឃុំឃាំងនៅមណ្ឌលអប់រំកែប្រែទី១ នៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ ។

**-បានឃើញ** សាលដីកាស្ថាពរលេខ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ឈ្មោះ " " ភេទប្រុស អាយុ ៤២ឆ្នាំ មានអាសយដ្ឋាននៅភូមិកង្កែប

ស្រុក...... ខេត្ត ។

២.ឈ្មោះ ភេទប្រុស អាយុ ២២ឆ្នាំ មានអាសយដ្ឋាននៅភូ បង្កាត់

ក្រុង ខេ...... ។

## ៦រឿងហេតុមានដូចតទៅ ៖

កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩ នៅវេលាម៉ោង១៤និង៣០នាទី នៅចំណុចមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ឆ្នាំង និងនៅម៉ោង១៥និង០០នាទី នៅចំណុចមុខផ្ទះឈ្មោះ ជ ស្ថិតនៅក្នុងភូមិត្រពាំងចិក្សា សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កើតមានករណី អំពើលួច (កាច់កម៉ូតូ) ដែលបង្កឡើងដោយ ១.ឈ្មោះ , ២.ឈ្មោះ , ៣.ឈ្មោះ ផាន់ណា, ៤.ឈ្មោះ និង៥.ឈ្មោះ បានកាច់កម៉ូតូរបស់ជនរងគ្រោះឈ្មោះ យ័ន្ត ម៉ៅ ភេទប្រុស និងឈ្មោះ ភេទប្រុស បណ្តាលឲ្យបាត់បង់ម៉ូតូចំនួន០២គ្រឿង ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ២៨៣/០១៩ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ។

**-បានឃើញ** ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខៈ ១០៣/១៩ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ឆ្នាំង ។

**-បានឃើញ** ដីកាបង្គាប់ឲ្យឃុំខ្លួនលេខៈ ១០៣/១៩ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ឆ្នាំង ។

**-បានឃើញ** លិខិតជូនព័ត៌មានអំពីការបិទការស៊ើបសួរដល់តំណាងអយ្យការលេខៈ ២៣៤/១៩ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ របស់របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ឆ្នាំង ។

**-បានឃើញ**ដីកាសន្និដ្ឋានស្ថាពរលេខៈ ៨៧០ អ.យ/២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង បានសម្រេចថា៖

<u>ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេច៖</u>

បញ្ជូនជនត្រូវចោទៈ

១. (មានសាវតាជាតិខាងលើ)

២ ានសាវតាជាតិខាងលើ)

បន្តនីតិវិធីស៊ើបសួរលើឈ្មោះ៖

៣. ានសាវតាជាតិខាងលើ)

៤ ានសាវតាជាតិខាងលើ)

៥. មានសាវតាជាតិខាងលើ)

និងសំណុំរឿងព្រហ្មទណ្ឌលេខៈ ៧៤ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ ទៅជំនុំជម្រះ ។

**-បានឃើញ** ពាក្យសុំ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ របស់លោក **មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ ដែលបានដាក់ពាក្យប្តឹងផ្ទាល់មកសភាស៊ើបសួរ សុំមោឃកម្មលើកំណត់ហេតុស្រង់ចម្លើយរបស់ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង ។**

-**បានឃើញ** របាយការណ៍សំណុំរឿងស៊ើបសួរលេខៈ ុះថ្ងៃទី០៤-៦-២០១៩ របស់ចៅក្រមរបាយការណ៍ នៃសាលាឧទ្ធរណ៍ ។

-**បានឃើញ** សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

**<u>នាពេលសវនាការ</u>**

-ជនត្រូវចោទឈ្មោះ (អវត្តមាន)

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ (អវត្តមាន)

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ អវត្តមាន)

-មេធាវីការពារឲ្យជនត្រូវចោទៈ ត្តមាន)

ប្រធានក្រុមប្រឹក្សាអានសង្ខេបអង្គហេតុ

**<u>សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ</u>**

នៅក្នុងសំណុំរឿងនេះ ពុំឃើញមានឯកសារសំបុត្រកំណើតរបស់ឈ្មោះ ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ពីអាយុ នោះឡើយ នាំឱ្យប៉ះពាល់ដល់នីតិវិធី ។ សូមក្រុមប្រឹក្សាពិចារណា និងសម្រេចតាមច្បាប់ ។

**<u>សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនត្រូវចោទ</u>**

កូនក្ដីខ្លួនបានឈប់រៀនតាំងពីឆ្នាំ២០១៥ នៅថ្នាក់ទី៨ E ដោយសារតែក្រុមគ្រួសាររបស់គាត់បែកបាក់គ្នា ។ យោងតាមកំណត់ហេតុនគរបាល រហូតដល់អយ្យការ និងចៅក្រមស៊ើបសួរ សុទ្ធតែដាក់អាយុ១៧ឆ្នាំ ទាំងអស់ និងសុំមោឃភាពលើកំណត់ហេតុស្រង់ចម្លើយរបស់ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាន នគរបាលខេត្តកំពង់ឆ្នាំង តាមពាក្យសុំ។ សូមក្រុមប្រឹក្សាសម្រេចមោឃភាពតាមពាក្យសុំ។

-ក្រោយពីបានស្ដាប់ការសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ការសន្និដ្ឋានរបស់មេធាវីការពារជនត្រូវចោទ

-ក្រោយពីបានពិភាក្សាពិចារណាត្រឹមត្រូវតាមច្បាប់

**<u>សភាស៊ើបសួរ</u>**

**<u>យល់ឃើញថា</u>**

-ពាក្យសុំចូលមកសភាស៊ើបសួរ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ របស់លោក មេធាវីការពារឲ្យជនត្រូវចោទឈ្មោះ សុំមោឃកម្មលើកំណត់ហេតុស្រង់ចម្លើយរបស់ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការនគរបាលខេត្តកំពង់ឆ្នាំង ធ្វើឡើងត្រឹមត្រូវតាមច្បាប់ សភាស៊ើបសួរអាចលើកយកមកជំនុំជម្រះបាន យោងតាមមាត្រា២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-ជនត្រូវចោទ ត្រូវបានដាក់ក្រោមការពិនិត្យពីបទៈ អំពើលួច(កាច់កម៉ូតូ) បទល្មើសដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

-តាមពាក្យបណ្ដឹង ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ របស់លោក មេធាវីការពារឲ្យជនត្រូវចោទឈ្មោះ បានប្ដឹងសុំឲ្យសភាស៊ើបសួរ ទុកជាមោឃៈនូវកំណត់ហេតុស្រង់ចម្លើយឈ្មោះ អាយុ ១៧ឆ្នាំ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ការិយាល័យព្រហ្មទណ្ឌកម្រិត

ស្រាលនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង ដោយពុំមានវត្តមានរបស់មេធាវី ឬ អាណាព្យាបាលឡើយ យោងតាមមាត្រា២២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រង់កថាខ័ណ្ឌ២ និងកថាខ័ណ្ឌ១០ ។

-តាមការពិនិត្យលើកំណត់ហេតុស្រង់ចម្លើយលើឈ្មោះ ហៅ អាយុ ១៧ឆ្នាំ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង ឃើញថា នៅក្នុងកំណត់ហេតុនេះ សមត្ថកិច្ចនគរបាលយុត្តិធម៌ពុំបានរកមេធាវី ឬ អាណាព្យាបាល ឬ ឪពុកម្តាយរបស់ជនសង្ស័យ មុននឹងសួរយកចម្លើយរបស់ជនសង្ស័យឡើយ ។ ករណីនេះជាការរំលោភលើមាត្រា១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលចែងអំពីអនីតិជន ត្រង់កថាខ័ណ្ឌ២ ចែងថាៈ វិធានដែលបានបញ្ញត្តិនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នេះទេ និងនាំឲ្យមានមោឃភាពនៃនីតិវិធី ។ ដូច្នេះ គប្បីក្រុមប្រឹក្សាពិចារណា និងសម្រេចតាមមាត្រា២៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលពាក្យសុំមោឃកម្ម ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ របស់លោកមេធាវី ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-ទុកជាមោឃចំពោះកំណត់ហេតុស្រង់ចម្លើយចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការនគរបាលខេត្តកំពង់ឆ្នាំង ។

៣-ដកកំណត់ហេតុស្រង់ចម្លើយចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការនគរបាលខេត្តកំពង់ឆ្នាំង ចេញពីសំណុំរឿង យកមកតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជី នៃសភាស៊ើបសួរ ។

៤-សាលដីកានេះ ជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ និងប្រកាសជាអសាធារណៈ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ ។

-បើកសិទ្ធិប្តឹងសាទុក្ខ តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| លោក | លោក ,លោក | លោក |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ ចន្ទ ៧កើត ខែ អាសាឍ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ក្រឡាបញ្ជី**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ ភ្នំពេញ

**សភាស៊ើបសួរ**
**សំណុំរឿងព្រហ្មទណ្ឌ**
លេខ:
ចុះថ្ងៃទី២៦-០៨-២០១៩
**សាលដីកាព្រហ្មទណ្ឌ**
លេខ
ចុះថ្ងៃទី០៦-០៩-២០១៩

សភាស៊ើបសួរបង្កើតឡើង តាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ បានបើកកិច្ចពិភាក្សាដេញដោលអសាធារណៈ នៅសាលសវនាការសាលាឧទ្ធរណ៍នាថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក ជាប្រធានក្រុមប្រឹក្សា

លោក ជាចៅក្រមប្រឹក្សា

លោក ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

ដើម្បីជំណើរការកិច្ចពិភាក្សាដេញដោលលើបណ្តឹងឧទ្ធរណ៍នៃរឿងស៊ើបសួរលេខ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ដែលមាន:

-ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិផ្សារឆ្នាំង សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ទីលំនៅបច្ចុប្បន្ននៅភូមិចុងកោះ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ ម្ដាយឈ្មោះ (ស) ប្រពន្ធឈ្មោះ ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារចំនួន ០២ ខែ។

មានមេធាវីឈ្មោះ ការពារសិទ្ធិឲ្យជនត្រូវចោទ ។

ចៅក្រមស៊ើបសួរដាក់ស្ថិតឲ្យនៅក្រោមការពិនិត្យពីបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន (ករណីមិនរាងចាល) ប្រព្រឹត្តនៅភូមិចំការតាម៉ៅ ឃុំស្រែថ្មី ស្រុករលាប្អៀ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**ការប្រព្រឹត្តរបស់ជនត្រូវចោទមានដូចតទៅ:**

កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ នៅវេលាម៉ោង១២និង០០នាទី នៅចំណុចភូមិចំការតាម៉ៅ ឃុំស្រែថ្មី ស្រុករលាប្អៀ ខេត្តកំពង់ឆ្នាំង កើតមានករណី ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលប្រព្រឹត្តឡើងដោយឈ្មោះ ព បានយកថ្នាំញៀនមកលក់ឲ្យកម្លាំងសមត្ថកិច្ចចំនួន ០១ កញ្ចប់ក្នុងតម្លៃ ៥០០០០រៀល ហើយត្រូវបានសមត្ថកិច្ចបានចាប់ឃាត់ខ្លួន និងដកហូតបានថ្នាំញៀនចំនួន ០១ កញ្ចប់ និងទូរស័ព្ទដៃចំនួន ០២ គ្រឿង។ អំពើប្រព្រឹត្តខាងលើជាបទល្មើស៖ ជួញដូរ

និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន (ករណីមិនរាងចាល) ប្រព្រឹត្តនៅភូមិចកាតោមោ ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដែលមានចែងតាមមាត្រា ៤០, ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**-បានឃើញ**: ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ១៤៤០/០១៩ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

បើកការស៊ើបសួរលើអង្គហេតុ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន (ករណីមិនរាងចាល) និងស្នើសុំៈ

-ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យលើៈ ឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិចុងកោះ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

-ដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្នលើឈ្មោះៈ ខាងលើ

**-បានឃើញ**: កំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ នៅនគរបាលយុត្តិធម៌ ខេត្តកំពង់ឆ្នាំង

១-ថ្នាំញៀន ០១ កញ្ចប់ ទម្ងន់ ០,២៦g

២-ទូរស័ព្ទដៃ ០១ គ្រឿង ម៉ាក NOKAI ពណ៌ខ្មៅ

**-បានឃើញ**: កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ នៅនគរបាលយុត្តិធម៌ ខេត្តកំពង់ឆ្នាំង ។

**-បានឃើញ**: កំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ នៅអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ។

**-បានឃើញ**: ពាក្យបណ្តឹងសុំមោឃកម្មកំណត់ហេតុ របស់មេធាវី ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ សុំប្តឹងឧទ្ធរណ៍ទុកជាមោឃៈនូវកំណត់ហេតុស្តាប់ចម្លើយចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០១៩ របស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង និងកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។

**-បានឃើញ**: របាយការណ៍រឿងព្រហ្មទណ្ឌចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ របស់សភាស៊ើបសួរ។

**-បានឃើញ**: សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៩ របស់មហាអយ្យការអមសាលាឧទ្ធរណ៍។

**នាពេលសវនាការ**

-ជនត្រូវចោទឈ្មោះ (អវត្តមាន)

-មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទ (វត្តមាន)

-ប្រធានក្រុមប្រឹក្សាអានរបាយការណ៍រឿង

**សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ**: ក្រោយពីបានពិនិត្យសំណុំរឿង និងក្រោយពីបានស្តាប់នូវរបាយការណ៍របស់ប្រធានក្រុមប្រឹក្សា តំណាងមហាអយ្យការយល់ឃើញថា ពាក្យបណ្តឹងសុំមោឃកម្មកំណត់ហេតុស្តាប់ចម្លើយរបស់មេធាវី ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ ដោយប្តឹងសុំមោឃភាពនូវកំណត់ហេតុស្តាប់ចម្លើយចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ របស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង និងកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។ យល់ឃើញថាពាក្យបណ្តឹងសុំមោឃកម្មនេះគឺធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់តាមមាត្រា៥៥ និងមាត្រា ២៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ យល់ឃើញថាតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន តាមបញ្ញត្តិមាត្រា២២ និងមាត្រា២៦ ការស្តាប់ចម្លើយរបស់អនីតិជនតម្រូវឲ្យមានមេធាវីនៅជាមួយ

ហើយការស្តាប់ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង និងការស្តាប់ចម្លើយរបស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង គឺពុំមានវត្តមានរបស់មេធាវីនៅពេលស្តាប់ចម្លើយរបស់អនីតិជនទេ ហេតុដូច្នេះសូមក្រុមប្រឹក្សាពិនិត្យ និងពិចារណាបញ្ញត្តិមាត្រា ២២ និងមាត្រា ២៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទធ្វើសេចក្តីសន្និដ្ឋានថាៈ ក្នុងរឿងក្តីនេះគឺលោកមេធាវី ប្តឹងសុំមោឃភាពនូវកំណត់យកចម្លើយនៅដំណាក់នគរបាលយុត្តិធម៌ និងដំណាក់កាលអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ហើយតាមកំណត់ហេតុទាំងពីរនេះ គឺពិតជាគ្មានមេធាវី ឬអ្នកតំណាង ឬអាណាព្យាបាលណាមួយដែលបានចូលរួមស្តាប់ការយកចម្លើយនោះទេ ដែលផ្ទុយនឹងបញ្ញត្តិមាត្រា ២២ និងមាត្រា ២៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលច្បាប់នេះចូលជាធរមានតាំងពីឆ្នាំ២០១៦ ដូច្នេះគប្បី តុលាការជួយពង្រឹងចំណុចនេះ ហើយសុំឲ្យក្រុមប្រឹក្សាសម្រេចមោឃភាពនូវកំណត់ទាំងពីរខាងលើនេះចោល។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទ

-ក្រោយពីបានពិនិត្យកស្តុតាងដែលពាក់ព័ន្ធនិងរឿងក្តី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សភាស៊ើបសួរយល់ឃើញថាៈ

១-ពាក្យបណ្តឹងសុំមោឃកម្មកំណត់ហេតុ របស់មេធាវី ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ សុំប្តឹងឧទ្ធរណ៍ទុកជាមោឃនូវកំណត់ហេតុស្តាប់ចម្លើយចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ របស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង និងកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង បានធ្វើឡើងត្រឹមត្រូវតាមច្បាប់ សភាស៊ើបសួរទទួលសំណុំរឿងខាងលើនេះ ជំនុំជម្រះបាន យោងតាមមាត្រា ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន និងសំណូមពរថាៈ ក្រោយពីបានពិនិត្យសំណុំរឿង ក្រោយពីបានស្តាប់នូវរបាយការណ៍របស់ចៅក្រមក្រុមប្រឹក្សា តំណាងមហាអយ្យការយល់ឃើញថាពាក្យបណ្តឹងសុំមោឃកម្មកំណត់ហេតុស្តាប់ចម្លើយរបស់មេធាវី ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ ដោយប្តឹងសុំមោឃភាពនូវកំណត់ហេតុស្តាប់ចម្លើយចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ របស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង និងកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។ យល់ឃើញថាពាក្យបណ្តឹងសុំមោឃកម្មនេះគឺធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់តាមមាត្រា២៤៥ និងមាត្រា ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ យល់ឃើញថាតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន តាមបញ្ញត្តិមាត្រា ២២ និងមាត្រា ២៦ ការស្តាប់ចម្លើយរបស់អនីតិជនតម្រូវឲ្យមានមេធាវីនៅជាមួយ ហើយការស្តាប់ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង និងការសួរចម្លើយរបស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង គឺពុំមានវត្តមានរបស់មេធាវីនៅពេលស្តាប់ចម្លើយរបស់អនីតិជនទេ ហេតុដូច្នេះសូមក្រុមប្រឹក្សាពិនិត្យ និងពិចារណាបញ្ញត្តិមាត្រា ២២ និងមាត្រា ២៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ គប្បីសភាស៊ើបសួរពិចារណា និងសម្រេច ។

៣-មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទធ្វើសេចក្តីសន្និដ្ឋានថាៈ ក្នុងរឿងក្តីនេះគឺលោកមេធាវី ប្តឹងសុំមោឃភាពនូវកំណត់យកចម្លើយនៅដំណាក់នគរបាលយុត្តិធម៌ និងដំណាក់កាលអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ហើយតាមកំណត់ហេតុទាំងពីរនេះ គឺពិតជាគ្មានមេធាវី ឬអ្នកតំណាង ឬអាណាព្យាបាល

ណាមួយដែលបានចូលរួមស្តាប់ការយកចម្លើយនោះទេ ដែលផ្ទុយនឹងបញ្ញត្តិមាត្រា ២២ និងមាត្រា ២៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលច្បាប់នេះចូលជាធរមានតាំងពីឆ្នាំ២០១៦ ដូច្នេះគប្បី តុលាការជួយពង្រឹងចំណុចនេះ ហើយសុំឲ្យក្រុមប្រឹក្សាសម្រេចមោឃភាពនូវកំណត់ទាំងពីខាងលើនេះចោល។ គប្បីសភាស៊ើបសួរពិចារណា និងសម្រេច ។

៤-តាមលទ្ធផលនៃកិច្ចពិភាក្សាសួរដេញដោលសភាស៊ើបសួរឃើញថាៈ ពាក្យបណ្តឹងសុំមោឃកម្មកំណត់ហេតុ របស់មេធាវី ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ សុំប្តឹងឧទ្ធរណ៍ទុកជាមោឃនូវកំណត់ហេតុស្តាប់ចម្លើយចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ របស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង និងកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ដោយលើកហេតុថា កំណត់ហេតុខាងលើនេះ គឺកត់ត្រាខុសពីអ្វីដែលកូនក្តីខ្លួនបានឆ្លើយ។ម្យ៉ាងវិញទៀតឈ្មោះ គឺជាអនីតិជន អាយុ ១ ឆ្នាំ ដែលត្រូវការមានមេធាវី ឬអាណាព្យាបាលអមជានិច្ចនៅក្នុងនីតិវិធី យោងតាមមាត្រា ២៦ កថាខណ្ឌទី២ និងកថាខណ្ឌទី១០ និងមាត្រា ២៦ កថាខណ្ឌទី២ និងកថាខណ្ឌទី៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប៉ុន្តែកំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៩ របស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង និងនិងកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង គឺពុំមានវត្តមានរបស់មេធាវី ឬអាណាព្យាបាលរបស់កូនក្តីខ្លួនឡើយ។

ដូច្នេះសភាស៊ើបសួរយល់ឃើញថា នៅដំណាក់កាលនគរបាលយុត្តិធម៌ និងដំណាក់កាលអយ្យការបានដំណើរការនីតិវិធីស្តាប់ចម្លើយលើជនត្រូវចោទ ឈ្មោះ ក្នុងឋានៈជាអនីតិជនពុំមានមេធាវីការពារសិទ្ធិ ឬឪពុកម្តាយ ឬ អាណាព្យាបាលចូលរួម គឺផ្ទុយនឹងស្មារតីមាត្រា ១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ២២ និងមាត្រា ២៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ មាត្រាខាងលើនេះ មានចែងអំពីវិធានដែលបានបញ្ញត្តិនៅក្នុងមាត្រានេះមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នេះទេនឹងនាំឲ្យមានមោឃភាពនីតិវិធី។

ពាក្យប្តឹងសុំឲ្យមោឃកម្មកំណត់ហេតុស្តាប់ចម្លើយចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ របស់មេធាវី ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ មានមូលហេតុត្រឹមត្រូវតាមច្បាប់។ យោងតាមមាត្រា ២៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គប្បីសភាស៊ើបសួរសម្រេចមោឃភាពនូវកំណត់ហេតុស្តាប់ចម្លើយចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ របស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង និងកំណត់ហេតុសួរចម្លើយចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងសុំមោឃកម្មកំណត់ហេតុស្តាប់ចម្លើយចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ របស់មេធាវី ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-ទុកជាមោឃៈនូវកំណត់ហេតុស្តាប់ចម្លើយចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ របស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង និងកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។

៣-ត្រូវដកចេញពីសំណុំរឿងនូវកំណត់ហេតុស្តាប់ចម្លើយចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ របស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង និងកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ហើយត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ ។

៤-សម្រេចបង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ           រុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទៅសាលាដំបូងខេត្តកំពង់ឆ្នាំង ដើម្បីចាត់ការតាមច្បាប់បន្ត ។

សាលដីកានេះ ពិភាក្សាសួរដេញដោលជាអសាធារណៈ និងប្រកាសជាអសាធារណៈនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩ ។

បើកសិទ្ធិប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រុមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃសុក្រ ៨កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សាលាឧទ្ធរណ៍,ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ២០១៩
**ក្រឡាបញ្ជី**

**បានឃើញ**
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

# ឧបសម្ព័ន្ធទី១៩

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ ភ្នំពេញ

សភាស៊ើបសួរ
សំណុំរឿងព្រហ្មទណ្ឌ
លេខ
ចុះថ្ងៃទី២៩-០៨-២០១៩
សាលដីកាព្រហ្មទណ្ឌ
លេខ:
ចុះថ្ងៃទី២០-០៩-២០១៩

សភាស៊ើបសួរបង្កើតឡើង តាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ បានបើកកិច្ចពិភាក្សាដេញដោលអសាធារណៈ នៅសាលសវនាការសាលាឧទ្ធរណ៍នាថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក ជាប្រធានក្រុមប្រឹក្សា

លោក ជាចៅក្រមប្រឹក្សា

លោក ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក

ដើម្បីដំណើរការកិច្ចពិភាក្សាដេញដោលលើបណ្តឹងឧទ្ធរណ៍នៃរឿងស៊ើបសួរលេខ: ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៩ ដែលមាន:

-ជនត្រូវចោទឈ្មោះ កេទប្រុស អាយុ៤១ឆ្នាំ ជាតិខ្មែរ មុខរបរ លក់បបរគ្រឿង មានទី កន្លែងកំណើតនៅភូមិស្រែជា ឃុំ , ស្រុក ខេ ទីលំនៅមុនពេលឃាត់ខ្លួន ក្រុម១ ខេត្ត ឪពុកឈ្មោះ ម្តាយឈ្មោះ ប្រពន្ធឈ្មោះ មានកូនចំនួន ០២នាក់ ជានីតិជន ទោសពីមុន គ្មាន ។

មានលោកមេធាវី ការពារសិទ្ធិឲ្យជនត្រូវចោទ ។

<u>ចៅក្រមស៊ើបសួរដាក់ស្ថិតឲ្យនៅក្រោមការពិនិត្យពីបទៈរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់</u> ទងនឹងជនរងគ្រោះ ប្រព្រឹត្តនៅចំណុចភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីពាក់ កណ្តាលខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ ចំណុច ទី៣ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ទស្រី អាយុ ៤៧ឆ្នាំ ជាតិខ្មែរ មុខរបរ លក់នំបញ្ចុក មានទី លំនៅបច្ចុប្បន្នផ្ទះជួល ភូ ស

**<u>ការប្រព្រឹត្តរបស់ជនត្រូវចោទមានដូចតទៅ:</u>**

កាលពីពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង០០នាទីព្រឹក ស្ថិតនៅចំណុចភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានករណីរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសមួយកើត ឡើង ប្រព្រឹត្តដោយជនសង្ស័យឈ្មោ កេទប្រុស បានធ្វើសកម្មភាពចាប់រំលោភលើជនរងគ្រោះ ឈ្មោះ កេទស្រី អាយុ២៨ឆ្នាំ (មានសតិមិនប្រក្រតី) ដោយបបួលជនរងគ្រោះទៅកើអុសនៅលើភ្នំ

លុះដល់កន្លែងស្ងាត់កម្លេសកម្មភាពម្តែបេមនរេគ្រោះ...

សង្ស័យបានចាប់រំលោភជនរងគ្រោះជាបន្តបន្ទាប់រហូតដល់ជនរងគ្រោះមានផ្ទៃពោះ ។

-**បានឃើញ**: ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ១៩ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

បើកការស៊ើបសួរលើអង្គហេតុ **រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ** និងស្នើសុំ៖

-ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យលើ: ឈ្មោះ កទប្រុស ពីបទ: **រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ** តាមបញ្ញត្តិមាត្រា ២៤១ ចំណុចទី៣ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង០០នាទី ។

-ដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនជាបណ្តោះអាសន្នលើឈ្មោះ ទប្រុស ។

-**បានឃើញ**: កំណត់ហេតុស្តីពីការឃាត់ខ្លួន ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់មន្ត្រីនគរបាលយុត្តិធម៌ក្រុងព្រះសីហនុ បានបញ្ជាក់ថា: នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង២០នាទី កំលាំងនៃអធិការដ្ឋាននគរបាលក្រុងព្រះសីហនុ បានធ្វើការឃាត់ខ្លួនជនសង្ស័យឈ្មោះ ទប្រុស អាយុ ៤១ឆ្នាំ មុខរបរ លក់បបរគ្រឿងតាមរទេះ ស្នាក់នៅបន្ទប់ជួលក្រុមទី១២ ភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ក្នុងបទ: **រំលោភសេពសន្ថវៈ** កាលពីអំឡុងពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង០០នាទីព្រឹក នៅភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

-**បានឃើញ**: កំណត់ហេតុសរុបនៃការឃាត់ខ្លួន ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៩ របស់មន្ត្រីនគរបាល យុត្តិធម៌ក្រុងព្រះសីហនុ បានបញ្ជាក់ថា: កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង ២០នាទី សមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនសង្ស័យម្នាក់ឈ្មោះ ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិខ្មែរបានប្រព្រឹត្តពីបទ: **រំលោភសេពសន្ថវៈ** កាលពីពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០១៩ នៅចំណុចភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

-**បានឃើញ**: កំណត់ហេតុស្រង់ចម្លើយជនសង្ស័យឈ្មោះ ុះថ្ងៃទី២២ ខែមីនា ឆ្នាំ ២០១៩ របស់មន្ត្រីនគរបាលយុត្តិធម៌ក្រុងព្រះសីហនុ បានបញ្ជាក់ថា: ខ្លួនមិនចេះប្រើប្រាស់គ្រឿងញៀនអ្វីទេ ការលេង ល្បែងស៊ីសង និងសកម្មភាពលួច ឆក់ ប្លន់ ខ្លួនមិនដែលប្រព្រឹត្តឡើយ ។

ខ្លួនមិនចាំថ្ងៃតែនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ០៨ព្រឹក ខ្លួនបានជិះម៉ូតូតែម្នាក់ឯង ចេញពីផ្ទះក៏ឃើញឈ្មោះ កទស្រី កំពុងដើរតែម្នាក់ឯងនៅជិតផ្ទះរបស់វា ដោយឈ្មោះ ពាក់ខោអាវឈុតពណ៌ក្រហម ខ្លួនក៏បបួលឈ្មោះ វាទៅរកអុសនៅម្តុំអូរ៤ ជិតសាលារៀនដុនបូស្កូ ចូលតាមផ្លូវលំទៅក្នុងព្រៃប្រហែលកន្លះគីឡូដី ពេលទៅដល់ក្នុងព្រៃកន្លែងគ្មានមនុស្សនៅស្ងាត់ផង ខ្លួនក៏សុំឈ្មោះ កាន់ ទំ រំលោភសេពសន្ថវៈហើយខ្លួនចាប់ស្រាតខោឈ្មោះ នាះ ដោយមិនមានពាក់លីអូទេ ហើយខ្លួនក៏ មិនបានដោះអាវឈ្មោះ នោះចេញដែរ បន្ទាប់មកខ្លួនក៏បានធ្វើសកម្មភាពរំលោភសេពសន្ថវៈឈ្មោះ ,នាះបានសម្រេចដោយមិនបានប្រើស្រោមអនាម័យឡើយ ពេលរំលោករួចហើយខ្លួនក៏បានជិកឈ្មោះ ត្រឡប់មកផ្ទះវិញតែម្តង។ លុះដល់ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ០៤រសៀល ខ្លួនកំពុងនៅផ្ទះក៏ឃើញសមត្ថកិច្ចមក ឃាត់ខ្លួនៗតែម្តង ។

-**បានឃើញ**: ពាក្យសុំមោឃភាពនៃនីតិវិធីចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ របស់លោកមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ ) សុំមកសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ សុំមោឃភាពឯកសាររបស់មន្ត្រីនគរបាលយុត្តិធម៌មានដូចជា កំណត់ហេតុស្តីពីការឃាត់ខ្លួន, កំណត់ហេតុសរុបនៃ

ការឃាត់ខ្លួន និងកំណត់ហេតុស្រង់ចម្លើយ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ។

-**បានឃើញ**: របាយការណ៍រឿងព្រហ្មទណ្ឌចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ របស់សភាស៊ើបសួរ។

-**បានឃើញ**: សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់មហាអយ្យការអមសាលាឧទ្ធរណ៍។

**<u>នាពេលសវនាការ</u>**

-ជនត្រូវចោទឈ្មោះ (អវត្តមាន)

-មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទ (វត្តមាន)

-ប្រធានក្រុមប្រឹក្សាអានរបាយការណ៍រឿង

**មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទធ្វើការកត់សម្គាល់ថា**: កំណត់ហេតុស្រង់ចម្លើយ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ គឺមិនមែនជាកំណត់ហេតុដែលមានចែងនៅក្នុងបញ្ញត្តិមាត្រា ៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នោះទេ ព្រោះថាតាមបញ្ញត្តិមាត្រា៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺជាកំណត់ហេតុលើការស្តាប់ចម្លើយ។ ចំពោះកំណត់ហេតុស្តីពីការឃាត់ខ្លួន និងកំណត់ហេតុសរុបនៃការឃាត់ខ្លួន ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ គឺគ្មានការជូនដំណឹងទៅព្រះរាជអាជ្ញានោះទេ ហើយបទល្មើសនោះគឺមិនមែនជាបទល្មើសជាក់ស្តែង ដោយយោងតាមបញ្ញត្តិមាត្រា ៩៦, មាត្រា ៩៧, មាត្រា៩៨, និងមាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ**: នៅក្នុងរឿងសុំមោឃភាពនីតិវិធី ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ របស់លោកមេធាវី ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ គឺមាន ៣ ចំណុច គឺទី១ កំណត់ហេតុស្រង់ចម្លើយ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ខុសចំណងជើង តាមបញ្ញត្តិមាត្រា ៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តំណាងមហាអយ្យការយល់ឃើញថា មាត្រា៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គ្រាន់តែខុសចំណងជើងគឺមិនអាចសុំមោឃភាពបានទេ ហើយចំណុចទី២ កំណត់ហេតុឃាត់ខ្លួន និងកំណត់ហេតុសរុបនៃការឃាត់ខ្លួន ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ តំណាងមហាអយ្យការយល់ឃើញថា ការលើកឡើងរបស់មេធាវីគឺមិនច្បាស់លាស់ ដោយលោកមេធាវីលើកឡើងថាមិនបានជូនដំណឹងទៅព្រះរាជអាជ្ញាគឺមិនត្រឹមត្រូវនោះទេ ព្រោះថានៅក្នុងកំណត់ហេតុឃាត់ខ្លួនគឺបានដាក់ថា បានជូនដំណឹងទៅព្រះរាជអាជ្ញារួចហើយ ហើយនៅក្នុងកំណត់ហេតុឃាត់ខ្លួននោះគឺឃាត់ខ្លួនតាមបញ្ជារបស់ព្រះរាជអាជ្ញា ដូច្នេះនីតិវិធីដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌នៅដំណាក់កាលស៊ើបអង្កេតបឋមរហូតដល់បញ្ជូនទៅព្រះរាជអាជ្ញាបើកការស៊ើបសួរនោះ គឺត្រឹមត្រូវតាមលំហូរនីតិវិធីដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។

**មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទធ្វើសេចក្តីសន្និដ្ឋានថា**: នៅក្នុងរឿងនេះគឺកូនក្តីខ្លួនពឹងពាក់ឲ្យប្តឹងមោឃភាពកំណត់ហេតុចំនួន ៣គឺកំណត់ហេតុស្រង់ចម្លើយ, កំណត់ហេតុស្តីពីការឃាត់ខ្លួន និងកំណត់ហេតុសរុបនៃការឃាត់ខ្លួន ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ ដោយហេតុថាការឃាត់ខ្លួនកូនក្តីរបស់ខ្លួនគឺខុសនីតិវិធីច្បាប់ មានន័យថាបទល្មើសនោះដែលមន្ត្រីនគរបាលយុត្តិធម៌បានឃាត់ខ្លួននោះគឺមិនមែនជាបទល្មើសជាក់ស្តែងនោះទេ ហើយការឃាត់ខ្លួននោះ តាមផ្លូវច្បាប់លុះត្រាតែមានការជូនដំណឹង និងការយល់ព្រមពីព្រះរាជអាជ្ញាជាលាយលក្ខណ៍អក្សរ ប៉ុន្តែពុំមានការហត្ថលេខា ឬចំណារជាលាយលក្ខណ៍អក្សរនៅលើកំណត់ហេតុឃាត់ខ្លួន ឬឯកសារណាមួយពីព្រះរាជអាជ្ញានោះទេ ដែលផ្ទុយនឹងនីតិវិធីច្បាប់ តាមបញ្ញត្តិមាត្រា ៩៦, មាត្រា ៩៧ និងមាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះកំណត់ហេតុសរុបនៃការឃាត់ខ្លួន ក៏ដូចគ្នាដែរ គឺខុសនឹងនីតិវិធីច្បាប់ដូចការលើកឡើងតាមបញ្ញត្តិមាត្រា

ខាងលើនេះដែរ ហើយចំពោះកំណត់ហេតុស្រង់ចម្លើយ [illegible]
មាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដូច្នេះច្បាប់បានចែងរួចហើយ ពាក្យថាខុស ឬផ្ទុយ សភាស៊ើបសួរត្រូវតែមោឃភាព ទោះបីជាចំណងជើងក៏ដោយ ឲ្យតែខុសគឺត្រូវតែមោឃភាព។ ចំពោះការសុំមោឃភាពនោះ គឺខ្លួននៅតែរក្សាពាក្យបណ្តឹងសុំមោឃភាពនីតិវិធីចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ ទុកទាំងស្រុងដដែល ដោយយោងតាមបញ្ញត្តិមាត្រា ៩៣, មាត្រា ៩៤, មាត្រា ៩៦, មាត្រា ៩៧ និងមាត្រា ៩៨ និងមាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទ

-ក្រោយពីបានពិនិត្យកស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**<u>សភាស៊ើបសួរយល់ឃើញថា:</u>**

១-ពាក្យសុំមោឃភាពនៃនីតិវិធី ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ របស់លោកមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ , សុំប្តឹងមោឃភាពនូវកំណត់ហេតុស្តីពីការឃាត់ខ្លួន, កំណត់ហេតុសរុបនៃការឃាត់ខ្លួន និងនិងកំណត់ហេតុស្រង់ចម្លើយ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ បានធ្វើឡើងត្រឹមត្រូវតាមច្បាប់ សភាស៊ើបសួរទទួលសំណុំរឿងខាងលើនេះជំនុំជម្រះបាន យោងតាមមាត្រា ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន និងសំណូមពរថា: នៅក្នុងរឿងសុំមោឃភាពនីតិវិធី ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ របស់លោកមេធាវី ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ គឺមាន ៣ ចំណុច គឺទី១ កំណត់ហេតុស្រង់ចម្លើយ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ខុសចំណងជើង តាមបញ្ញត្តិមាត្រា ៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តំណាងមហាអយ្យការយល់ឃើញថា មាត្រា៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គ្រាន់តែខុសចំណងជើងគឺមិនអាចសុំមោឃភាពបានទេ ហើយចំណុចទី២ កំណត់ហេតុឃាត់ខ្លួន និងកំណត់ហេតុសរុបនៃការឃាត់ខ្លួន ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ តំណាងមហាអយ្យការយល់ឃើញថា ការលើកឡើងរបស់មេធាវីគឺមិនច្បាស់លាស់ ដោយលោកមេធាវីលើកឡើងថាមិនបានជូនដំណឹងទៅព្រះរាជអាជ្ញាគឺមិនត្រឹមត្រូវនោះទេ ព្រោះថានៅក្នុងកំណត់ហេតុឃាត់ខ្លួនគឺបានដាក់ថា បានជូនដំណឹងទៅព្រះរាជអាជ្ញារួចហើយ ហើយនៅក្នុងកំណត់ហេតុឃាត់ខ្លួននោះគឺឃាត់ខ្លួនតាមបញ្ជារបស់ព្រះរាជអាជ្ញា ដូច្នេះនីតិវិធីដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌នៅដំណាក់កាលស៊ើបអង្កេតបឋម រហូតដល់បញ្ជូនទៅព្រះរាជអាជ្ញាបើកការស៊ើបសួរនោះ គឺត្រឹមត្រូវតាមលំហូរនីតិវិធីដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ គប្បីសភាស៊ើបសួរពិចារណា និងសម្រេច ។

៣-មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទធ្វើសេចក្តីសន្និដ្ឋានថា: នៅក្នុងរឿងនេះគឺកូនក្តីខ្លួនពឹងពាក់ឲ្យប្តឹងមោឃភាពកំណត់ហេតុចំនួន ៣គឺកំណត់ហេតុស្រង់ចម្លើយ, កំណត់ហេតុស្តីពីការឃាត់ខ្លួន និងកំណត់ហេតុសរុបនៃការឃាត់ខ្លួន ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ ដោយហេតុថាការឃាត់ខ្លួនកូនក្តីរបស់ខ្លួនគឺខុសនីតិវិធីច្បាប់ មានន័យថាបទល្មើសនោះដែលមន្ត្រីនគរបាលយុត្តិធម៌បានឃាត់ខ្លួននោះគឺមិនមែនជាបទល្មើសជាក់ស្តែងនោះទេ ហើយការឃាត់ខ្លួននោះ តាមផ្លូវច្បាប់លុះត្រាតែមានការជូនដំណឹង និងការយល់ព្រមពីព្រះរាជអាជ្ញាជាលាយលក្ខណ៍អក្សរ ប៉ុន្តែពុំមានការហត្ថលេខា ឬចំណារជាលាយលក្ខណ៍អក្សរនៅលើកំណត់ហេតុឃាត់ខ្លួន ឬឯកសារណាមួយពីព្រះរាជអាជ្ញានោះទេ ដែលផ្ទុយនឹងនីតិវិធីច្បាប់ តាមបញ្ញត្តិមាត្រា ៩៦, មាត្រា ៩៧ និងមាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ចំពោះកំណត់ហេតុសរុបនៃការឃាត់ខ្លួន ក៏ដូចគ្នាដែរ [illegible] មាត្រាខាងលើនេះដែរ ហើយចំពោះកំណត់ហេតុស្រង់ចម្លើយ គឺគ្មានចែងទេនូវពាក្យថាស្រង់ចម្លើយ តាមបញ្ញត្តិមាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដូច្នេះច្បាប់បានចែងរួចហើយ ពាក្យថាខុស ឬផ្ទុយ សភាស៊ើបសួរត្រូវតែមោឃភាព ទោះបីជាចំណងជើងក៏ដោយ ឲ្យតែខុសគឺត្រូវតែមោឃភាព។ ចំពោះការសុំមោឃភាពនោះ គឺខ្លួននៅតែរក្សាពាក្យបណ្ដឹងសុំមោឃភាពនីតិវិធីចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ ទុកទាំងស្រុងដដែល ដោយយោងតាមបញ្ញត្តិមាត្រា ៩៣, មាត្រា ៩៤, មាត្រា ៩៦, មាត្រា ៩៧ និងមាត្រា ៩៨ និងមាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ គប្បីសភាស៊ើបសួរពិចារណា និងសម្រេច ។

៤-តាមលទ្ធផលនៃកិច្ចពិភាក្សាសួរដេញដោល សភាស៊ើបសួរឃើញថាៈ ពាក្យសុំមោឃភាពនៃនីតិវិធី ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ របស់លោកមេធាវី ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ , ៖ សុំប្ដឹងមោឃភាពនូវកំណត់ហេតុស្ដីពីការឃាត់ខ្លួន, កំណត់ហេតុសរុបនៃការឃាត់ខ្លួន និងកំណត់ហេតុស្រង់ចម្លើយ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ ដោយលើកមូលហេតុថា កំណត់ហេតុខាងលើនេះ គឺសមត្ថកិច្ចសម្លុតឲ្យកូនក្ដីខ្លួនឆ្លើយសារភាព ផ្ទុយនឹងបញ្ញត្តិច្បាប់ដូចជាៈ

កំណត់ហេតុស្រង់ចម្លើយ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ គឺធ្វើឡើងដោយផ្ទុយនឹងបញ្ញត្តិមាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយបានបញ្ជាក់ថា ខុសទម្រង់ និងពុំមែនជាប្រភេទកំណត់ហេតុ ដូចមានចែងក្នុងមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌឡើយ។ ម្យ៉ាងវិញទៀតតាមរយៈអង្គហេតុ និងចម្លើយរបស់ឈ្មោះ ត្រូវជាម្ដាយរបស់ឈ្មោះ បានបញ្ជាក់ថា បទល្មើសគឺកើតឡើងតាំងពីពាក់កណ្ដាលខែកុម្ភៈ ឆ្នាំ២០១៩ ហើយរហូតដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ ទើបឈ្មោះ ប្រាប់ថាឈ្មោះ ចាប់រំលោភច្រើនដង។ តាមរយៈអង្គហេតុខាងលើនេះ ឃើញថា មិនមែនជាបទល្មើសជាក់ស្ដែងទេ ព្រោះថាតាមបញ្ញត្តិមាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា រយៈពេលនៃការស៊ើបអង្កេតបទល្មើសជាក់ស្ដែងមិនអាចលើសពី ៧ថ្ងៃ គិតចាប់ពីថ្ងៃប្រព្រឹត្តិបទល្មើស។ ដូច្នេះបទល្មើសកើតឡើងតាំងពីពាក់កណ្ដាលខែកុម្ភៈ ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ទើបមន្ត្រីនគរបាលយុត្តិធម៌ ចាប់ផ្ដើមស៊ើបអង្កេតបឋម ដែលមិនគោរពវិធានក្នុងមាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ចំពោះកំណត់ហេតុស្ដីពីការឃាត់ខ្លួន និងកំណត់ហេតុសរុបនៃការឃាត់ខ្លួន ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ ២០១៩ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ គឺពុំមានការយល់ព្រមឯកភាពជាលាយលក្ខណ៍អក្សរពីព្រះរាជអាជ្ញា និងមិនបានប្រាប់អំពីសិទ្ធិមានជំនួយមេធាវី ដែលផ្ទុយនឹងបញ្ញត្តិមាត្រា ៩៦ និងមាត្រា៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សរុបមក ឯកសារដូចបានរៀបរាប់ខាងលើ ដែលមន្ត្រីនគរបាលយុត្តិធម៌ បានកសាងឡើងដើម្បីចាប់ឃាត់កូនក្ដីខ្លួន គឺខុសទៅនឹងមាត្រា ៩៣,មាត្រា ៩៤, មាត្រា៩៦ កថាខណ្ឌទី៣, មាត្រា៩៧, មាត្រា៩៨ និង មាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សភាស៊ើបសួរយល់ឃើញថាៈ កំណត់ហេតុស្រង់ចម្លើយ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ គឺធ្វើឡើងត្រឹមត្រូវតាមទម្រង់បញ្ញត្តិមាត្រា៩៣ និងមាត្រា ៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយមានស្នាមមេដៃទទួលស្គាល់លើកំណត់ហេតុស្រង់ចម្លើយនោះ និងមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទអះអាងថានៅពេលដែលសមត្ថកិច្ចសួរចំលើយកូនក្ដីខ្លួន បានសម្លុតគំរាមឲ្យកូនក្ដីរបស់ខ្លួនឆ្លើយនោះ ពុំមានភស្តុតាងយកមកបញ្ជាក់ឲ្យសភាស៊ើបសួរជឿជាក់បានឡើយ រីឯនាពេលសវនាការ មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទបានអះអាងបន្ថែមថា សមត្ថកិច្ចបានសរសេរចំណងជើងថា កំណត់ហេតុស្រង់ចម្លើយ ខុសនឹងមាត្រា ៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សភាស៊ើបសួរយល់ឃើញថា ការលើកឡើងរបស់មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទខាងលើនេះ ពុំមែនជាមូលហេតុធ្វើឲ្យកំណត់ហេតុរបស់សមត្ថកិច្ចមោឃភាព

បានឡើយ។ ម្យ៉ាងវិញទៀត មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទបានលើកឡើងថាបទល្មើសកើតឡើងតាំងពីពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ទើបមន្ត្រីនគរបាលយុត្តិធម៌ចាប់ផ្តើមស៊ើបអង្កេតបឋម ដែលមិនគោរពវិធានក្នុងមាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលកំណត់រយៈពេលបទល្មើសជាក់ស្តែងគឺមានរយៈពេលត្រឹមតែ ៧ថ្ងៃ គឺមិនត្រឹមត្រូវនោះទេ ព្រោះថាក្នុងករណីដែលផុតរយៈពេលស៊ើបអង្កេតជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមបាន កាលណាបានដឹងអំពីបទល្មើសកើតឡើង តាមបញ្ញត្តិមាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ចំពោះកំណត់ហេតុស្តីពីការឃាត់ខ្លួន និងកំណត់ហេតុសរុបនៃការឃាត់ខ្លួន ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ មន្ត្រីនគរបាលយុត្តិធម៌ក៏បានជូនដំណឹងដល់ព្រះរាជអាជ្ញា ទើបមានបញ្ជាពីព្រះរាជអាជ្ញាឲ្យធ្វើការឃាត់ខ្លួនជនសង្ស័យនោះ។ ដូច្នេះកំណត់ហេតុស្រង់ចម្លើយ, កំណត់ហេតុឃាត់ខ្លួន និងកំណត់ហេតុសរុបនៃការឃាត់ខ្លួន ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ ធ្វើឡើងនៅដំណាក់កាលស៊ើបអង្កេតបឋម គឺមានលក្ខណៈត្រឹមត្រូវតាមលំហូរនីតិវិធីដែលមានចែងនៅក្នុងមាត្រា ៩៣, មាត្រា ៩៤, មាត្រា ៩៦, មាត្រា ៩៧, មាត្រា ៩៨ និងមាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ពាក្យសុំមោឃភាពនៃនីតិវិធី ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ របស់លោកមេធាវី ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ សភាស៊ើបសួរយល់ឃើញថា គ្មានសំអាងហេតុ និងគ្មានមូលកភាពយ៉ាងជាក់ស្តែង ហេតុដូច្នេះសភាស៊ើបសួរប្រកាសថាពាក្យសុំមោឃភាពនៃនីតិវិធី ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ របស់លោកមេធាវី ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោ មិនអាចទទួលយកបាន ។ យោងតាមមាត្រា ២៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ប្រកាសថា ពាក្យសុំមោឃភាពនៃនីតិវិធី ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ របស់លោកមេធាវី ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ **មិនអាចទទួលយកបាន។**

២-សម្រេចបង្វិលសំណុំរឿងព្រហ្មទណ្ឌលេខៈ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទៅសាលាដំបូងខេត្តសីហនុ ដើម្បីចាត់ការបន្ត ។

សាលដីកានេះ ពិភាក្សាសួរដេញដោលជាអសាធារណៈ និងប្រកាសជាអសាធារណៈនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- |
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃសុក្រ ៧រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សាលាឧទ្ធរណ៍,ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ២០១៩
**ក្រឡាបញ្ជី**

**បានឃើញ**
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

# ឧបសម្ព័ន្ធទី២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាឧទ្ធរណ៍**

លេខ: ... ......បឧ/២០១៩

## ដីកាបញ្ជូន

**សូមគោរពជូន**
**ឯកឧត្តម អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍**

| រាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|
| សាលដីកាព្រហ្មទណ្ឌលេខ រៈថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍។ | ០១ ច្បាប់ | ដើម្បីចាត់ការតាមនីតិវិធី |
| សាលដីកាព្រហ្មទណ្ឌលេខ ស.ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ។ | ០១ ច្បាប់ | |
| សរុប | ០២ ច្បាប់ | |

ទទួល: ០៩/០៩/2019

ថ្ងៃចន្ទ ១១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សាលាឧទ្ធរណ៍ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩
ជ.ប្រធាន